# សូមក្រាបបង្គំទូលថ្វាយ
# ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
# ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា



## ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត

### ក្នុងឱកាសដ៏មហានក្ខត្តឫក្សឧត្តុង្គឧត្តមថ្លៃថ្លាបំផុតនៃពិធីខួបលើកទី ៩ នៃការឡើងគ្រងរាជសម្បត្តិរបស់ព្រះករុណា ជាអម្ចាស់

*ទូលព្រះបង្គំយើងខ្ញុំសូមព្រះបរមរាជានុញ្ញាតថ្វាយព្រះរាជស័ព្ទសាធុការពរ សិរីសួស្តី ជ័យមង្គល បវរមហាប្រសើរ ថ្វាយព្រះករុណាជាអម្ចាស់ សូមព្រះអង្គមានព្រះរាជសុខភាពល្អបរិបូណ៌ ព្រះកាយពលមាំមួន ព្រះបញ្ញាញាណភ្លឺថ្លា ព្រះជន្មាយុយឺនយូរ និងសម្រេចបានព្រះមហាជោគជ័យសិរីមង្គលគ្រប់ប្រការ ប្រកបដោយព្រះតេជបារមីភ្លឺចិញ្ចាចចិញ្ចែង ដើម្បីគង់នៅជាម្លប់ដ៏ត្រជាក់ត្រជុំរបស់ប្រជារាស្ត្រកម្ពុជាគ្រប់រូប ។*

*រយៈពេល ៩ ឆ្នាំ នៃការឡើងគ្រងរាជសម្បត្តិរបស់ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង បាននាំមកនូវភាពកក់ក្តៅ និងភាពសុខក្សេមក្សាន្ត ចំរុងចម្រើនឥតឈប់ឈររបស់ប្រទេសជាតិ និងប្រជារាស្ត្រកម្ពុជាទាំងមូល ។*

*សូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ កែវទាំងបី វត្ថុស័ក្តិសិទ្ធិក្នុងលោក ទេវតាថែរក្សាព្រះមហាស្វេតច្ឆ័ត្រ និងព្រះបារមីអតីតព្រះមហាក្សត្រ ព្រះមហាក្សត្រិយានីខ្មែរគ្រប់ព្រះអង្គ សូមប្រោះព្រំ ទ្រទ្រង់ថែរក្សាព្រះករុណាជាទីគោរព សក្ការៈ ជានិច្ចនិរន្តរ៍តរៀងទៅ ។*

*សូមព្រះករុណាថ្លៃវិសេស ទ្រង់ព្រះរាជមេត្តាប្រោស ទទួលនូវគារវភក្តីដ៏ខ្ពង់ខ្ពស់បំផុតពីទូលព្រះបង្គំយើងខ្ញុំ ។*

**ក្រាបបង្គំទូលថ្វាយដោយភក្តីគោរព និងកតញ្ញូតាធម៌ដ៏ខ្ពង់ខ្ពស់បំផុត**

***ទស្សនាវដ្តីប្រជាជន***

# សូមប្រសិទ្ធពរបវរមហាប្រសើរជូន

# សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម

## ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា
## និងជាប្រធានគណបក្សប្រជាជនកម្ពុជា



## ក្នុងឱកាសដ៏មហានក្ខត្តឫក្សនៃទិវាគម្រប់ជន្មាយុ ៨១ វស្សា ឈានចូល ៨២ វស្សារបស់សម្តេច
## (១៥.១១.១៩៣២-១៥.១១.២០១៣)

យើងខ្ញុំទាំងអស់គ្នាសូមសម្តែងគារវភក្តី និងកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅបំផុតជូនសម្តេចអគ្គមហាធម្មពោធិសាល ***ជា ស៊ីម*** អគ្គមគ្គុទ្ទេសដ៏វិសេសវិសាលនៃប្រជាជនកម្ពុជា ដែលបានតស៊ូពុះពារ និងលះបង់អស់កម្លាំងកាយ កម្លាំងចិត្ត បញ្ញា ស្មារតី ដើម្បីបុព្វហេតុឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដី សន្តិភាព សេរីភាព ប្រជាធិបតេយ្យ និងវឌ្ឍនភាពនៃប្រទេសកម្ពុជា ។

សូមគោរពជូនពរ ***សម្តេចអគ្គមហាធម្មពោធិសាល*** សូមបានប្រកបនូវពុទ្ធពរទាំង៤ ប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ ជារៀងដរាប ដើម្បីបន្តដឹកនាំមាតុភូមិកម្ពុជា និងគណបក្សប្រជាជនកម្ពុជា ឆ្ពោះទៅរកជោគជ័យធំៗថ្មីៗទៀត ក្នុងបុព្វហេតុកសាង អភិវឌ្ឍន៍ និងការពារមាតុភូមិ ។

***ដោយក្តីគោរព និងដឹងគុណដ៏ខ្ពង់ខ្ពស់បំផុត***

**ទស្សនាវដ្តីប្រជាជន**

# រួបរួមកម្លាំងជាតិ ជម្នះផលវិបាកនៃគ្រោះទឹកជំនន់ដ៏ធ្ងន់ធ្ងរ

ក្នុងរដូវវស្សាឆ្នាំ ២០១៣ នេះ ប្រទេសកម្ពុជាបានទទួលរងនូវគ្រោះមហន្តរាយធម្មជាតិយ៉ាងអាក្រក់បំផុតដែលបណ្តាលមកពីជំនន់ទឹកភ្លៀងផង និងជំនន់ទឹកទន្លេមេគង្គផង ។ យោងរបាយការណ៍របស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយបានឱ្យដឹងថា គ្រោះទឹកជំនន់ឆ្នាំនេះមានទំហំប្រហាក់ប្រហែលនឹងគ្រោះទឹកជំនន់ឆ្នាំ ២០១១ ដែរ ដែលបានប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់រាជធានី ខេត្តចំនួន ២០ ប៉ះពាល់ប្រជាជន ៣៧៧ ៣៥៤ គ្រួសារ មានមនុស្សស្លាប់ ១៦៨ នាក់ ស្រូវ សន្ទូង ពង្រោះ ផលដំណាំនានា ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ផ្ទះសម្បែងទ្រព្យសម្បត្តិប្រជាជនត្រូវទទួលរងការខូចខាតយ៉ាងច្រើនក្រៃលែង ។ រាជរដ្ឋាភិបាលបានប៉ាន់ប្រមាណថា តម្លៃនៃការខូចខាតដោយទឹកជំនន់នេះមានរហូតដល់ជាង ១០០០ លានដុល្លារអាមេរិក ។ នេះជាទុក្ខលំបាកយ៉ាងធំធេងរបស់ប្រជាជនយើង ដែលទាមទារឱ្យមានការជួយសង្គ្រោះជាបន្ទាន់ ។

នៅក្នុងស្ថានភាពដ៏ធ្ងន់ធ្ងរនេះ រាជរដ្ឋាភិបាលកម្ពុជា គណៈកម្មាធិការជាតិកាកបាទក្រហមកម្ពុជា គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ព្រមទាំងសប្បុរសជននានាទាំងក្នុងនិងក្រៅប្រទេស បានធ្វើការឧបត្ថម្ភយ៉ាងទាន់ពេលវេលាជួយសម្រាលការលំបាករបស់ប្រជាជនយើង ។ ជាមួយគ្នានេះ គណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជាបានចេញសេចក្តីថ្លែងការណ៍ថ្លែងអំណរគុណដល់សប្បុរសជនក្នុង និងក្រៅប្រទេស ក៏ដូចសមាជិក សមាជិកាគណបក្សប្រជាជនកម្ពុជា ដែលបានប្រឹងប្រែងជួយដល់ប្រជាជននៅគ្រាជួបគ្រោះទឹកជំនន់នេះ និងបានអំពាវនាវសូមបន្តសកម្មភាពផ្តល់ជំនួយសង្គ្រោះបន្ទាន់នេះបន្ថែមទៀត ។ មន្ត្រី ក្រុមការងាររបស់គណបក្សប្រជាជនកម្ពុជាគ្រប់លំដាប់ថ្នាក់ បាននាំអំណោយជាស្បៀងអាហារ ថ្នាំសង្កូវ ជម្រក ប្រេងឥន្ធនៈ ។ល។ យកទៅឧបត្ថម្ភដល់ប្រជាជនរងគ្រោះនៅគ្រប់តំបន់រងគ្រោះ ដោយមិនគិតអំពីនិន្នាការនយោបាយណាឡើយ ។ រាល់ជំនួយសង្គ្រោះបន្ទាន់ត្រូវបានបញ្ជូនទៅដល់ប្រជាជនរងគ្រោះដោយផ្ទាល់ ហើយឆ្លងតាមរយៈចលនានេះ បានបង្ហាញឱ្យឃើញអំពីការរួបរួមកម្លាំងជាតិពីគ្រប់មជ្ឈដ្ឋានទាំងអស់ ដើម្បីជម្នះនូវផលវិបាកដែលបណ្តាលមកពីគ្រោះទឹកជំនន់ ។ ថ្វីបើអំណោយទាំងអស់នោះពុំអាចឆ្លើយតបនឹងតម្រូវការដ៏ធំធេងរបស់ប្រជាជនរងគ្រោះបាន ប៉ុន្តែវាបានបង្ហាញអំពីទឹកចិត្តសប្បុរសធម៌ ស្មារតីចែករំលែកក្នុងគ្រាលំបាក ដែលជាប្រពៃណីដ៏ថ្លៃថ្លារបស់ប្រជាជាតិយើង ព្រមទាំងសមានចិត្តដ៏ល្អប្រពៃរបស់សហគមន៍អន្តរជាតិចំពោះប្រជាជនកម្ពុជា ។

ជាមួយនឹងការជួយសង្គ្រោះ និងការឧបត្ថម្ភស្បៀងអាហារ ចំពោះមុខនេះ ភារកិច្ចបន្ទាន់សំខាន់របស់អាជ្ញាធរដែនដី ក្រសួង ស្ថាប័នពាក់ព័ន្ធនានា ព្រមទាំងគណៈកម្មាធិការនៃគណបក្សប្រជាជនកម្ពុជានៅគ្រប់ថ្នាក់ គ្រប់ផ្នែក គឺការយកចិត្តទុកដាក់ជំរុញអនុវត្តការងារនានាដើម្បីជំនះនូវផលវិបាកក្រោយពេលទឹកជំនន់ស្រកអស់ ។ ទន្ទឹមនឹងការប្រឹងប្រែងស្តារឡើងវិញនូវផលិតកម្ម និងជីវភាពរស់នៅរបស់ប្រជាជន រាជរដ្ឋាភិបាលក៏នឹងត្រូវចំណាយថវិកាយ៉ាងច្រើនថែមទៀតដើម្បីស្តារហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តដែលខូច ខាត ដូចជា ផ្លូវថ្នល់ ស្ពាន អាងទឹក ទំនប់ប្រឡាយ សាលារៀន មន្ទីរពេទ្យ ។ល។ ដែលប្រការនេះនឹងធ្វើឱ្យប៉ះពាល់មួយផ្នែកដល់កំណើនសេដ្ឋកិច្ចយើងក្នុងឆ្នាំ ២០១៣ នេះ ។ ប៉ុន្តែទោះជាមានការ លំបាកយ៉ាងណាក្តី ក៏រាជរដ្ឋាភិបាលកម្ពុជា ដែលតែងតែយកចិត្តទុកដាក់ជានិច្ចចំពោះសុខទុក្ខរបស់ប្រជាជន គួបផ្សំនឹងការជួយឧបត្ថម្ភពីសប្បុរសជនជាតិ និងពីសហគន៍អន្តរជាតិ ជាពិសេសស្មារតីតស៊ូ អំណត់ព្យាយាម និងការចូលរួមរបស់កម្លាំងជាតិនោះ យើងពិតជាអាចជំនះបាននូវផលវិបាកទាំងនេះជាមិនខាន ដូចដែលយើងធ្លាប់បានឆ្លងកាត់រួចមកហើយនៅក្នុងគ្រោះទឹកជំនន់កាលពីឆ្នាំ ២០០០ និងឆ្នាំ ២០១១ ។

គួរកត់សម្គាល់ថា នៅពេលដែលប្រជាជនកំពុងរងគ្រោះធ្ងន់ធ្ងរដោយសារទឹកជំនន់នោះ ក្រុមអ្នកនយោបាយនៃគណបក្សប្រឆាំង និងមជ្ឈដ្ឋានអគតិមួយចំនួនទៀតមិនបានខ្វល់ខ្វាយពីការលំបាកទាំងនេះទេ ហើយបែរជាបន្តជំរុញសកម្មភាពដែលបង្កការលំបាកដល់សង្គមថែមទៀត ។ ពួកគេអួតអាងខ្លួនឯងថាសុទ្ធតែជាអ្នកស្រឡាញ់ជាតិ ស្រឡាញ់ប្រជាជន អាណិតអាសូរប្រជាជន ប៉ុន្តែគេមិនឃើញពួកអ្នកទាំងនោះចុះទៅជួយប្រជាជនឡើយ ។ ផ្ទុយទៅវិញ ពួកគេកំពុងតែបន្តជំរុញយុទ្ធនាការបំផ្លាញផលប្រយោជន៍ប្រជាជន ដោយមានក្រុមទៅធ្វើយុទ្ធនាការមួលបង្កាច់ជាតិឯងពីខាងក្រៅ ឯពួកនៅខាងក្នុងកំពុងតែប៉ុនប៉ងធ្វើគ្រប់សកម្មភាពទាំងអស់ ដើម្បីពន្យឺតការរីកចម្រើនរបស់ប្រទេសជាតិ បង្កអស្ថិរភាព សង្គម និងនយោបាយ ។ ពួកគេឃោសនាបោកប្រាសប្រជាជនឱ្យចូលរួមក្នុងអ្វីដែលហៅថា "មហាបាតុកម្មរកយុត្តិធម៌ស្អីគេនោះ" នៅពេលដែលប្រជាជនឯជនបទកំពុងលិចលង់ក្នុងគ្រោះទឹកជំនន់ ។ តើទង្វើបែបនេះឬដែលពួកគេតែងអួតអាងថាជាអ្នកជួយសង្គ្រោះជាតិនោះ ? មនុស្សមានសតិសម្បជញ្ញៈគ្រប់រូបពិតជាបានឃើញនិងយល់យ៉ាងច្បាស់ថា ពួកគេគឺជាអ្នកបំផ្លាញជាតិទៅវិញទេ ។

នៅក្នុងបរិការណ៍នេះ រាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំរបស់សម្តេចតេជោ **ហ៊ុន សែន** និងគណបក្សប្រជាជនកម្ពុជា ដែលប្រជាជនបានបោះឆ្នោតគាំទ្រឱ្យបន្តដឹកនាំប្រទេសសម្រាប់ រយៈពេល ៥ ឆ្នាំតទៅមុខទៀត និងខិតខំប្រឹងប្រែងពេញទំហឹង ដើម្បីដោះស្រាយការលំបាកសព្វយ៉ាងរបស់ប្រជាជននៅគ្រប់តំបន់ ដែលត្រូវរងគ្រោះដោយទឹកជំនន់ សំដៅស្តារឡើងវិញឱ្យបានឆាប់រហ័សនូវហេដ្ឋារចនាសម្ព័ន្ធ ផលិតកម្ម និងជីវភាពរស់នៅរបស់ប្រជាជន ។ ក្នុងទិសដៅនេះ មន្ត្រីគ្រប់ថ្នាក់ គ្រប់ផ្នែកនៃគណបក្សប្រជាជនកម្ពុជា គប្បីពង្រីកនូវប្រពៃណីផ្សារភ្ជាប់ជាមួយប្រជាជន ចែករំលែកទុក្ខលំបាកជាមួយប្រជាជន និងខិតខំជួយប្រជាជនតាមគ្រប់លទ្ធភាព ដោយពុំមានការប្រកាន់និន្នាការនយោបាយណាឡើយ ព្រោះថា គណបក្សប្រជាជនកម្ពុជានៅតែជាបង្អែកដ៏រឹងមាំ និងជាទឹកក់ក្តៅរបស់ប្រជាជនកម្ពុជា ។/

ទស្សនាវដ្តីប្រជាជន

**គណបក្សប្រជាជនកម្ពុជា**
គណៈកម្មាធិការកណ្ដាល

ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ
អព្យាក្រឹត និង វឌ្ឍនភាពសង្គម

# សេចក្ដីថ្លែងការណ៍របស់គណបក្សប្រជាជនកម្ពុជា
# អំពី
# កំណែទម្រង់ការបោះឆ្នោតនាពេលខាងមុខ

ផ្អែកលើរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាននានានៃព្រះរាជាណាចក្រកម្ពុជា និងយោងតាមស្ថានការណ៍ជាក់ស្ដែងក្រោយការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី ៥ កាលពីថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០១៣ កន្លងទៅ និងយោងតាមជំនួបរវាងថ្នាក់ដឹកនាំគណបក្សប្រជាជនកម្ពុជា និងថ្នាក់ដឹកនាំគណបក្សសង្គ្រោះជាតិ កាលពីថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ ២០១៣ គណបក្សប្រជាជនកម្ពុជាសូមប្រកាសជាឧឡារិកចំពោះសាធារណមតិជាតិ និងអន្តរជាតិ នូវជំហរ និងការប្ដេជ្ញាចិត្តរបស់ខ្លួនក្នុងការកែទម្រង់ការបោះឆ្នោតនាពេលខាងមុខ ស្របតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋ ដូចខាងក្រោមៈ

១-ស្នើធ្វើវិសោធនកម្មច្បាប់ និងនីតិវិធីទាំងឡាយ ដែលពាក់ព័ន្ធនឹងការបោះឆ្នោត ជាអាទិ៍ ច្បាប់ស្ដីពីការបោះឆ្នោត ច្បាប់ស្ដីពីគណបក្សនយោបាយ បទបញ្ជា និងនីតិវិធីនៃការបោះឆ្នោត ដើម្បីធានាដល់ការកែលម្អឱ្យកាន់តែសុក្រឹតថែមទៀតនូវដំណើរការនៃការបោះឆ្នោត ។
២-ស្នើឱ្យមានក្របខ័ណ្ឌគតិយុត្តិមួយចំនួនថែមទៀត ដើម្បីបន្តលើកកម្ពស់សុចរិតភាព និងតម្លាភាពនៃដំណើរការបោះឆ្នោត ជាអាទិ៍ ការស្នើសេចក្ដីព្រាងច្បាប់ស្ដីពីថវិកាគណបក្សនយោបាយ ច្បាប់នានា និងលិខិតបទដ្ឋានមួយចំនួនទៀតពាក់ព័ន្ធនឹងការបោះឆ្នោត ។ល។
៣-ក្នុងដំណើរការកំណែទម្រង់ខាងលើនេះ គណបក្សប្រជាជនកម្ពុជាប្រកាន់គោលការណ៍បើកចំហ និងទទួលយកមកសិក្សា នូវអនុសាសន៍នានាទាំងជាតិ និងអន្តរជាតិ ទាក់ទងនឹងការបោះឆ្នោត ។
៤-យន្តការសមស្របមួយអាចនឹងត្រូវបង្កើតឡើង ដើម្បីសិក្សាស្រាវជ្រាវបង្កើតឱ្យបានក្របខ័ណ្ឌកំណែទម្រង់ការបោះឆ្នោត ស្របតាមគោលការណ៍ប្រជាធិបតេយ្យសេរី ត្រឹមត្រូវ និងយុត្តិធម៌ ។
៥-ក្របខ័ណ្ឌកំណែទម្រង់ដ៏មានសារៈសំខាន់នេះត្រូវធ្វើតាមរយៈអង្គការនីតិប្រតិបត្តិ និងនីតិបញ្ញត្តិ ។

គណបក្សប្រជាជនកម្ពុជាអំពាវនាវចំពោះសហគមន៍ជាតិ និងអន្តរជាតិ សូមមេត្តាបន្តគាំទ្រដំណើរការនៃលទ្ធិប្រជាធិបតេយ្យ សេរី ពហុបក្ស និងនីតិរដ្ឋ រួមចំណែកដល់បុព្វហេតុផ្សះផ្សារ បង្រួបបង្រួមជាតិ សន្តិភាព ស្ថិរភាព និងការអភិវឌ្ឍនៅកម្ពុជា ជាបន្តទៀត។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០១៣
**គណបក្សប្រជាជនកម្ពុជា**

# បញ្ជីរាយនាមសមាសភាពរាជរដ្ឋាភិបាលសម្រាប់នីតិកាលទី ៥ នៃរដ្ឋសភា



*សម្តេចអគ្គមហាសេនាបតីតេជោ* **ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី**

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**

**ឧបនាយករដ្ឋមន្ត្រី**

១- ឯកឧត្តម **ស ខេង**
២- ឯកឧត្តម **សុខ អាន**
៣- ឯកឧត្តម **ឡៅ ធាញ់**
៤- ឯកឧត្តម **គាត ឈន់** ប្រចាំការ
៥- ឯកឧត្តម **ហោ ណាំហុង**
៦- លោកជំទាវ **ម៉ែន សំអន**
៧- ឯកឧត្តម **ប៊ិន ឈិន**
៨- ឯកឧត្តម **យឹម ឆៃលី**
៩- ឯកឧត្តម **កែ គឹមយ៉ាន** ទេសរដ្ឋមន្ត្រី

**ទេសរដ្ឋមន្ត្រី**

១- ឯកឧត្តម **អ៊ឹម ឈុនលឹម**
២- ឯកឧត្តម **ឆាយ ថន**
៣- ឯកឧត្តម **ចម ប្រសិទ្ធ**
៤- ឯកឧត្តម **ញឹម វណ្ណដា** (ទទួលបន្ទុកបេសកកម្មពិសេស)
៥- ឯកឧត្តម **ឃុន ហាំង** (ទទួលបន្ទុកបេសកកម្មពិសេស)
៦- ឯកឧត្តម **លី ធុច** (ទទួលបន្ទុកបេសកកម្មពិសេស)
៧- ឯកឧត្តម **ចំរួន សារុន** (ទទួលបន្ទុកបេសកកម្មពិសេស)
៨- ឯកឧត្តម **ស៊ុន ចាន់ថុល**
៩- ឯកឧត្តម **ឱម យ៉ិនទៀង** (ទទួលបន្ទុកបេសកកម្មពិសេស)
១០- ឯកឧត្តម **អៀង ម៉ូលី** (ទទួលបន្ទុកបេសកកម្មពិសេស)
១១-ឯកឧត្តម **វ៉ា គឹមហុង** (ទទួលបន្ទុកបេសកកម្មពិសេស)
១២-ឯកឧត្តម **យឹម ឈុលឡា** (ទទួលបន្ទុកបេសកកម្មពិសេស)
១៣-ឯកឧត្តម **សេរី កុសល** (ទទួលបន្ទុកបេសកកម្មពិសេស)
១៤- ឯកឧត្តម **ហ៊ឹម ឆែម** (ទទួលបន្ទុកបេសកកម្មពិសេស)
១៥- ឯកឧត្តម **ជិន ប៊ុនសៀន** (ទទួលបន្ទុកបេសកកម្មពិសេស)

**ក្រសួង-រដ្ឋលេខាធិការដ្ឋាន**

**១- ទីស្តីការគណៈរដ្ឋមន្ត្រី**

១- ឯកឧត្តម **សុខ អាន** រដ្ឋមន្ត្រី
២- ឯកឧត្តម **ប៊ុន អ៊ុយ** រដ្ឋលេខាធិការ
៣- ឯកឧត្តម **ស៊ូ ភិរិន្ទ** រដ្ឋលេខាធិការ
៤- លោកជំទាវ **ឆាយ ថាន់នឿន** រដ្ឋលេខាធិការ
៥- ឯកឧត្តម **ចំរួន តារី** រដ្ឋលេខាធិការ
៦- ឯកឧត្តម **ស្វាយ ស៊ីថា** រដ្ឋលេខាធិការ
៧- ឯកឧត្តម **សុក ផេង** រដ្ឋលេខាធិការ
៨- ឯកឧត្តម **ឃឹម បូរ** រដ្ឋលេខាធិការ
៩- ឯកឧត្តម **ជ្រា សុចិន្តា** រដ្ឋលេខាធិការ
១០- ឯកឧត្តម **ផៃ ស៊ីផាន** រដ្ឋលេខាធិការ
១១-ឯកឧត្តម **អ៊ឹន វីរជាតិ** រដ្ឋលេខាធិការ
១២- ឯកឧត្តម **ហ៊ីង ថូរ៉ាក់ស៊ី** រដ្ឋលេខាធិការ
១៣- ឯកឧត្តម **គឹករ៉េត សំរេច** រដ្ឋលេខាធិការ
១៤- ឯកឧត្តម **កែវ រ៉េមី** រដ្ឋលេខាធិការ
១៥- ឯកឧត្តម **ប៊ុន សំបូរ** រដ្ឋលេខាធិការ
១៦- ឯកឧត្តម **ឃឹម រុស៊ីដា** រដ្ឋលេខាធិការ
១៧- ឯកឧត្តម **ទេៅ ហុងលី** រដ្ឋលេខាធិការ

**២- ក្រសួងមហាផ្ទៃ**

១- ឯកឧត្តម **ស ខេង** រដ្ឋមន្ត្រី
២- ឯកឧត្តម **ឯម សំអាន** រដ្ឋលេខាធិការ
៣- ឯកឧត្តម **ព្រុំ សុខា** រដ្ឋលេខាធិការ
៤- ឯកឧត្តម **នុត សាអាន** រដ្ឋលេខាធិការ
៥- ឯកឧត្តម **សក់ សេដ្ឋា** រដ្ឋលេខាធិការ
៦- ឯកឧត្តម **ទី ចំរុងផល** រដ្ឋលេខាធិការ

៧- លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការ
៨- ឯកឧត្ដម ប៉ុល លឹម រដ្ឋលេខាធិការ
៩- ឯកឧត្ដម តេង សាវង្ស រដ្ឋលេខាធិការ
១០- ឯកឧត្ដម ឌុល គៀន រដ្ឋលេខាធិការ
១១-ឯកឧត្ដម អ៊ុក គឹមលេខ រដ្ឋលេខាធិការ

## ៣. ក្រសួងការពារជាតិ

១- ឯកឧត្ដម ទៀ បាញ់ រដ្ឋមន្ត្រី
២- ឯកឧត្ដម ចាយ សាំងយុន រដ្ឋលេខាធិការ
៣- ឯកឧត្ដម ម៉ឹង សំផន រដ្ឋលេខាធិការ
៤- ឯកឧត្ដម នាង ផាត រដ្ឋលេខាធិការ
៥- ឯកឧត្ដម ឯល ទ៉ាន់សារ៉ាត រដ្ឋលេខាធិការ
៦- លោកជំទាវ ដាំ ដារីនី រដ្ឋលេខាធិការ

## ៤. ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

១- ឯកឧត្ដម ហោ ណាំហុង រដ្ឋមន្ត្រី
២- ឯកឧត្ដម ឡុង វិសាលោ រដ្ឋលេខាធិការ
៣- ឯកឧត្ដម អ៊ុច បូរិទ្ធ រដ្ឋលេខាធិការ
៤- ឯកឧត្ដម ពូ សុធីរៈ រដ្ឋលេខាធិការ
៥- ឯកឧត្ដម អ៊ុង ស៊ាន រដ្ឋលេខាធិការ
៦- លោកជំទាវ សឿង រដ្ឋចាវី រដ្ឋលេខាធិការ

## ៥. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

១- ឯកឧត្ដម អូន ព័ន្ធមុនីរ័ត្ន រដ្ឋមន្ត្រី
២- ឯកឧត្ដម វង្សី វិស្សុត រដ្ឋលេខាធិការ
៣- ឯកឧត្ដម ជូ វិជិត្ត រដ្ឋលេខាធិការ
៤- លោកជំទាវ ខួន សុខា រដ្ឋលេខាធិការ
៥- ឯកឧត្ដម ហ៊ាន សាហ៊ីប រដ្ឋលេខាធិការ
៦- ឯកឧត្ដម ទី តាឃី រដ្ឋលេខាធិការ
៧- ឯកឧត្ដម ជូ គឹមឡេង រដ្ឋលេខាធិការ

## ៦. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

១- ឯកឧត្ដម អ៊ុក រ៉ាប៊ុន រដ្ឋមន្ត្រី
២- ឯកឧត្ដម យុទ្ធ ភូថង រដ្ឋលេខាធិការ
៣- ឯកឧត្ដម ឱម គឹមស៊ា រដ្ឋលេខាធិការ
៤- ឯកឧត្ដម ទី សុគន្ធ រដ្ឋលេខាធិការ
៥- ឯកឧត្ដម ម៉ម អំណត់ រដ្ឋលេខាធិការ
៦- លោកជំទាវ ហោ ម៉ាលីន រដ្ឋលេខាធិការ

## ៧. ក្រសួងអភិវឌ្ឍន៍ជនបទ

១- ឯកឧត្ដម ជា សុផារ៉ា រដ្ឋមន្ត្រី
២- ឯកឧត្ដម សួស គង់ រដ្ឋលេខាធិការ
៣- ឯកឧត្ដម អ៊ិន ចន្ថា រដ្ឋលេខាធិការ
៤- ឯកឧត្ដម សៅ ជីវ័ន្ត រដ្ឋលេខាធិការ
៥- ឯកឧត្ដម ទ្រី មេង រដ្ឋលេខាធិការ
៦- លោកជំទាវ ម៉ាត់ ម៉ារ៉ា រដ្ឋលេខាធិការ

## ៨. ក្រសួងពាណិជ្ជកម្ម

១- ឯកឧត្ដម ស៊ុន ចាន់ថុល រដ្ឋមន្ត្រី
២- ឯកឧត្ដម គឹម ស៊ីថន រដ្ឋលេខាធិការ
៣- ឯកឧត្ដម ប៉ាន សូរស័ក្តិ រដ្ឋលេខាធិការ
៤- ឯកឧត្ដម ឱក ប៊ុង រដ្ឋលេខាធិការ
៥- ឯកឧត្ដម ម៉ៅ ថូរ៉ា រដ្ឋលេខាធិការ
៦- ឯកឧត្ដម ឈួន ដារ៉ា រដ្ឋលេខាធិការ
៧- ឯកឧត្ដម ឌិត ទីណា រដ្ឋលេខាធិការ
៨- លោកជំទាវ តឹករ៉េត កំរេង រដ្ឋលេខាធិការ

## ៩. ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

១- ឯកឧត្ដម ចម ប្រសិទ្ធ រដ្ឋមន្ត្រី
២- ឯកឧត្ដម អ៊ិត ប្រាំង រដ្ឋលេខាធិការ
៣- ឯកឧត្ដម សាត សាមី រដ្ឋលេខាធិការ
៤- ឯកឧត្ដម ភោគ សុវណ្ណរិទ្ធ រដ្ឋលេខាធិការ
៥- ឯកឧត្ដម ឯក សុនចាន់ រដ្ឋលេខាធិការ
៦- ឯកឧត្ដម ហេង សុខគង់ រដ្ឋលេខាធិការ
៧- លោកជំទាវ ឡាយ ណាវីន រដ្ឋលេខាធិការ
៨- ឯកឧត្ដម គឹម ទូច រដ្ឋលេខាធិការ

## ១០. ក្រសួងផែនការ

១- ឯកឧត្ដម ឆាយ ថន រដ្ឋមន្ត្រី
២- ឯកឧត្ដម ហ៊ូ តាំងអេង រដ្ឋលេខាធិការ
៣- ឯកឧត្ដម រិន វីរៈ រដ្ឋលេខាធិការ
៤- ឯកឧត្ដម សន ស៊ីថន រដ្ឋលេខាធិការ
៥- ឯកឧត្ដម ទួន ថាវរៈ រដ្ឋលេខាធិការ
៦- លោកជំទាវ ប៉ែន សុបភា រដ្ឋលេខាធិការ
៧- ឯកឧត្ដម ប៉ាន ប៊ុនធឿន រដ្ឋលេខាធិការ

## ១១. ក្រសួងអប់រំ យុវជន និងកីឡា

១- ឯកឧត្ដម ហង់ ជួនណារ៉ុន រដ្ឋមន្ត្រី
២- ឯកឧត្ដម ពិត ចំណាន រដ្ឋលេខាធិការ
៣- ឯកឧត្ដម ណាត ប៊ុនរឿន រដ្ឋលេខាធិការ
៤- លោកជំទាវ គឹម សេដ្ឋានី រដ្ឋលេខាធិការ
៥- ឯកឧត្ដម ស៊ាន បូរ៉ាត រដ្ឋលេខាធិការ
៦- ឯកឧត្ដម អ៊ឹម ភុច រដ្ឋលេខាធិការ
៧- ឯកឧត្ដម យក់ ឌុំយ រដ្ឋលេខាធិការ

### ១២_ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

១- ឯកឧត្តម **វង សូត** រដ្ឋមន្ត្រី
២- ឯកឧត្តម **នឹម ថូត** រដ្ឋលេខាធិការ
៣- ឯកឧត្តម **យី យ៉ុន** រដ្ឋលេខាធិការ
៤- ឯកឧត្តម **សយ ស៊ីផុន** រដ្ឋលេខាធិការ
៥- ឯកឧត្តម **មុត ខៀវ** រដ្ឋលេខាធិការ
៦- ឯកឧត្តម **សែម សុខា** រដ្ឋលេខាធិការ
៧- ឯកឧត្តម **អះម៉ាត់ យ៉ះយ៉ា** រដ្ឋលេខាធិការ
៨- ឯកឧត្តម **ឃួន រ៉ានីន** រដ្ឋលេខាធិការ
៩- លោកជំទាវ **ខៀវ បូរី** រដ្ឋលេខាធិការ

### ១៣_ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

១- ឯកឧត្តម **អ៊ឹម ឈុនលឹម** រដ្ឋមន្ត្រី
២- ឯកឧត្តម **ឆាន់ សាផាន** រដ្ឋលេខាធិការ
៣- ឯកឧត្តម **លឹម វាន់** រដ្ឋលេខាធិការ
៤- លោកជំទាវ **អ៊ូ វ៉ាំឌី** រដ្ឋលេខាធិការ
៥- ឯកឧត្តម **តឿង សុគំណ្ឌ** រដ្ឋលេខាធិការ
៦- ឯកឧត្តម **សរ សុវណ្ណា** រដ្ឋលេខាធិការ
៧- ឯកឧត្តម **ប៉ែន សុផល** រដ្ឋលេខាធិការ

### ១៤_ក្រសួងបរិស្ថាន

១- ឯកឧត្តម **សាយ សំអាល់** រដ្ឋមន្ត្រី
២- ឯកឧត្តម **ខៀវ មុត** រដ្ឋលេខាធិការ
៣- ឯកឧត្តម **យិន គិមស៊ាន** រដ្ឋលេខាធិការ
៤- ឯកឧត្តម **សាបូ អូហ្សារណូ** រដ្ឋលេខាធិការ
៥- លោកជំទាវ **ឃុន លក្ខិ្ម** រដ្ឋលេខាធិការ

### ១៥_ក្រសួងធនធានទឹក និងឧតុនិយម

១- ឯកឧត្តម **លឹម គានហោ** រដ្ឋមន្ត្រី
២- ឯកឧត្តម **វេង សាខុន** រដ្ឋលេខាធិការ
៣- ឯកឧត្តម **តន់ វ៉ាន់ថារ៉ា** រដ្ឋលេខាធិការ
៤- ឯកឧត្តម **ប៊ុន ហ៊ាន** រដ្ឋលេខាធិការ
៥- លោកជំទាវ **សេង វណ្ណសាយ** រដ្ឋលេខាធិការ
៦- ឯកឧត្តម **ថៅ ជេដ្ឋា** រដ្ឋលេខាធិការ

### ១៦_ក្រសួងព័ត៌មាន

១- ឯកឧត្តម **ខៀវ កាញារីទ្ធ** រដ្ឋមន្ត្រី
២- ឯកឧត្តម **អ៊ុក ប្រាថ្នា** រដ្ឋលេខាធិការ
៣- ឯកឧត្តម **ម៉ៅ អាយុទ្ធ** រដ្ឋលេខាធិការ
៤- ឯកឧត្តម **ថាច់ ផែន** រដ្ឋលេខាធិការ
៥- ឯកឧត្តម **នូវ សុវត្ថិរ៉ូ** រដ្ឋលេខាធិការ
៦- ឯកឧត្តម **ហោ សុភាព** រដ្ឋលេខាធិការ
៧- ឯកឧត្តម **ជា ចាន់បរិបូណ៌** រដ្ឋលេខាធិការ
៨- លោកជំទាវ **ចំនួ ធី** រដ្ឋលេខាធិការ

### ១៧_ក្រសួងយុត្តិធម៌

១- ឯកឧត្តម **អង្គ វង្សវឌ្ឍានា** រដ្ឋមន្ត្រី
២- ឯកឧត្តម **ហ៊ី សោភា** រដ្ឋលេខាធិការ
៣- លោកជំទាវ **ចាន់ សុទ្ធាវី** រដ្ឋលេខាធិការ
៤- ឯកឧត្តម **ចៅ សុវណ្ណ** រដ្ឋលេខាធិការ
៥- ឯកឧត្តម **ព្រហ្ម សិទ្ធត្រា** រដ្ឋលេខាធិការ
៦- ឯកឧត្តម **កើត រិទ្ធ** រដ្ឋលេខាធិការ

### ១៨_ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច

១- លោកជំទាវ **ម៉ែន សំអន** រដ្ឋមន្ត្រី
២- ឯកឧត្តម **ឆេង សារឿន** រដ្ឋលេខាធិការ
៣- ឯកឧត្តម **កង ណែម** រដ្ឋលេខាធិការ
៤- ឯកឧត្តម **ថាច់ ឃន** រដ្ឋលេខាធិការ
៥- ឯកឧត្តម **ឌុច សុវណ្ណារី** រដ្ឋលេខាធិការ
៦- លោកជំទាវ **សុភ័ក្ត ថាវី** រដ្ឋលេខាធិការ
៧- លោកជំទាវ **សុខ វិឡាយ** រដ្ឋលេខាធិការ

### ១៩_ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

១- ឯកឧត្តម **ប្រាក់ សុខុន** រដ្ឋមន្ត្រី
២- ឯកឧត្តម **សារ៉ាក់ ខាន់** រដ្ឋលេខាធិការ
៣- ឯកឧត្តម **ខាយ ឃុនហេង** រដ្ឋលេខាធិការ
៤- ឯកឧត្តម **ឯក វណ្ណឌី** រដ្ឋលេខាធិការ
៥- លោកជំទាវ **រស់ សូរក្សា** រដ្ឋលេខាធិការ
៦- ឯកឧត្តម **ភាន ចំនួមេត្តា** រដ្ឋលេខាធិការ
៧- លោកជំទាវ **ប្រាក់ ចំនួណយ** រដ្ឋលេខាធិការ

### ២០_ ក្រសួងសុខាភិបាល

១- ឯកឧត្តម **ម៉ម ប៊ុនហេង** រដ្ឋមន្ត្រី
២- ឯកឧត្តម **ហេង តៃគ្រី** រដ្ឋលេខាធិការ
៣- ឯកឧត្តម **អ៊ឹង ភិរុន** រដ្ឋលេខាធិការ
៤- ឯកឧត្តម **អេង ហួត** រដ្ឋលេខាធិការ
៥- ឯកឧត្តម **សុខ ផេង** រដ្ឋលេខាធិការ
៦- លោកជំទាវ **តាន់ វួចឆេង** រដ្ឋលេខាធិការ
៧- ឯកឧត្តម **តែ គុយស៊ាង** រដ្ឋលេខាធិការ
៨- ឯកឧត្តម **ជូ យិនស៊ីម** រដ្ឋលេខាធិការ
៩- ឯកឧត្តម **ធា គ្រួយ** រដ្ឋលេខាធិការ

### ២១_ក្រសួងសាធារណការ និងដឹកជញ្ជូន

១- ឯកឧត្តម ត្រាំ អ៊ីវតឹក រដ្ឋមន្ត្រី
២- ឯកឧត្តម តូច ចាន់កុសល រដ្ឋលេខាធិការ
៣- ឯកឧត្តម សួង ហេង រដ្ឋលេខាធិការ
៤- ឯកឧត្តម សួន រចនា រដ្ឋលេខាធិការ
៥- ឯកឧត្តម លឹម ស៊ីដេនីន រដ្ឋលេខាធិការ
៦- ឯកឧត្តម នូ សុវត្ថិ រដ្ឋលេខាធិការ
៧- ឯកឧត្តម សុខុម ភគវន្តមុនី រដ្ឋលេខាធិការ
៨- លោកជំទាវ មឺន មាណវី រដ្ឋលេខាធិការ

### ២២_ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

១- លោកជំទាវ ភឿង សកុណា រដ្ឋមន្ត្រី
២- ឯកឧត្តម ឃឹម សារិទ្ធ រដ្ឋលេខាធិការ
៣- ឯកឧត្តម ជុច ភឿន រដ្ឋលេខាធិការ
៤- លោកជំទាវ ម៉ិញ កុសនី រដ្ឋលេខាធិការ
៥- ឯកឧត្តម អ៊ុក សុជាតិ រដ្ឋលេខាធិការ
៦- ឯកឧត្តម សោម សុគន្ធ រដ្ឋលេខាធិការ
៧- ឯកឧត្តម ថៃ នរៈសត្យា រដ្ឋលេខាធិការ
៨- ឯកឧត្តម សំរាំង កំសាន្ត រដ្ឋលេខាធិការ

### ២៣_ក្រសួងទេសចរណ៍

១- ឯកឧត្តម ថោង ខុន រដ្ឋមន្ត្រី
២- ឯកឧត្តម សូ ម៉ារ៉ា រដ្ឋលេខាធិការ
៣- ឯកឧត្តម លី ប៊ុនធឿន រដ្ឋលេខាធិការ
៤- ឯកឧត្តម គោស៊ុំ សារឿត រដ្ឋលេខាធិការ
៥- លោកជំទាវ សម មុន្នីភា រដ្ឋលេខាធិការ
៦- ឯកឧត្តម ទិត ចន្ថា រដ្ឋលេខាធិការ
៧- ឯកឧត្តម ជា បូរ៉ា រដ្ឋលេខាធិការ

### ២៤_ក្រសួងធម្មការ និងសាសនា

១- ឯកឧត្តម មិន ឃិន រដ្ឋមន្ត្រី
២- ឯកឧត្តម ផ្លោក ផន រដ្ឋលេខាធិការ
៣- ឯកឧត្តម សុះ មុះសិន រដ្ឋលេខាធិការ
៤- ឯកឧត្តម នរៈ រតនវឌ្ឍនោ រដ្ឋលេខាធិការ
៥- លោកជំទាវ ទូច សារ៉ុម រដ្ឋលេខាធិការ

### ២៥_ ក្រសួងកិច្ចការនារី

១- លោកជំទាវ អ៊ឹង កន្ថាផាវី រដ្ឋមន្ត្រី
២- លោកជំទាវ ខេង សំវ៉ាដា រដ្ឋលេខាធិការ
៣- លោកជំទាវ ឃឹម ចំរើន រដ្ឋលេខាធិការ
៤- លោកជំទាវ ច័ន្ទ សូរីយ៉ រដ្ឋលេខាធិការ
៥- លោកជំទាវ អ៊ឹម ស៊ីថៃ រដ្ឋលេខាធិការ
៦- លោកជំទាវ ស៊ី ដេហ្វីន រដ្ឋលេខាធិការ
៧- លោកជំទាវ សាន្ត អរុណ រដ្ឋលេខាធិការ
៨- លោកជំទាវ កុប ម៉ារីយ៉ាស រដ្ឋលេខាធិការ
៩- លោកជំទាវ ហ៊ូ សាមិត្ត រដ្ឋលេខាធិការ

### ២៦_ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

១- ឯកឧត្តម អ៊ិត សំហេង រដ្ឋមន្ត្រី
២- ឯកឧត្តម ពេជ សោភ័ន រដ្ឋលេខាធិការ
៣- ឯកឧត្តម អូស្មាន ហាស្សាន់ រដ្ឋលេខាធិការ
៤- ឯកឧត្តម ភាន់ ម៉ន រដ្ឋលេខាធិការ
៥- លោកជំទាវ ស៊ើង សរសុចិត្តា រដ្ឋលេខាធិការ
៦- ឯកឧត្តម អ៊ុំ មាន រដ្ឋលេខាធិការ
៧- ឯកឧត្តម ហ៊ុយ ហានសុង រដ្ឋលេខាធិការ
៨- ឯកឧត្តម ម៉ម វណ្ណៈ រដ្ឋលេខាធិការ

### ២៧_ក្រសួងមុខងារសាធារណៈ

១- ឯកឧត្តម ពេជ្រ ប៊ុនធិន រដ្ឋមន្ត្រី
២- ឯកឧត្តម យូ ស៊ុនឡុង រដ្ឋលេខាធិការ
៣- ឯកឧត្តម អៀម សារុំ រដ្ឋលេខាធិការ
៤- ឯកឧត្តម រស់ សុផាន់ រដ្ឋលេខាធិការ
៥- លោកជំទាវ វ៉ាន់ ម៉ារា រដ្ឋលេខាធិការ
៦- ឯកឧត្តម ប៉ុល ពីឌុ រដ្ឋលេខាធិការ
៧- ឯកឧត្តម យក់ ប៊ុនណា រដ្ឋលេខាធិការ

### ២៨_រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី

១- ឯកឧត្តម ហូ សិទ្ធី
២- ឯកឧត្តម សុខ ចិន្តាសោភា
៣- ឯកឧត្តម ម៉ម សារិន
៤- ឯកឧត្តម ស៊្រី ថាមរុន្ត
៥- ឯកឧត្តម ទៅ សុវណ្ណ
៦- ឯកឧត្តម ឈៀង យ៉ាណារ៉ា
៧- ឯកឧត្តម ឌុល គឿន
៨- ឯកឧត្តម យូ ស៊ុនឡុង
៩- ឯកឧត្តម អូស្មាន ហាស្សាន់
១០- ឯកឧត្តម សោម សឿន
១១- ឯកឧត្តម សុន គន្ធរ
១២- ឯកឧត្តម ហ្សាការីយ៉ា អាដាម
១៣- ឯកឧត្តម កៅ គឹមហួន

### រដ្ឋលេខាធិការដ្ឋានចំណុះទីស្តីការគណៈរដ្ឋមន្ត្រី

### រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល

ឯកឧត្តម ម៉ៅ ហាវណ្ណាល់ រដ្ឋលេខាធិការ

# ព្រះរាជពិធីគោរពព្រះវិញ្ញាណក្ខន្ធព្រះករុណា ព្រះបរមរតនកោដ្ឋ គម្រប់ខួប ១ ឆ្នាំ បានប្រព្រឹត្តទៅនៅទូទាំងប្រទេស





***ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ***
*ក្នុងព្រះរាជពិធីសម្ពោធវិមាន **ព្រះបរមរូប ព្រះបរមរតនកោដ្ឋ***

នៅថ្ងៃទី ១៥ ខែតុលា ឆ្នាំ ២០១៣ រាជរដ្ឋាភិបាល និងប្រជាជនកម្ពុជានៅទូទាំងប្រទេសបានប្រារព្ធព្រះរាជពិធីបុណ្យគោរពព្រះវិញ្ញាណក្ខន្ធ **ព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះបរមរតនកោដ្ឋ** ជាទីសក្ការៈ គម្រប់ ១ ឆ្នាំ ដើម្បីរំឭកនូវព្រះមហាគុណូបការៈដ៏វិសេសវិសាល ឧត្តុង្គឧត្តមបំផុតរបស់ព្រះអង្គចំពោះបុព្វហេតុជាតិ និងប្រជារាស្ត្រខ្មែរ។

នៅរាជធានីភ្នំពេញ ថ្នាក់ដឹកនាំជាន់ខ្ពស់នៃស្ថាប័ននីតិប្បញ្ញត្តិ នីតិប្រតិបត្តិបានដឹកនាំគណៈប្រតិភូអញ្ជើញទៅកាន់វិមាន**ព្រះបរមរូប ព្រះបរមរតនកោដ្ឋ** ដែលស្ថិតនៅខាងកើតវិមានឯករាជ្យ រំឭកនូវការចងចាំចំពោះមហាគុណូបការៈរបស់ព្រះអង្គដែលពុំអាចកាត់ថ្លៃបាន និងឧទ្ទិសបួងសួងសូមដួងព្រះវិញ្ញាណក្ខន្ធរបស់ព្រះករុណាជាអម្ចាស់បានយាងទៅកាន់សុគតិភពជារៀងរហូត និងសូមជួយថែរក្សាប្រជាជាតិខ្មែរឱ្យបានជួបប្រទះតែនឹងសេចក្តីសុខសេចក្តីចម្រើនតរៀងទៅ។ សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ឯកឧត្តម **សាយ ឈុំ** អនុប្រធានទី ១ ព្រឹទ្ធ-សភាតំណាងដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា បានដឹកនាំគណៈប្រតិភូតំណាងស្ថាប័ននីតិប្បញ្ញតិ និងនីតិប្រតិបត្តិចូលរួមក្នុងព្រះរាជពិធីគោរពព្រះវិញ្ញាណក្ខន្ធនេះនៅវិមានព្រះបរមរូប ។

ព្រះរាជពិធីតាមប្រពៃណីព្រះពុទ្ធសាសនា ក៏បានប្រព្រឹត្តនៅក្នុងព្រះបរមរាជវាំងក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតនៃ **ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និង **សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ** ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល។

**ព្រះករុណា ព្រះបាទ សម្តេចព្រះនរោត្តម សីហនុ** ព្រះអង្គបានយាងសោយព្រះទិវង្គតក្នុងព្រះជន្មាយុ ៩០ ព្រះវស្សា នៅទីក្រុងប៉េកាំង សាធារណរដ្ឋប្រជាមានិតចិន កាលពីថ្ងៃទី ១៥ ខែតុលា ឆ្នាំ ២០១២។ ក្នុងមួយព្រះជន្មរបស់ **ព្រះករុណា ព្រះវររាជបិតាជាតិ** ព្រះអង្គបានលះបង់អស់ព្រះកាយពល និងព្រះបញ្ញាញាណដើម្បីបុព្វហេតុឯករាជ្យជាតិ បូរណភាពទឹកដី ការបង្រួបបង្រួមជាតិសាសនា សេរីភាព សមភាព យុត្តិធម៌ មនុស្សធម៌ ការអភិវឌ្ឍសេដ្ឋ-កិច្ចសង្គម និងការលើកស្ទួយជីវភាពប្រជាជន។ ព្រះអង្គបានដឹកនាំ

ព្រះរាជបូជនីយកិច្ចដ៏រុងរឿងឧត្តុង្គឧត្តមរបស់ព្រះករុណាព្រះបរមរតនកោដ្ឋបានពេញបរិបូរជូនប្រទេសជាតិ និងបានធ្វើឱ្យកម្ពុជាបានសុខសន្តិភាព ឯកភាពជាតិ និងវឌ្ឍនភាព ហើយមានកេរ្តិ៍ឈ្មោះល្បីល្បាញនៅលើសកលលោក។

នៅក្នុងសុន្ទរកថា ថ្លែងនៅចំពោះព្រះភ័ក្ត្រ **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** និង **សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ** ក្នុងពិធីសម្ពោធវិមាន **ព្រះបរមរូប សម្តេចព្រះនរោត្តម សីហនុ** នាព្រឹកថ្ងៃទី ១១ ខែតុលា ឆ្នាំ ២០១៣ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាបានអំពាវនាវ និងផ្តែផ្តាំផ្ញើទៅដល់អ្នកជំនាន់ក្រោយ ដែលត្រូវបន្តវេនដឹកនាំរាជរដ្ឋាភិបាល ត្រូវចាំទុកថា **ព្រះបិតាជាតិ** ជា **ព្រះបិតា** ជារៀងរហូត និងសូមរក្សាទុកថ្ងៃទី ១៥ តុលា ជារៀងរាល់ឆ្នាំ ដើម្បីបង្កើតឱកាសសម្រាប់ប្រជាពលរដ្ឋគោរព **ព្រះវិញ្ញាណក្ខន្ធព្រះបិតាជាតិ**។

សម្តេចតេជោនាយករដ្ឋមន្ត្រីបានអះអាងថា យើងទាំងអស់គ្នានៅពេលនេះ ក៏ដូចជាពេលអនាគត ក្រោមបាវចនាជាតិ សាសនា ព្រះមហាក្សត្រ ព្រះរាជាណាចក្រកម្ពុជានឹងបន្តស្ថិតស្ថេរជាអមតៈ ។ យើងត្រូវរួមគ្នា ដើម្បីការពាររាជានិយម ការពាររាជបល្ល័ង្ក ការពារព្រះមហាក្សត្រជាទីគោរពសក្ការៈ ក៏ដូចជាសម្តេចម៉ែដែលកំពុងគង់ប្រថាប់នៅទីនេះ។

រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** បានសម្រេច និងប្រកាសឱ្យសាងសង់វិមាន **ព្រះបរមរូប ព្រះបរមរតនកោដ្ឋ** ដើម្បីជានិមិត្តរូបនៃកតញ្ញូតាធម៌ និងចងចាំជានិច្ចរបស់ប្រជារាស្ត្រខ្មែរគ្រប់ៗជំនាន់តរៀងទៅនូវព្រះរាជជីវប្រវត្តិ និងស្នាព្រហស្តដែលមានតម្លៃយ៉ាងធំធេងជាប្រវត្តិសាស្ត្ររបស់ **ព្រះករុណា ព្រះមហាវីរក្សត្រ** ចំពោះជាតិ មាតុភូមិ និងប្រជារាស្ត្រជាកូន ជាចៅ របស់ព្រះអង្គ ។

ក្នុងពិធីសម្ពោធវិមាន **ព្រះបរមរូប ព្រះករុណា ព្រះបរមរតនកោដ្ឋ** នេះដែរ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **សុខ អាន** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានអនុគណៈកម្មការព័ត៌មានផ្សព្វផ្សាយ និងសាងសង់ **ព្រះបរមរូប** បានធ្វើរបាយការណ៍អំពីការសាងសង់វិមាននេះថា វិមាន **ព្រះបរមបដិមា ព្រះបរមរតនកោដ្ឋ** ត្រូវបានបញ្ចុះបឋមសិលាសាងសង់កាលពីថ្ងៃទី ២០ ខែកុម្ភៈ ឆ្នាំ ២០១៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។ ការសាងសង់វិមាន និង **ព្រះបរមបដិមា** ចាប់ផ្តើមអនុវត្តពីថ្ងៃទី ៧



*សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ថ្លែងសុន្ទរកថាក្នុងព្រះរាជពិធីសម្ពោធវិមាន **ព្រះបរមរូប ព្រះបរមរតនកោដ្ឋ***

ខែមីនា ដល់ថ្ងៃទី ៨ ខែតុលា ឆ្នាំ ២០១៣ មានរយៈពេល ៨ ខែ ដោយក្រុមសិលានៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដោយមានសិល្បករ វិចិត្រករ ស្ថូនរូប និងអ្នកជំនាញខាងស្ថាបត្យកម្ម សរុបចំនួន ១១៧ នាក់ ចែកចេញជា ៩ ក្រុម និងចំណាយថវិកាសរុបចំនួន ១ ២២៩ ៨២០ ដុល្លារអាមេរិក។ ចំពោះការរៀបចំបរិវេណជុំវិញវិមាន **ព្រះបរមបដិមា** សាលារាជធានីភ្នំពេញជាអ្នករៀបចំចាត់ចែង។ ដំណើការសាងសង់វិមាន និង **ព្រះបរមបដិមា**ចែកចេញជា ៣ ផ្នែកសំខាន់ៗគឺ :

**ផ្នែកទី ១** : ផ្តោតលើការងាររៀបចំការដ្ឋាន រួមមាន ការងារសម្អាតទីធ្លា សាងសង់ការធ្វើរបងសុវត្ថិភាព ការធ្វើកន្លែងស្នាក់នៅរបស់កម្មករ ឃ្លាំង រោងជាង និងការិយាល័យសម្រាប់ធ្វើការ។ ចំពោះការសិក្សាពិសោធន៍ដីបានបង្ហាញឱ្យឃើញថា ស្ថានភាពដីមានភាពរឹងល្អ អាចឱ្យសសរគ្រឹះឈរបានក្នុង ជម្រៅ ២១ ម៉ែត្រ ហើយការបុកគ្រឹះបានចាប់ដំណើរការនៅថ្ងៃទី១៩ ខែមេសា ឆ្នាំ ២០១៣ ក្នុងនោះទីតាំងបុកគ្រឹះមានចំនួន ១៦៣ រណ្តៅ មានសសរ ចំនួន ២៧៣ ដើម។ ក្រៅពីនេះ គឺការវាស់វែងទីតាំងសាងសង់ ការកំណត់ទំហំវិមាន **ព្រះបរមបដិមា** លើទីតាំងជាក់ស្តែង ការកំណត់ទីតាំងរណ្តៅគ្រឹះ និងដំណើរការសាងសង់តួវិមានទាំងមូល ។

**ផ្នែកទី ២** : សំដៅលើការសូនរូប **ព្រះបរមបដិមា** ដែលត្រូវបានកំណត់យកតាមព្រះរូបខ្នាត ១,៦៨ ម៉ែត្រ ធ្វើពីដីក្រមួនសម្រាប់ជាការសាកល្បង និងព្រះរូបខ្នាត ៤,៥០ ម៉ែត្រ សម្រាប់ការសាងសង់ **ព្រះបរមបដិមា** ពិត ។ ចំណែកឯការសិតស្ពាន់ រួមមានការរៀបចំធ្វើឡសម្រាប់ស្លស្ពាន់និងការចាក់សាកល្បងមុននឹងចាក់សិត**ព្រះបរមបដិមា** តាមខ្នាតពិត ។ ការងារសូន **ព្រះបរមបដិមា** រួមមាន ការសូនដំបូងពីស៊ីម៉ងត៍ដោយប្រើឆ្អឹងបេតុងរួចហើយ ទើបធ្វើការកែ

សម្រួលនៅផ្នែក **ព្រះភ័ក្ត្រព្រះបរមបដិមា** ឱ្យបានត្រឹមត្រូវតាមលំនាំគំរូដែលមាន ។ បន្ទាប់ពីបានកែសម្រួលត្រឹមត្រូវហើយអ្នកជំនាញស្មូនរូបបានរៀបចំស្លក្រមួនដើម្បីធ្វើពុម្ពដីពេជ្រស្រោបក្រមួនដើម្បីចាក់ស្ពាន់ ។

**ផ្នែកទី ៣** : ផ្តោតលើការងារចម្លាក់ក្បាច់ពីស៊ីម៉ង់ត៍សម្រាប់បំពាក់លើតួបុស្បុក និងសម្រាប់លម្អលើតួអគារទាំងមូល និងចម្លាក់បង្គោលសីមាចំនួន ៥៤ និងព្រះទែនកម្ពស់ ២,៧ ម៉ែត្រពីថ្មភក់ ។ ក្រៅពីនេះ គឺការបំពាក់ប្រព័ន្ធអគ្គិសនីបំភ្លឺ ឧបករណ៍ការពាររន្ទះ , សំណង់បុស្បុកព្រះវិមាន រៀបចំបណ្តាញប្រព័ន្ធអគ្គិសនីដោយអំពូលហ្វា LED ទាំងបួនជ្រុង ហើយនៅតាមថ្នាក់នីមួយៗ នៃបុស្បុកទាំង ៧ ជាន់ និងតាមបង្គោលសីមាទាំង ៥៤ ក៏មានបំពាក់ដោយអំពូល LED ដែរ ។ ការងារនេះមានកិច្ចសហការយ៉ាងពេញលេញពីសាលារាជធានីភ្នំពេញដែលបានផ្តល់ការសម្របសម្រួល និងភាពងាយស្រួលយ៉ាងច្រើនចំពោះការភ្ជាប់បណ្តាញអគ្គិសនី ។

វិមាន **ព្រះបរមរូប** ត្រូវបានរចនាតាមទម្រង់បុស្បុក មានកម្ពស់សរុប ២៧ ម៉ែត្រ គិតពីប្លង់បាតខាងក្រោមដល់កំពូល ។ រីឯតួ **ព្រះបរមរូប** ធ្វើអំពីស្ពាន់មានកម្ពស់៤,៥ម៉ែត្រ ទ្រង់លើព្រះទែនមានកម្ពស់ ២,៧ម៉ែត្រ សាងសង់នៅលើខឿនរាងចតុកោណកែងមានបណ្តោយ ៥៤ ម៉ែត្រ ទទឹង ២៧ ម៉ែត្រ កម្ពស់ 0,៩ម៉ែត្រ ។ ការរចនាវិមាន **ព្រះបរមរូប** ប្រកបដោយបុស្បុក និង **ព្រះបរមរូប** ត្រូវបានកំណត់យកខ្នាតយ៉ាងវិសេសវិសាល មួយមានលេខបូកផ្គុំបញ្ចូលគ្នាបានជាលេខ ៩ ដែលតំណាងឱ្យព្រះនព្វគុណទាំង ៩ ឬនព្វលោកុត្តរធម៌ ទាំង ៩ បានដល់ : មគ្គ ៤ ផល ៤ និងនិព្វាន ១ តំណាងឱ្យមង្គលនៃផ្កាយនព្វគ្រោះទាំង៩ មាន : ចន្ទ អង្គារ ពុធ ព្រហស្បតិ៍ សុក្រ សៅរ៍ អាទិត្យ រាហ៊ុ កេតុ និងតំណាងឱ្យនព្វរ័តន៍ទាំង ៩ ប្រការមាន : មុក្តា បទុមរាគ បុស្សរាគ ពេជ្រ មរកត ពិទូរ្យ ប្រពាល កណ្តៀង ផនិក ។

វិមាន **ព្រះបរមរូប ព្រះបរមរតនកោដ្ឋ** ប្រកបដោយក្បូរក្បាច់រចនាដ៏ល្អវិចិត្រនេះ គឺជាស្នាដៃរបស់កូនខ្មែរជំនាន់នេះ ដែលសម្រេចបាននៅក្នុងរយៈពេលដ៏ខ្លី ត្រូវបានសាងសង់ទៅតាមរចនាបថខ្មែរពិតៗ ដើម្បីទុកជាអនុស្សាវរីយ៍វត្ថុដ៏មានតម្លៃកាត់ថ្លៃពុំបាន និងជាកេរមរតកសម្រាប់បច្ឆាជនជំនាន់ក្រោយបានឃើញ និងចងចាំនូវព្រះរាជសកម្មភាពដ៏ថ្លៃថ្លាវិសេសវិសាល និងយកជាគំរូតាមក្នុងការកសាង និងអភិវឌ្ឍមាតុភូមិយើងឱ្យកាន់តែមានភាព សម្បូររុងរឿងថ្កុំថ្កើងជានិច្ចនិរន្តរ៍ សមតាមមាគ៌ាដែលជាព្រះរាជតម្រិះដ៏ខ្ពង់ខ្ពស់របស់ព្រះអង្គដែលបានត្រួសត្រាយទុកមក ។

ការសាងសង់រូបសំណាក **ព្រះមហាវីរក្សត្រ** នៅជិតវិមានឯករាជ្យនេះ ពិតជាមានអត្ថន័យជ្រាលជ្រៅណាស់ ដើម្បីបង្កភាពងាយស្រួលដល់គណៈប្រតិភូបរទេសជាន់ខ្ពស់ ដែលបន្ទាប់ពីបានដាក់កម្រងផ្កានៅវិមានឯករាជ្យ គណៈប្រតិភូនឹងត្រូវបានអញ្ជើញទៅដាក់កម្រងផ្កានៅព្រះភ័ក្ត្ររបស់ **ព្រះបរមរូបព្រះបរមរតនកោដ្ឋ** ទៀត ។ម្យ៉ាងវិញទៀតវិមានឯករាជ្យ ក៏ជាស្នាព្រះហស្តរបស់ព្រះអង្គ ដែលជានិមិត្តរូបក្នុងការទាមទារឯករាជ្យជូនជាតិពីនឹមអាណានិគមនិយមបារាំងផងដែរ ។/



*ថ្នាក់ដឹកនាំព្រឹទ្ធសភា រដ្ឋសភា និងរាជរដ្ឋាភិបាល គោរពព្រះវិញ្ញាណក្ខន្ធ* ***ព្រះករុណា ព្រះបរមរតនកោដ្ឋ***



# រដ្ឋសភានីតិកាលទី ៥ បន្តបើកសម័យប្រជុំលើកទី ១





*រដ្ឋសភានីតិកាលទី ៥ បន្តសម័យប្រជុំលើកទី ១ របស់ខ្លួននៅវិមានរដ្ឋសភា ដើម្បីបោះឆ្នោតជ្រើសតាំង សមាជិកគណៈកម្មការជំនាញទាំង ៩ នៃរដ្ឋសភា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន***





នៅព្រឹកថ្ងៃទី ១០ ខែតុលា ឆ្នាំ ២០១៣ រដ្ឋសភានីតិកាលទី ៥ បានបន្តសម័យប្រជុំលើកទី ១ របស់ខ្លួននៅវិមានរដ្ឋសភា ដើម្បីបោះឆ្នោតជ្រើសតាំងសមាជិកគណៈកម្មការជំនាញទាំង ៩ នៃរដ្ឋសភា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភានិងមានការចូលរួមពីសមាជិកសមាជិការដ្ឋសភាចំនួន ៦៥ រូប ។ តាមការកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា គណៈកម្មការជំនាញនីមួយៗត្រូវមានសមាជិកចំនួន៧ រូប ។

គួរបញ្ជាក់ថា គណៈកម្មការជំនាញទាំង ៩ នៃរដ្ឋសភា រួមមាន ១-គណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្តឹង អង្កេត និងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា ២-គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម ៣-គណៈកម្មការផែនការ វិនិយោគ កសិកម្ម អភិវឌ្ឍន៍ជនបទ បរិស្ថាន និងធនធានទឹក ៤-គណៈកម្មការមហាផ្ទៃ ការពារជាតិ អង្កេត បោសសំអាត និងមុខងារសាធារណៈ ៥-គណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន ៦-គណៈកម្មការនីតិកម្ម និងយុត្តិធម៌ ៧-គណៈកម្មការអប់រំ យុវជន កីឡា ធម្មការ កិច្ចការសាសនា វប្បធម៌ និងទេសចរណ៍ ៨-គណៈកម្មការសុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារី និង ៩-គណៈកម្មការ សាធារណការ ដឹកជញ្ជូន ទូរគមនាគមន៍ ប្រៃសណីយ៍ ឧស្សាហកម្ម រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដី នគររូបនីយកម្ម និងសំណង់ ។ ដំណើរការបោះឆ្នោតជ្រើសតាំងសមាជិកគណៈកម្មការជំនាញនៃរដ្ឋសភាបានប្រព្រឹត្តទៅដោយជោគជ័យ ដោយមានសំឡេងគាំទ្រចំនួន ៦៥ សំឡេងលើចំនួនសមាជិកសភាមានវត្តមានចំនួន ៦៥ រូប ។

ដោយឡែក នៅថ្ងៃទី ១៦ ខែតុលា ឆ្នាំ ២០១៣ គណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភា ក្រោមអធិបតីភាពសម្តេចចក្រី **ហេង សំរិន** បានធ្វើការប្រជុំពិភាក្សាលើរបៀបវារៈស្តីពីថវិកាចំណាយរបស់រដ្ឋសភា សម្រាប់ឆ្នាំ ២០១៤ ខាងមុខនេះ ។ អង្គប្រជុំបានសម្រេចឯកភាពលើកគម្រោងថវិកាចំណាយចំនួនជាងមួយរយពាន់លានរៀល ឬស្មើនឹង ២៥ លានដុល្លារ ទាំងចំណាយចរន្ត និងចំណាយជាមូលធន ។/

# កិច្ចប្រជុំកំពូលអាស៊ានលើកទី ២៣ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធនានានៅប្រទេសប្រ៊ុយណេ




*ប្រមុខរដ្ឋ ប្រមុខរដ្ឋាភិបាលអាស៊ានទាំង ១០ ប្រទេស ក្នុងឱកាសចូលរួមកិច្ចប្រជុំកំពូលអាស៊ានលើកទី ២៣ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធនានានៅទីក្រុងបាន់ដាសេរីបេហ្គាវ៉ាន់ រាជាណាចក្រប្រ៊ុយណេ ដារុយសាឡឹម*

ថ្ងៃទី ០៨-១០ ខែតុលា ឆ្នាំ ២០១៣ សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាបានដឹកនាំគណៈប្រតិភូជាន់ខ្ពស់នៃរាជរដ្ឋាភិបាលកម្ពុជា អញ្ជើញចូលរួមកិច្ចប្រជុំកំពូលអាស៊ានលើកទី ២៣ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធនានានៅទីក្រុងបាន់ដាសេរីបេហ្គាវ៉ាន់ រាជាណាចក្រប្រ៊ុយណេ ដារុយសាឡឹម ។

នៅព្រឹកថ្ងៃទី ៩ ខែតុលា កិច្ចប្រជុំកំពូលលើកទី ២៣ បានប្រារព្ធឡើងដោយមានការអញ្ជើញចូលរួមពីប្រមុខរដ្ឋ ប្រមុខរដ្ឋាភិបាលអាស៊ានទាំង ១០ ប្រទេស។ កិច្ចប្រជុំបានពិភាក្សាទៅលើបញ្ហាសំខាន់ៗចំនួន ៣ គឺទី១-សហគមន៍អាស៊ានឆ្នាំ ២០១៥ និងឆ្នាំខាងមុខ ទី២-មុខនាទីស្នូលរបស់អាស៊ាននិងទំនាក់ទំនងជាមួយដៃគូខាងក្រៅនិងទី៣-បញ្ហាតំបន់និងអន្តរជាតិ។ មេដឹកនាំអាស៊ានបានទទួលស្គាល់ធម្មនុញ្ញអាស៊ាន និងសន្ធិសញ្ញាមិត្តភាព និងសហប្រតិបត្តិការក្នុងតំបន់អាស៊ីអាគ្នេយ៍ថា ជាមូលដ្ឋាននៃគោលការណ៍ និងគុណតម្លៃស្នូលរបស់អាស៊ានដែលត្រូវប្រកាន់ឱ្យខ្ជាប់។ បណ្ដាមេដឹកនាំអាស៊ានបានរំឭកឡើងវិញអំពីផែនទីចង្អុលផ្លូវសម្រាប់សហគមន៍អាស៊ាន (២០០៩-២០១៥) ដែលប្រមើលមើលពីការបង្កើតឡើងនូវសហគមន៍អាស៊ានមួយក្នុងឆ្នាំ ២០១៥ និងផែនការមេស្ដីពីការតភ្ជាប់អាស៊ានដែលនឹងបំពេញបន្ថែម និងគាំទ្រសមាហរណកម្មអាស៊ានតាមរយៈការតភ្ជាប់ជាលក្ខណៈជារូបវន្ត ស្ថាប័ន និងរវាងប្រជាជននឹងប្រជាជន។ មេដឹកនាំអាស៊ានបានជំរុញឆន្ទៈក្នុងការធ្វើឱ្យតំបន់អាស៊ីអាគ្នេយ៍ទៅជាតំបន់មួយដែលចងជាធ្លុងមួយដោយចក្ខុវិស័យតែមួយ អត្តសញ្ញាណតែមួយ សហគមន៍តែមួយ។ តាមរយៈនេះ មេដឹកនាំអាស៊ានបានឯកភាពរៀបចំចក្ខុវិស័យសម្រាប់អាស៊ានក្រោយឆ្នាំ ២០១៥ ក្នុងនោះរួមមានការសម្រេចឱ្យបាននូវតំបន់អាស៊ានដែលមានប្រជាជនជាស្នូលក្នុងការជួយឱ្យសម្រេចបាននូវបំណងប្រាថ្នារួមគ្នាមួយសម្រាប់ប្រជាជនរបស់យើង ដូចជាអភិបាលកិច្ចល្អ ការលុបបំបាត់ភាពក្រីក្រ ការអភិវឌ្ឍប្រកបដោយចីរភាព និងអាចទទួលបានផលប្រយោជន៍ទាំងអស់គ្នា ការការពារសង្គម និងការផ្ដល់សិទ្ធិអំណាចដល់ប្រជាជនទន់ខ្សោយគ្មានទីពឹង ការលើកកម្ពស់ និងការការពារសិទ្ធិមនុស្ស ការការពារបរិស្ថាន។ បង្រួមគម្លាតអភិវឌ្ឍន៍រវាងសមាជិកនៃក្រុមគ្រួសារអាស៊ីអាគ្នេយ៍។ បង្កើតតំបន់មួយដែលប្រកបដោយសន្តិភាព វិបុលភាព គ្មានជម្លោះ គ្មានអាវុធប្រល័យលោក និងគ្រឿនញៀន។ ពង្រឹងបន្ថែមនូវសហគមន៍អាស៊ានដែលផ្អែកលើច្បាប់។ បង្កើតតំបន់អាស៊ានមួយដែលកាន់តែមានសមាហរណកម្ម និងការប្រកួតប្រជែងផ្នែកសេដ្ឋកិច្ច ។ ពង្រីកតួនាទីស្នូលរបស់អាស៊ាន និងភាពជាអ្នកដឹកនាំនៅក្នុងនិម្មាបនកម្មតំបន់ដែលកំពុងមានការវិវឌ្ឍ និងការចូលរួមកាន់តែសកម្មប្រកបដោយការស្ថាបនារបស់អាស៊ាននៅក្នុងកិច្ចការសកលដែលជាប្រយោជន៍ និងកង្វល់រួម។ ធ្វើឱ្យរឹងមាំបន្ថែមទៀតនូវទំនាក់ទំនងក្រៅតំបន់ជាមួយដៃគូសន្ទនាឱ្យកាន់តែមានប្រសិទ្ធភាព ស្មើភាព និងមានសារៈសំខាន់។ ពាក់ព័ន្ធបញ្ហាតំបន់ និងអន្តរជាតិ មេដឹកនាំអាស៊ានបានបញ្ជាក់ជាថ្មីទៀតពីការគាំទ្ររបស់អាស៊ានដើម្បីរក្សាសន្តិភាព ស្ថិរភាព និងសន្តិសុខលំហសមុទ្រនៅក្នុងតំបន់ តាមរយៈសេចក្ដីថ្លែងការណ៍ស្ដីពីក្រមប្រតិបត្តិរបស់ភាគីនៅក្នុងសមុទ្រចិនខាងត្បូង (DOC) គោលការណ៍៦ចំណុចរបស់អាស៊ានស្ដីពីសមុទ្រចិនខាងត្បូង និងសេចក្ដីប្រកាសរួមអាស៊ាន-ចិន ស្ដីពីខួបលើកទី ១០នៃការប្រតិបត្តិរបស់ភាគីនៅសមុទ្រចិនខាងត្បូង។ មេដឹកនាំអាស៊ានសង្ឃឹមថានឹងធ្វើការឱ្យកាន់តែជិតស្និទ្ធជាមួយចិនលើការរៀបចំក្រមប្រតិបត្តិនៅសមុទ្រចិនខាងត្បូង (DOC) ដែលមានតួនាទីដើម្បីធ្វើឱ្យប្រសើរឡើងនូវសន្តិភាព ស្ថិរភាព និងវិបុលភាពនៅក្នុងតំបន់ តាមរយៈការអនុវត្តឱ្យបានពេញលេញ និងប្រកបដោយប្រសិទ្ធភាពនូវការប្រតិបត្តិរបស់ភាគីនៅ



*ទិដ្ឋភាពរួមនៃកិច្ចប្រជុំកំពូលអាស៊ានលើកទី ២៣ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធនានានៅទីក្រុងបាន់ដាសេរីបេហ្គាវ៉ាន់ រាជាណាចក្រប៊្រុយណេ ដារុយសាឡឹម*



*សម្តេចតេជោ **ហ៊ុន សែន** ក្នុងឱកាសនៃកិច្ចប្រជុំកំពូលអាស៊ានលើកទី ២៣ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធនានានៅទីក្រុងបាន់ដាសេរីបេហ្គាវ៉ាន់ រាជាណាចក្រប៊្រុយណេ ដារុយសាឡឹម*

សមុទ្រចិនខាងត្បូង។ មេដឹកនាំអាស៊ានក៏បានសម្តែងក្តីកង្វល់ជាមួយសហគមន៍អន្តរជាតិចំពោះការប្រើប្រាស់អាវុធគីមីនៅស៊ីរី ដែលធ្វើឱ្យបាត់បង់អាយុជីវិតជនស៊ីវិលជាច្រើននាក់។ កិច្ចប្រជុំអាស៊ានលើកទី ២៣ បានចេញសេចក្តីថ្លែងការណ៍ ដែលបានអនុម័តទៅលើបញ្ហាជាច្រើនដូចជាសេចក្តីប្រកាសបាន់ដាសេរីបេហ្គាវ៉ាន់ ស្តីពីចក្ខុវិស័យរបស់សហគមន៍អាស៊ានក្រោយឆ្នាំ ២០១៥ ការពិនិត្យឡើងវិញនូវផែនការលម្អិតពាក់ព័ន្ធកណ្តាលអាណត្តិនៃសហគមន៍សង្គម-វប្បធម៌អាស៊ាន អនុម័តសេចក្តីថ្លែងការណ៍ស្តីពីសហគ្រិនភាព យុវជន និងការងារ ជំងឺមិនឆ្លងក្នុងតំបន់អាស៊ាន ការលើកកម្ពស់កិច្ចសហប្រតិបត្តិការក្នុងការគ្រប់គ្រងគ្រោះមហន្តរាយ ការពង្រឹងកិច្ចគាំពារសង្គម ការលុបបំបាត់អំពើហិង្សាលើស្ត្រី និងការលុបបំបាត់អំពើហិង្សាលើកុមារក្នុងអាស៊ាន ។

នៅថ្ងៃទី ៩ ខែតុលា កិច្ចប្រជុំកំពូលអាស៊ាន-ជប៉ុន លើកទី ១៦ បានប្រារព្ធឡើងដោយមានការចូលរួមពីប្រមុខដឹកនាំអាស៊ាន និងឯកឧត្តម **ស៊ីនហ្សូអាបេ** នាយករដ្ឋមន្ត្រីជប៉ុន។ កិច្ចប្រជុំនេះមានគោលបំណងពិនិត្យឡើងវិញអំពីទិសដៅអនាគតនៃទំនាក់ទំនងអាស៊ាន-ជប៉ុន។ សម្តេចតេជោ **ហ៊ុន សែន** បានថ្លែងក្នុងកិច្ចប្រជុំនោះថាវឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពអាស៊ាន-ជប៉ុនឆ្នាំ ២០១១-២០១៥ ដែលត្រូវបានដាក់ឱ្យអនុវត្តមិនគ្រាន់តែដើរតួនាទីយ៉ាងសំខាន់ក្នុងការធ្វើឱ្យកាន់តែស៊ីជម្រៅនូវភាពជាដៃគូយុទ្ធសាស្ត្រអាស៊ាន-ជប៉ុនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានរួមចំណែកដល់ការកសាងសហគមន៍អាស៊ាននាឆ្នាំ ២០១៥ និងបណ្តាឆ្នាំខាងមុខ។ សម្តេចតេជោបញ្ជាក់ទៀតថា ក្នុងនាមជាអ្នកសម្របសម្រួលទំនាក់ទំនងអាស៊ាន-ជប៉ុន កម្ពុជានឹងខិតខំបំពេញការងារ និងសហការឱ្យបានជិតស្និទ្ធជាមួយបណ្តាប្រទេសជាសមាជិកអាស៊ាន និងប្រទេសជប៉ុន ដើម្បីធានាដល់ការរៀបចំឱ្យបានជោគជ័យនូវកិច្ចប្រជុំកំពូលរំឭកខួបអនុស្សាវរីយ៍អាស៊ាន-ជប៉ុន ដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី ១៣-១៥ ខែធ្នូ ឆ្នាំ ២០១៣ នៅទីក្រុងតូក្យូ ដើម្បីអបអរសាទរខួបទី ៤០ ឆ្នាំនៃទំនាក់ទំនងកិច្ចសន្ទនាអាស៊ាន-ជប៉ុន។ ក្នុងពេលនោះ ឯកឧត្តម **ស៊ីនហ្សូអាបេ** បានបញ្ជាក់ពីការតាំងចិត្តរបស់រាជរដ្ឋាភិបាលជប៉ុនក្នុងការបន្តជួយដល់បណ្តាប្រទេសអាស៊ានក្នុងក្របខណ្ឌពាក់ព័ន្ធទៅនឹងការវិនិយោគទំនាក់ទំនង និងការផ្លាស់ប្តូរយុវជន និងទំនាក់ទំនងរវាងប្រជាជន និងប្រជាជន។ ឯកឧត្តម **អាបេ** បានផ្តល់នូវសារៈសំខាន់ដ៏ខ្ពស់បំផុត ចំពោះសន្តិសុខនៅតំបន់អាស៊ី ពិសេសការឯកភាពគ្នាក្នុងចំណោមបណ្តាប្រទេសអាស៊ាន។

នៅថ្ងៃទី ៩ ខែតុលា កិច្ចប្រជុំកំពូលអាស៊ាន-កូរ៉េលើកទី ១៦ បានដំណើរការដោយមានការចូលរួមពីមេដឹកនាំអាស៊ាន និងលោកជំទាវ **ប៉ាក់ យ៉ុនហេ** ប្រធានាធិបតីនៃសាធារណរដ្ឋកូរ៉េ។ ថ្លែងនៅក្នុងពេលនោះ សម្តេចតេជោ **ហ៊ុន សែន** បានស្វាគមន៍ចំពោះសំណើរបស់កូរ៉េក្នុងការរៀបចំកិច្ចប្រជុំកំពូលពិសេសអាស៊ាន-សាធារណរដ្ឋកូរ៉េឆ្នាំ ២០១៤ នៅសាធារណរដ្ឋកូរ៉េ ដើម្បីរំឭកខួបទី ២៥ ឆ្នាំ នៃកិច្ចសន្ទនាអាស៊ាន-សាធារណរដ្ឋ កូរ៉េ ។ សម្តេចតេជោបានសម្តែងការពេញចិត្តចំពោះកំណើនពាណិជ្ជកម្មរវាងអាស៊ាន-សាធារណរដ្ឋកូរ៉េ ដែលសម្រេចបានដល់ ១៣១ ពាន់លានដុល្លាអាមេរិកក្នុងឆ្នាំ ២០១២ ។ សម្តេចតេជោបានស្នើឱ្យមានការខិតខំបន្ថែមទៀតក្នុងការអនុវត្តកិច្ចព្រមព្រៀងតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-សាធារណរដ្ឋកូរ៉េឱ្យបានពេញលេញ ដើម្បីឈានទៅសម្រេចបានគោលដៅ ១៥០ ពាន់លានដុល្លារអាមេរិកក្នុងឆ្នាំ ២០១៥។ បណ្តាមេដឹកនាំទាំងអស់ដែលបានចូលរួមក្នុងកិច្ចប្រជុំកំពូលនេះបានស្វាគមន៍នូវរាល់លទ្ធផលនៃកិច្ចសហប្រតិបត្តិការអាស៊ាន-សាធារណរដ្ឋកូរ៉េ និងបានពិភាក្សាលើបញ្ហាជាច្រើនទៀតដែលមានផលប្រយោជន៍សម្រាប់ប្រជាជនក្នុងតំបន់។

នៅថ្ងៃទី ៩ ខែតុលា ដដែល កិច្ចប្រជុំកំពូលអាស៊ាន-សាធារណរដ្ឋប្រជាមានិតចិនលើកទី ១៦ បានប្រព្រឹត្តទៅដោយមានការចូលរួមពីមេដឹកនាំកំពូលអាស៊ាន និងឯកឧត្តម **លីខឺ ឈាង** នាយករដ្ឋមន្ត្រីចិន។ ក្នុងកិច្ចប្រជុំនោះ សម្តេចតេជោ **ហ៊ុន សែន** បានកោតសរសើរចំពោះវឌ្ឍនភាពដែលសម្រេចបានក្នុងការអនុវត្តសេចក្តីថ្លែងការណ៍ស្តីពីក្រមប្រតិបត្តិរបស់ភាគីនៅសមុទ្រចិនខាងត្បូង (DOC) ជាពិសេសតាមរយៈលទ្ធផលជាផ្លែផ្កានៃកិច្ចប្រជុំលើកទី ៦ របស់ឧត្តមមន្ត្រី និងកិច្ចប្រជុំលើកទី ៩ របស់ក្រុមការងាររួមអាស៊ាន-ចិន ស្តីពីការអនុវត្តសេចក្តីថ្លែងការណ៍ស្តីពីក្រមប្រតិបត្តិរបស់ភាគីនៅសមុទ្រចិនខាងត្បូង (DOC) នៅទីក្រុង



*សម្តេចតេជោ **ហ៊ុន សែន** ក្នុងជំនួបជាមួយឯកឧត្តម **បាន គីមូន***

ស៊ូចូវ ប្រទេសចិន ។ កិច្ចប្រជុំបានឯកភាពគ្នាជំរុញឱ្យមានការចុះហត្ថលេខាលើសន្ធិសញ្ញាភាពជាប្រទេសជិតខាងល្អ ពិសេសសហប្រតិបត្តិការរវាងអាស៊ាន និងចិន។ ស្វាគមន៍ចំពោះការបង្កើតធនាគារសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធក្នុងបណ្តាប្រទេសអាស៊ាន តាមរយៈការផ្តល់ជំនួយមួយចំនួនពីប្រទេសចិន។ មេដឹកនាំទាំងអស់ក៏បានគូសបញ្ជាក់ពីសមត្ថភាពក្នុងការដោះស្រាយនូវរាល់បញ្ហានានាក្នុងក្របខណ្ឌអាស៊ាន-ចិនផងដែរ។ នៅរសៀលថ្ងៃទី ៩ ខែតុលា កិច្ចប្រជុំកំពូលអាស៊ាន-សហរដ្ឋអាមេរិកលើកទី ១ បានប្រព្រឹត្តទៅដោយមានការចូលរួមពីមេដឹកនាំអាស៊ាន និងឯកឧត្តម **ចន ឃែរី** រដ្ឋមន្ត្រីការបរទេសអាមេរិក តំណាងឯកឧត្តម **បារ៉ាក់ អូបាម៉ា** ប្រធានាធិបតីអាមេរិក ។ សម្តេចតេជោ **ហ៊ុន សែន** បានថ្លែងក្នុងកិច្ចប្រជុំនោះដោយបានស្វាគមន៍ដល់ការគាំទ្ររបស់សហរដ្ឋអាមេរិកចំពោះការអនុវត្តផែនការមេស្តីពីការតភ្ជាប់អាស៊ាន និងកិច្ចប្រឹងប្រែងរបស់អាមេរិក ក្នុងការបង្កើនការវិនិយោគរបស់ខ្លួននៅក្នុងតំបន់មេគង្គក្រោម តាមរយៈគំនិតផ្តួចផ្តើមមេគង្គក្រោមដើម្បីជំរុញការធ្វើសមាហរណកម្ម និងការតភ្ជាប់អាស៊ាន។ សម្តេចតេជោ **ហ៊ុន សែន** បានស្នើឱ្យអាមេរិកជួយបង្កើនអាហារូបករណ៍ដល់និស្សិតអាស៊ាន ជាពិសេសបណ្តាប្រទេសមានការអភិវឌ្ឍតិចតួចនៅក្នុងតំបន់អាស៊ាន និងបានស្នើរកថវិកាសម្រាប់សាលាក្តីកាត់ទោសមេដឹកនាំខ្មែរក្រហម។ ឯកឧត្តម **ចន ឃែរី** បានបញ្ជាក់ថា អាមេរិកបានប្តេជ្ញារួចមកហើយក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេសក្នុងតំបន់អាស៊ាន។ ទាក់ទិនបញ្ហាសមុទ្រចិនខាងត្បូងឯកឧត្តម **ចន ឃែរី** បានស្នើឱ្យមានការឈានទៅសម្រេច DOC ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន។ ទាក់ទិនទៅនឹងសាលាក្តីកាត់ទោសមេដឹកនាំខ្មែរក្រហម ឯកឧត្តម **ចន ឃែរី** បានមានប្រសាសន៍ថា ឯកឧត្តមនឹងជួបពិភាក្សាការងារបញ្ហានេះជាមួយអគ្គលេខាធិការអង្គការសហប្រជាជាតិ ដើម្បីរកថវិកាដល់ដំណើរការសាលាក្តីនេះ។

នៅរសៀលថ្ងៃទី៩ ខែតុលា ដដែល កិច្ចប្រជុំកំពូលអាស៊ាន-ឥណ្ឌា លើកទី ១១ បានប្រព្រឹត្តទៅដោយមានការចូលរួមពីមេដឹកនាំកំពូលអាស៊ាន និងឯកឧត្តម **ម៉ាន់ ម៉ូហាន់ស៊ីង** នាយករដ្ឋមន្ត្រីឥណ្ឌា។ ថ្លែងនៅក្នុងឱកាសនោះ សម្តេចតេជោ **ហ៊ុន សែន** បានចាត់ទុកថា ការលើកកម្ពស់កិច្ចសហប្រតិបត្តិការអាស៊ាន-ឥណ្ឌា គឺពិតជាមានសារៈសំខាន់ខ្លាំងណាស់ក្នុងការទាញយកកាលានុវត្តភាពវិស័យពាណិជ្ជកម្មអាស៊ាន-ឥណ្ឌាឱ្យបានដល់ ១០០ ពាន់លានដុល្លារអាមេរិកនៅឆ្នាំ ២០១៥។ សម្តេចតេជោបានអំពាវនាវឱ្យមានការកសាងផ្លូវអាស៊ានហាយវេតភ្ជាប់ឥណ្ឌា មីយ៉ាន់ម៉ា ឡាវ វៀតណាម និងកម្ពុជា និងផ្លូវហាយវេត្រីភាគីឥណ្ឌា មីយ៉ាន់ម៉ា និងថៃ ព្រមទាំងពង្រីកការតភ្ជាប់មកកាន់ប្រទេសឡាវ និងកម្ពុជាឱ្យបានកាន់តែឆាប់តាមដែលអាចធ្វើឱ្យទៅបាន ដើម្បីបង្ហាញការប្តេជ្ញាចិត្តគាំទ្ររបស់ឥណ្ឌាលើការតភ្ជាប់បណ្តាញដឹកជញ្ជូន។ កិច្ចប្រជុំកំពូលនេះ បានស្វាគមន៍ដល់ការបង្កើតមជ្ឈមណ្ឌលអាស៊ាន-ឥណ្ឌា និងវឌ្ឍនភាពនៃការបង្កើតមជ្ឈមណ្ឌលពាណិជ្ជកម្ម និងវិនិយោគអាស៊ាន-ឥណ្ឌា នៅប្រទេសឥណ្ឌាដែលអាចជួយជំរុញដល់វិស័យពាណិជ្ជកម្ម វិនិយោគ ទេសចរណ៍ និងការផ្លាស់ប្តូរវប្បធម៌រវាងគ្នាទៅវិញទៅមក។

កិច្ចប្រជុំកំពូលអាស៊ាន-អង្គការសហប្រជាជាតិលើកទី ៥ បានដំណើរការនៅរសៀលថ្ងៃទី ៩ ខែតុលា នេះដែរ ដោយមានការចូលរួមពីប្រមុខដឹកនាំអាស៊ាន និងឯកឧត្តម **បាន គីមូន** អគ្គលេខាធិការ អ.ស.ប។ ថ្លែងក្នុងឱកាសនោះសម្តេចតេជោ **ហ៊ុន សែន** អំពាវនាវឱ្យមានការពន្លឿនការអនុវត្តសេចក្តីថ្លែងការណ៍រួមស្តីពីភាពជាដៃគូគ្រប់ជ្រុងជ្រោយរវាងអាស៊ាននឹង អ.ស.ប និងឧបសម្ព័ន្ធនៃសេចក្តីថ្លែងការណ៍រួម ដើម្បីដោះស្រាយបញ្ហាប្រឈមក្នុងកម្រិតតំបន់និងសាកលលោក រួមទាំងការប្តេជ្ញាចិត្តរបស់អាស៊ាន ក្នុងការសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្ស។ ឯកឧត្តម **បាន គីមូន** បានថ្លែងថា អ.ស.ប នឹងជួយនូវរាល់ការលំបាកសព្វបែបយ៉ាងដល់អាស៊ានក្នុងការធ្វើសមាហរណកម្មអាស៊ាន និងការបង្កើតសហគមន៍អាស៊ាននៅឆ្នាំ ២០១៥ ពិសេសការរួមគ្នាធ្វើឱ្យបានសម្រេចនូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរបស់អ.ស.ប។ កិច្ចប្រជុំកំពូលបានកត់សម្គាល់ថា ភាពខុសគ្នាក្នុងការសម្រេចបាននូវគោលដៅអភិឌ្ឍន៍សហស្សវត្សនៅតែបន្តកើតមានមិនថាតែនៅក្នុងវិស័យសុខាភិបាល អប់រំ ភាពក្រីក្រ អាហារូបត្ថម្ភ ទឹក អនាម័យ និងបរិស្ថាននោះទេ ហើយបញ្ហានេះ ទាមទារឱ្យមានការគាំទ្ររបស់អ.ស.បចំពោះបណ្តាសមាជិករដ្ឋភាគីអាស៊ានក្នុងការសម្រេចនូវគោលដៅអភិវឌ្ឍន៍សហស្សវត្សនៅតែជាតម្រូវការដ៏ចាំបាច់និងនៅតែទទួលបាននូវការស្វាគមន៍ជានិច្ច។

នៅព្រឹកថ្ងៃទី ១០ ខែតុលា កិច្ចប្រជុំកំពូលអាស៊ានបូក ៣ (ចិន-ជប៉ុន-សាធារណរដ្ឋកូរ៉េ) លើកទី ១៦ បានប្រារព្ធឡើងដោយបានធ្វើការពិនិត្យឡើងវិញអំពីការកំណត់ទិសដៅអនាគតនៃទំនាក់ទំនងអាស៊ានបូក ៣ ព្រមទាំងផ្លាស់ប្តូរទស្សនៈអំពីបញ្ហាតំបន់ និងអន្តរជាតិ។ នៅក្នុងកិច្ចប្រជុំកំពូលនេះ សម្តេចតេជោ **ហ៊ុន សែន** បានស្នើឱ្យមានការយកចិត្តទុកដាក់ដល់ការផ្តល់ជំនួយបច្ចេកទេសពីសំណាក់ប្រទេសបូក៣ចំពោះកម្ពុជា ឡាវ មីយ៉ាន់ម៉ា វៀតណាម ដើម្បីពង្រីកសមត្ថភាពចរាចរណ៍

ពាណិជ្ជកម្ម។ សម្តេចតេជោបានស្នើដោយទទូចឱ្យមានការអនុវត្តយ៉ាងពេញលេញកិច្ចព្រមព្រៀងអង្គរបម្រុងសម្រាប់គ្រាអាសន្ននៃប្រទេសអាស៊ានបូក៣ដែលប្រការនេះ អាចធានាបាននូវសន្តិសុខស្បៀងមួយកម្រិតទៀតនៅក្នុងតំបន់។ កិច្ចប្រជុំកំពូលនេះបានធ្វើការពិភាក្សា ដោយផ្តោតទៅលើគ្រប់ទិដ្ឋភាពនយោបាយ សេដ្ឋកិច្ច សង្គម ការប្រែប្រួលអាកាសធាតុ សន្តិសុខស្បៀង និងថាមពល ការគ្រប់គ្រងគ្រោះមហន្តរាយ ការទប់ស្កាត់ការរីករាលដាលនៃជំងឺឆ្លង ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម និងការប្តេជ្ញាជួយគាំទ្រតាមគ្រប់រូបភាពក្នុងការកសាងសហគមន៍អាស៊ាន ឱ្យបានសម្រេចនៅឆ្នាំ ២០១៥ ខាងមុខ ។ កិច្ចប្រជុំក៏បានធ្វើការពិភាក្សាអំពីបញ្ហាទាក់ទិនទៅនឹងបញ្ហានៅឧបទ្វីបកូរ៉េ ព្រមទាំងបានលើកទឹកចិត្តឱ្យបន្តកិច្ចពិភាក្សា ៦ ភាគីឡើងវិញ។

នៅថ្ងៃទី ១០ ខែតុលា នេះដែរ កិច្ចប្រជុំកំពូលអាស៊ីបូព៌ាលើកទី ៨ បានប្រារព្ធពិធីឡើងដើម្បីពិភាក្សា ទៅលើបញ្ហាសន្តិសុខស្បៀង និងថាមពល ការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងគ្រោះមហន្តរាយ។ ថ្លែងនៅក្នុងពេលនោះសម្តេចតេជោ **ហ៊ុន សែន** បានគាំទ្រយ៉ាងពេញទំហឹងចំពោះសេចក្តីថ្លែងការណ៍នៃកិច្ចប្រជុំកំពូលអាស៊ីបូព៌ាលើកទី ៨ ស្តីពីសន្តិសុខស្បៀង ដែលផ្តួចផ្តើមឡើងដោយប្រទេសប្រ៊ុយណេ។ សម្តេចតេជោ **ហ៊ុន សែន** ក៏បានស្នើឱ្យមានការជំរុញការអនុវត្តឱ្យបានពេញលេញនូវសេចក្តីថ្លែងការណ៍របស់កិច្ចប្រជុំកំពូលអាស៊ីបូព៌ាលើកទី ៧ ស្តីពីការឆ្លើយតបថ្នាក់តំបន់ទៅនឹងការគ្រប់គ្រងជំងឺគ្រុនចាញ់ និងការដោះស្រាយភាពស៊ាំនឹងឱសថប្រឆាំងជំងឺគ្រុនចាញ់ ដែលត្រូវបានអនុវត្តក្នុងកិច្ចប្រជុំកំពូលអាស៊ីបូព៌ានៅរាជធានីភ្នំពេញក្នុងឆ្នាំ ២០១២ ។ កិច្ចប្រជុំកំពូលនេះ បានសម្តែងនូវការពេញចិត្តចំពោះវឌ្ឍនភាពនៃកិច្ចសហប្រតិបត្តិការអាស៊ីបូព៌ាដែលបានសម្រេចកន្លងមក ជាពិសេសលទ្ធផលនៃកិច្ចប្រជុំអាស៊ីបូព៌ាលើកទី ៧ កាលពីថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ ២០១២ នៅរាជធានីភ្នំពេញដែលបានដាក់ចេញនូវវិធានការដ៏មានប្រសិទ្ធភាពនានាចំពោះការគ្រប់គ្រងជំងឺគ្រុនចាញ់ និងការដោះស្រាយភាពស៊ាំនៃឱសថប្រឆាំងជំងឺគ្រុនចាញ់ ព្រមទាំងបានស្វាគមន៍ចំពោះវឌ្ឍនភាព និងការឯកភាពក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការក្នុងក្របខណ្ឌអាស៊ីបូព៌ាលើវិស័យអាទិភាពចំនួន ៦ រួមមាន វិស័យហិរញ្ញវត្ថុ ថាមពល អប់រំ សុខភាពសកល ជំងឺឆ្លង និងការគ្រប់គ្រងគ្រោះមហន្តរាយ។ កិច្ចប្រជុំកំពូលក៏បានគូសបញ្ជាក់អំពីការលើកកម្ពស់ការគោរពគ្នាទៅវិញទៅមកនូវឯករាជ្យភាព អធិបតេយ្យ សមភាព បូរណភាពដែនដី អត្តសញ្ញាណជាតិ ការការពារសិទ្ធិមនុស្ស និងការលើកកម្ពស់យុត្តិធម៌សង្គម ព្រមទាំងជំរុញកិច្ចសហប្រតិបត្តិការក្នុងការគាំទ្រការអនុវត្តផែនការមេស្តីពីការតភ្ជាប់អាស៊ាន និងការជំរុញការតភ្ជាប់នៅក្នុងតំបន់អាស៊ីបូព៌ា។

គួរបញ្ជាក់ថា ក្រៅពីជំនួបកំពូលអាស៊ាន សម្តេចតេជោ **ហ៊ុន សែន** ក៏បានទទួលជួបពិភាក្សាការងារ ទ្វេភាគីជាមួយឯកឧត្តម **បាន គីមូន** អគ្គលេខាធិការអ.ស.បនារសៀលថ្ងៃទី ១០ ខែតុលា។ *ឯកឧត្តមបានសម្តែងនូវការវាយតម្លៃខ្ពស់ និងកោតសរសើរចំពោះការបោះឆ្នោតនៅក្នុងប្រទេសកម្ពុជាកាលពីថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០១៣ កន្លងទៅដែលបានប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ យុត្តិធម៌មានភាពស្ងប់ស្ងាត់ និងប្រកបដោយសុខសន្តិភាព។ ឯកឧត្តមបានគាំទ្រចំពោះសម្តេចនាយករដ្ឋមន្ត្រី* ***ហ៊ុន សែន*** *ក្នុងការបន្តដឹកនាំរាជរដ្ឋាភិបាលនីតិកាលទី ៥ នៃរដ្ឋសភាពីឆ្នាំ ២០១៣ ដល់ឆ្នាំ ២០១៨ បន្តទៀត ព្រមទាំងបានអបអរសាទរចំពោះគណបក្សប្រជាជនកម្ពុជាដែលទទួលជោគជ័យក្នុងការបោះឆ្នោតកាលពីថ្ងៃទី ២៨ ខែកក្កដា កន្លងទៅនេះ។* ទាក់ទិននឹងសំណួររបស់ឯកឧត្តម **បាន គីមូន** អំពីការមិនចូលរួមប្រជុំសភាលើកដំបូងរបស់គណបក្សប្រឆាំង សម្តេចតេជោ **ហ៊ុន សែន** ថ្លែងថា មិនមានអ្វីប្លែកទេ ក្នុងរយៈពេល ៥ ឆ្នាំនៃដំណើរការបោះឆ្នោតនៅកម្ពុជា ។ គណបក្សប្រឆាំងដែលចាញ់ឆ្នោតតែងតែធ្វើពហិការមិនទទួលស្គាល់លទ្ធផលនៃការបោះឆ្នោត ប៉ុន្តែគណបក្សប្រឆាំងមិនដែលបោះបង់ចោលអាសនៈរបស់ខ្លួនដែលទទួលបានពីដំណើរការបោះឆ្នោតតាមបែបប្រជាធិបតេយ្យ និងទាមទារនូវបុព្វសិទ្ធិ និងប្រាក់បៀវត្សទៅវិញ។ ចំពោះការដែលគណបក្សប្រឆាំងទាមទារតំណែងប្រធានរដ្ឋសភា សម្តេចតេជោ **ហ៊ុន សែន** បញ្ជាក់ថា ធម្មតាគណបក្សដែលឈ្នះឆ្នោតតែងតែធ្វើជាប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រី។ ទាក់ទិនអំពីសាលាក្តីកាត់ទោសមេដឹកនាំខ្មែរក្រហមដែលកំពុងជួបនឹងកង្វះថវិកា ឯកឧត្តមអគ្គលេខាធិការ អ.ស.ប មានប្រសាសន៍ថា ឯកឧត្តមនឹងបញ្ជូនមន្ត្រី អ.ស.ប ទៅកាន់ប្រទេសកម្ពុជាដើម្បីដោះស្រាយបញ្ហានេះប្រកបដោយភាពវិជ្ជមានបំផុត។

នៅថ្ងៃទី១០ ខែតុលានេះដែរ សម្តេចតេជោ **ហ៊ុន សែន** ក៏បានជួបពិភាក្សាការងារទ្វេភាគីជាមួយ ឯកឧត្តម **ចន ឃី** នាយករដ្ឋមន្ត្រីនូវែលហ្សេឡង់។ ឯកឧត្តម **ចន ឃី** បានសម្តែងនូវការស្វាគមន៍ និងជូនពរយ៉ាងកក់ក្តៅបំផុតចំពោះសម្តេចតេជោ **ហ៊ុន សែន** ដែលត្រូវបានជាប់ឆ្នោតសារជាថ្មីដឹកនាំរាជរដ្ឋាភិបាលកម្ពុជាក្នុងអាណត្តិទី ៥ បន្ទាប់ពីការបោះឆ្នោតដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ កាលពីថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០១៣។ ឯកឧត្តម **ចន ឃី** បានប្តេជ្ញាបន្តធ្វើទំនាក់ទំនង និងសហប្រតិបត្តិការល្អជាមួយសម្តេចតេជោ **ហ៊ុន សែន** និងរាជរដ្ឋាភិបាលកម្ពុជាក្នុងការជំរុញទំនាក់ទំនងកិច្ចសហប្រតិបត្តិការនៃប្រទេសទាំងពីរឈានដល់ចំណុចកំពូលថ្មីមួយទៀត។ សម្តេចតេជោ **ហ៊ុន សែន** បានថ្លែងអំណរគុណចំពោះរដ្ឋាភិបាលនូវែលហ្សេឡង់ ដែលបានបន្តជួយគាំទ្រយ៉ាងពេញទំហឹងដល់ដំណើរការសន្តិភាព និងការអភិវឌ្ឍប្រទេសកម្ពុជាឡើងវិញ ពិសេសការផ្តល់អាហារូបករណ៍ដល់និស្សិតកម្ពុជាដែលបានបន្តការសិក្សានៅចក្រភពអង់គ្លេស និងនូវែលហ្សេឡង់ និងបានស្នើសុំបន្តជួយដល់ដំណើរការរបស់សាលាក្តីកាត់ទោសមេដឹកនាំខ្មែរក្រហម ជួយគាំទ្រដល់មជ្ឈមណ្ឌលកំចាត់មីននៅកម្ពុជា។ ឯកឧត្តម **ចន ឃី** បានស្វាគមន៍ចំពោះសំណើទាំងឡាយរបស់សម្តេចតេជោ **ហ៊ុន សែន** ដោយសន្យាឆ្លើយតបឱ្យបានទាន់ពេលវេលាដើម្បីរួមចំណែកដល់ការអភិវឌ្ឍប្រទេសកម្ពុជាឱ្យកាន់តែរីកចម្រើនថែមទៀត។/

# ឯកឧត្តម ទេព ងន ចុះសួរសុខទុក្ខ និងផ្តល់អំណោយជូនប្រជាពលរដ្ឋរងគ្រោះ ដោយទឹកជំនន់ នៅខេត្តកណ្តាល ព្រៃវែង និងខេត្តបាត់ដំបង





*ឯកឧត្តម **ទេព ងន** ផ្តល់អំណោយជូនប្រជាពលរដ្ឋរងគ្រោះដោយទឹកជំនន់ ចំនួន ៥៧៦ គ្រួសារ នៅខេត្តកណ្តាល ខេត្តព្រៃវែង និងខេត្តបាត់ដំបង*

នៅក្នុងខែតុលា ឆ្នាំ ២០១៣ ឯកឧត្តម **ទេព ងន** សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា អនុប្រធានទី២ ព្រឹទ្ធសភា រួមដំណើរដោយឯកឧត្តម លោកជំទាវជាសមាជិក សមាជិកាព្រឹទ្ធសភា រដ្ឋសភា ទីប្រឹក្សា ថ្នាក់ដឹកនាំ និងមន្ត្រី រាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានអញ្ជើញចុះជួបសំណេះសំណាលសួរសុខទុក្ខ និងផ្តល់អំណោយជូនប្រជាពលរដ្ឋរងគ្រោះដោយទឹកជំនន់ចំនួន ៥៧៦ គ្រួសារ នៅខេត្តកណ្តាល ខេត្តព្រៃវែង និងខេត្តបាត់ដំបង ដោយក្នុង ១ គ្រួសារ ទទួលបានអង្ករ ២០ គីឡូក្រាម មី ១ កេស តង់កៅស៊ូ ១ ត្រីខកំប៉ុង ២ យួរ ទឹកត្រី ១ យួរ ទឹកស៊ីអ៊ីវ ១ យួរ ឆៃប៉ូវផ្អែម ១ គីឡូក្រាម សារុង ១ និងថវិកា ៥០ ០០០ រៀល ។

មានប្រសាសន៍ក្នុងឱកាសនោះ ឯកឧត្តម **ទេព ងន** បានចូលរួមរំលែកទុក្ខបងប្អូនប្រជាពលរដ្ឋទាំងអស់ដែលបានជួបប្រទះគ្រោះទឹក ជំនន់នាពេលនេះ និងបានពាំនាំនូវការសាកសួរសុខទុក្ខពីសំណាក់សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** និងសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ដែលតែងតែយកចិត្តទុកដាក់អំពីការលំបាករបស់ប្រជាពលរដ្ឋគ្រប់ពេលវេលា មិនថាប្រជាពលរដ្ឋមាននិន្នាការនយោបាយគាំទ្រគណបក្សណាក៏ដោយ ក៏សម្តេចទាំងបីនៅតែគិតគូរជួយដោះស្រាយការលំបាកក្នុងនាមជាប្រជាពលរដ្ឋខ្មែរតែមួយ ។ ទុក្ខលំបាករបស់បងប្អូនប្រជាពលរដ្ឋ គឺជាទុក្ខលំបាករបស់សម្តេចទាំងបី និងរូបឯកឧត្តមផ្ទាល់ ព្រោះសម្តេចទាំងបី និងរូបឯកឧត្តមគឺសុទ្ធតែមានកំណើតជាកូនកសិករដែលធ្លាប់ឆ្លងកាត់ការលំបាកគ្រប់បែបយ៉ាង ។អំណោយចែកជូនបងប្អូនប្រជាពលរដ្ឋនាពេលនេះ ទោះបីមិនអាចបំពេញតម្រូវការរបស់បងប្អូនបានគ្រប់គ្រាន់ និងមិនអាចប្រៀបធៀបជាមួយការខូចខាតរបស់បងប្អូនក៏ដោយ តែក៏បានជួយសម្រាលការលំបាករបស់បងប្អូនមួយកម្រិត ជាពិសេសបង្ហាញឱ្យឃើញពីការយកចិត្តទុក្ខដាក់របស់គណបក្សប្រជាជនកម្ពុជាចំពោះបងប្អូន ទោះបីតំបន់ខ្លះដែលបងប្អូនរស់នៅគណបក្សទទួលបានសំឡេងឆ្នោតគាំទ្រតិចជាងបក្សប្រឆាំងក៏ដោយ ។ បច្ចុប្បន្នប្រទេសកម្ពុជាកំពុងទទួលរងគ្រោះដោយសារទឹកជំនន់គ្រប់ទីកន្លែង បែរជាគណបក្សប្រឆាំងមិនបានចូលរួមជាមួយរាជរដ្ឋាភិបាលក្នុងការជួយសង្គ្រោះប្រជាពលរដ្ឋរងគ្រោះទេ គិតតែពីប្រមូលប្រជាពលរដ្ឋទៅធ្វើមហាបាតុកម្ម បង្កអស្ថិរភាពសង្គម និងធ្វើឱ្យប៉ះពាល់ដល់ជីវភាពរស់របស់ប្រជាពលរដ្ឋទៅវិញ ។សួរថាមហាបាតុកម្មរបស់គណបក្សប្រឆាំងកន្លងមកបានជាប្រយោជន៍អ្វីខ្លះដល់សង្គមជាតិ និងប្រជាពលរដ្ឋ ។

ឯកឧត្តម ក៏បានណែនាំឱ្យអាជ្ញាធរមូលដ្ឋានទាំងអស់ត្រូវចុះជាប់ជានិច្ច និងក្តាប់ឱ្យបានពីស្ថានភាពទឹកជំនន់ ដើម្បីធ្វើយ៉ាងណារក្សាឱ្យបាននូវសុវត្ថិភាពជូនបងប្អូនប្រជាពលរដ្ឋ ហើយនៅពេលទឹកស្រកវិញត្រូវស្វែករកទីតាំងថ្មី និងមានសុវត្ថិភាពជូនប្រជាពលរដ្ឋដែលរងគ្រោះ និងជួយជួសជុលផ្ទះព្រមទាំងឧបត្ថម្ភសម្ភារៈដល់ប្រជាពលរដ្ឋរងគ្រោះខូចខាតផ្ទះសម្បែង ។/

# សកម្មភាពសមាជិកព្រឹទ្ធសភា_រដ្ឋសភា_រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស



ថ្ងៃទី ១៩ ខែតុលា ឆ្នាំ ២០១៣ ឯកឧត្តម **ខួន ញឹល** សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា អនុប្រធានទី ១ រដ្ឋសភា អ្នកតំណាងរាស្ត្រមណ្ឌលកំពង់ធំ បានអញ្ជើញជួបសំណេះសំណាលសួរសុខទុក្ខ ព្រមទាំងនាំយកអំណោយរបស់រដ្ឋសភាឧបត្ថម្ភជូនប្រជាជនរងគ្រោះដោយទឹកជំនន់ចំនួន ១១៧៤ គ្រួសារ នៅស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ ដែលក្នុង ១ គ្រួសារៗទទួលបានអង្ករ ២៥ គីឡូក្រាម មី ១ កេស និងទឹកត្រី ១ យួរ ឧបត្ថម្ភថវិកាដល់សាលាស្រុកប្រាសាទសំបូរចំនួន ២ លានរៀល ជូនក្រុមកាយរិទ្ធ និងយុវជនកាកបាទក្រហមខេត្តចំនួន ៩១ ម៉ឺនរៀល ។ ជាមួយគ្នានោះដែរ ឯកឧត្តមបណ្ឌិត **ខួន ញឹល** បានឧបត្ថម្ភថវិកាផ្ទាល់របស់ឯកឧត្តមជូនដល់សាលាខេត្តកំពង់ធំចំនួន ៥០០០ ដុល្លារអាមេរិក សម្រាប់ខេត្តចាត់ចែងប្រើប្រាស់ក្នុងកិច្ចការជួយប្រជាជនរងគ្រោះដោយទឹកជំនន់ និងផ្ដល់ជូនដល់ស្ត្រីរងគ្រោះដោយសារប្ដីលង់ទឹក ស្លាប់ក្នុងទឹកជំនន់ស្ទឹងសែន ១ គ្រួសារ ចំនួន ៥០០ ដុល្លារអាមេរិកផងដែរ ។



*ក្នុងខែតុលាឆ្នាំ២០១៣នេះដែរឯកឧត្តម **ទៀ បាញ់** សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ បានអញ្ជើញជួបសំណេះសំណាលសួរសុខទុក្ខប្រជាពលរដ្ឋរងគ្រោះដោយទឹកជំនន់ និងពិនិត្យស្ថានភាពទឹកជំនន់នៅខេត្តសៀមរាប ។*



ថ្ងៃទី ១១ ខែតុលា ឆ្នាំ ២០១៣ លោកជំទាវ **ម៉ែន សំអន** សមាជិកាគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច អ្នកតំណាងរាស្ត្រមណ្ឌលស្វាយរៀង បានអញ្ជើញជួបសំណេះសំណាលសួរសុខទុក្ខ និងនាំយកអំណោយជារថយន្តសង្គ្រោះបន្ទាន់ ០១ គ្រឿង មានតម្លៃប្រមាណ ១ ម៉ឺនដុល្លារអាមេរិក ជាអំណោយរបស់ឯកឧត្តមឧកញ៉ាបណ្ឌិត **ជា រតនា** និងលោកជំទាវ **លី ហៀក រតនា** ជូនដល់មន្ទីរពេទ្យបង្អែកជីភូ ខេត្តស្វាយរៀង ដើម្បីបង្កលក្ខណៈងាយស្រួលដល់មន្ទីរពេទ្យក្នុងការបញ្ជូនអ្នកជំងឺសង្គ្រោះបន្ទាន់ទៅព្យាបាលនៅមន្ទីរពេទ្យរាជធានីភ្នំពេញ និងគោលដៅសេវាសុខាភិបាលឯទៀតៗ ។

*ថ្ងៃទី ១៧ ខែតុលា ឆ្នាំ ២០១៣ ឯកឧត្តម **កែ គឹមយ៉ាន** សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងលោកជំទាវ **ម៉ៅម៉ាល័យ កែ គឹមយ៉ាន** ព្រមទាំងមន្ត្រីថ្នាក់ដឹកនាំ បានអញ្ជើញនាំយកអំណោយផ្ដល់ជូនប្រជាពលរដ្ឋរងគ្រោះដោយទឹកជំនន់ចំនួន ១.៣៩៩ គ្រួសារ មកពីស្រុកអូរជ្រៅចំនួន ១.២០៩ គ្រួសារ និងក្រុងប៉ោយប៉ែត ១៩០ គ្រួសារ នៃខេត្តបន្ទាយមានជ័យ ។ ពិធីបានប្រារព្ធនៅវត្តកូនត្រី ភូមិកូនត្រី ឃុំកូប ស្រុកអូរជ្រៅ ។*



# សកម្មភាពសមាជិកព្រឹទ្ធសភា_រដ្ឋសភា_រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស

ថ្ងៃទី២០ខែតុលា ឆ្នាំ២០១៣ ឯកឧត្តម **អ៊ឹម ឈុនលឹម** សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ បានអញ្ជើញសួរសុខទុក្ខ និងនាំអំណោយទៅផ្តល់ជូនពលរដ្ឋរងគ្រោះដោយទឹកជំនន់ចំនួន ៤២១ គ្រួសារ មកពីឃុំចំនួនពីរក្នុងស្រុកសំបូរ ខេត្តក្រចេះ ។





*ថ្ងៃទី ២១ ខែតុលា ឆ្នាំ ២០១៣ ឯកឧត្តម **មិន ឃិន** សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា និងលោកជំទាវ ព្រមទាំងមន្ត្រីថ្នាក់ដឹកនាំក្រសួង និងសប្បុរសជនម្ចាស់អំណោយ បានអញ្ជើញនាំអំណោយទៅផ្តល់ជូនប្រជាជនរងគ្រោះដោយទឹកជំនន់ចំនួន៧៩០ គ្រួសារមកពីឃុំសូរគង ស្រុកកងមាស ខេត្តកំពង់-ចាម ។*



ថ្ងៃទី ១២ ខែតុលា ឆ្នាំ ២០១៣ ឯកឧត្តម **លឹម គានហោ** សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម និងសហការីបានអញ្ជើញចុះពិនិត្យស្ថានភាពទឹកជំនន់ និងពិនិត្យការទប់ទំនប់អាងទឹកកំពីងពួយស្ថិតក្នុងខេត្តបាត់ដំបង ដោយប្រើប្រាស់គ្រឿងចក្រជាច្រើនគ្រឿងរបស់ក្រសួងធនធានទឹក ។ ទំនប់ទឹកនេះបានផ្តាច់នូវផ្នែកខ្លះខណៈដែលទឹកជំនន់ជន់យ៉ាងគំហុកកាលពីពេលមុននេះ ។



*ថ្ងៃទី ១០ ខែតុលា ឆ្នាំ ២០១៣ ឯកឧត្តម **ម៉ម ប៊ុនហេង** សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងថ្នាក់ដឹកនាំក្រសួងសុខាភិ-បាល បានអញ្ជើញពិនិត្យស្ថានភាពសុខភាពប្រជាជនរងគ្រោះដោយទឹកជំនន់នៅស្រុកបវ-វេលខេត្តបាត់ដំបង ។ ឯកឧត្តមបានអប់រំប្រជាពលរដ្ឋអំពីអនាម័យ ពិសេសប្រសិនបើមានអ្នកជំងឺដោយមូសខាំ ឬពស់ចឹក ត្រូវរួសរាន់មករកគ្រូពេទ្យពិនិត្យ និងព្យាបាលជាបន្ទាន់ ។*



ថ្ងៃទី ១១ ខែតុលា ឆ្នាំ ២០១៣ ឯកឧត្តម **ស្រី បេន** សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា អភិបាលខេត្តតាកែវ បាននាំអំណោយកាកបាទក្រហមកម្ពុជាផ្តល់ជូនប្រជាពលរដ្ឋដែលមានជីវភាពក្រីក្រចំនួន ៧១៤ គ្រួសារ ក្នុងនោះ ២ គ្រួសារមានសមា-ជិកស្លាប់ដោយលង់ទឹកនៅឃុំគោកធ្លក ស្រុកអង្គរបូរី ខេត្តតាកែវ ។

# សកម្មភាពសមាជិកព្រឹទ្ធសភា_រដ្ឋសភា_រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស

*ថ្ងៃទី ១៣ ខែតុលា ឆ្នាំ ២០១៣ នៅបរិវេណសាលាបឋមសិក្សាតាឡំ ឃុំតាឡំ ឯកឧត្តម **អ៊ុង អឿន** សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា ប្រធានគណបក្សប្រជាជនកម្ពុជាខេត្តបន្ទាយមានជ័យ អ្នកតំណាងរាស្ត្រមណ្ឌលបន្ទាយមានជ័យ ព្រមទាំងសហការី បានអញ្ជើញជួបសំណេះសំណាលសួរសុខទុក្ខ និងនាំយកអំណោយផ្តល់ជូនពលរដ្ឋរងគ្រោះដោយទឹកជំនន់ចំនួន ២៣០ គ្រួសារ មកពីឃុំតាឡំ និងឃុំស្រះរាំង ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ។ អំណោយដែលផ្តល់ជូននាឱកាសនោះគឺទទួលបានពីមូលនិធិជនបទកម្ពុជា ។*





*ថ្ងៃទី ២០ ខែតុលា ឆ្នាំ ២០១៣ ឯកឧត្តម **នឹម ថូត** សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងជាប្រធានក្រុមការងារគណបក្សប្រជាជនកម្ពុជាចុះជួយស្រុកថ្មគោល ព្រមទាំងមន្ត្រីថ្នាក់ដឹកនាំក្រសួង និងមន្ត្រីអាជ្ញាធរជាច្រើនរូប បានអញ្ជើញជួបសំណេះសំណាលសួរសុខទុក្ខ និងនាំយកអំណោយរបស់ក្រសួងសង្គមកិច្ចផ្តល់ជូនពលរដ្ឋរងគ្រោះដោយទឹកជំនន់ចំនួន ៦០០ គ្រួសារ នៅភូមិវាលទ្រា ឃុំអូរតាគីស្រុកថ្មគោល ខេត្តបាត់ដំបង ។*



ថ្ងៃទី ៥ ខែតុលា ឆ្នាំ ២០១៣ ក្នុងបរិវេណសាលាបឋមសិក្សា **ហ៊ុន សែន** ជន្លាសដៃ ឯកឧត្តម **ហ៊ុន ម៉ានី** តំណាងរាស្ត្រមណ្ឌលកំពង់ស្ពឺ តំណាងដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាបតីតេជោ**ហ៊ុនសែន**នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជានិងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុនរ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជា ឯកឧត្តម **សៀង ណាំ** តំណាងរាស្ត្រមណ្ឌលសៀមរាប និងលោកជំទាវ ឯកឧត្តម **ស សុខា** តំណាងរាស្ត្រមណ្ឌលខេត្តព្រៃវែង បានអញ្ជើញជួបសំណេះសំណាលសួរសុខទុក្ខ ព្រមទាំងនាំអំណោយទៅផ្តល់ជូនពលរដ្ឋរងគ្រោះដោយទឹកជំនន់ចំនួន ១៨៦២ គ្រួសារ មកពីឃុំជន្លាសដៃ ស្រុកក្រឡាញ់ ខេត្តសៀមរាប ។



*ថ្ងៃទី ១៤ ខែតុលា ឆ្នាំ ២០១៣ ឯកឧត្តម **ឃឹម ប៊ុនសុង** អភិបាលខេត្តសៀមរាប ប្រធានកិត្តិយសសាខាកាកបាទក្រហមខេត្ត និងលោកជំទាវ បានអញ្ជើញសួរសុខទុក្ខ និងផ្តល់អំណោយដល់ប្រជាពលរដ្ឋរងគ្រោះដោយទឹកជំនន់ចំនួន ៥៣០ គ្រួសារមកពីភូមិវាល សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប ។*



ថ្ងៃទី ១១ ខែតុលា ឆ្នាំ ២០១៣ នៅក្នុងបរិវេណវត្តគីរីវន្ត ឯកឧត្តម **ឡូ ណារិន** អភិបាលខេត្តបន្ទាយមានជ័យ ប្រធានកិត្តិយសសាខាកាកបាទក្រហមខេត្ត ក្នុងនាមសម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុន សែន** ប្រធានកាកបាទក្រហមកម្ពុជា បានអញ្ជើញជួបសំណេះសំណាលសួរសុខទុក្ខ និងផ្តល់អំណោយដល់ប្រជាពលរដ្ឋរងគ្រោះដោយទឹកជំនន់ចំនួន ២១២ គ្រួសារ មកពីឃុំរហាល ឃុំព្រះនេត្រព្រះ និងឃុំទានកាំ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ ។

# សកម្មភាពរបស់ក្រុមការងារយុវជនគណបក្ស





ថ្ងៃទី ២៦ ខែតុលា ឆ្នាំ ២០១៣ នាទីស្នាក់ការកណ្តាល មានរៀបចំការផ្សព្វផ្សាយសភាពការណ៍នយោបាយមុន និងក្រោយការបោះឆ្នោត សភាព-ការណ៍ពាក់ព័ន្ធកម្ពុជា ជូនដល់ថ្នាក់ដឹកនាំក្រុមការ-ងារ និងសកម្មជនយុវជនគណបក្សរាជធានី-ខេត្ត ក្រសួង-ស្ថាប័ន រយៈពេល ១ ព្រឹក ដែលមានអ្នកចូលរួមជាង ៩០០ នាក់។ ឯកឧត្តម **ឱម យ៉ិនទៀង** សមាជិកគណៈកម្មាធិការកណ្តាលគណបក្ស និងឯកឧត្តម **សក់ សេដ្ឋា** សមាជិកគណៈកម្មាធិការកណ្តាលគណបក្ស បានធ្វើបទបង្ហាញជូនអង្គប្រជុំអំពីការងារបោះឆ្នោត និងសភាព-ការណ៍ក្នុងតំបន់ទាក់ទងនឹងកម្ពុជា ។ ចូលរួមក្នុងឱកាសនោះ ឯកឧត្តម **ហ៊ុន ម៉ានី** ឯកឧត្តម **សាយ សំអាល់** និងឯកឧត្តម **កែ ប៊ុនខៀង** ប្រធានក្រុមការងារយុវជនគណបក្សថ្នាក់កណ្តាល។





ថ្ងៃទី ២៣ ខែតុលា ឆ្នាំ ២០១៣ ប្រតិភូក្រុមការងារយុវជនគណបក្សថ្នាក់កណ្តាល ដឹកនាំដោយឯកឧត្តម **កែ ប៊ុនខៀង** បានជួបពិភាក្សាការងារជាមួយគណៈប្រតិភូរបស់សមាគមចិនសម្រាប់ការយល់ដឹងអន្តរជាតិ (CAFIU) ដឹកនាំដោយលោក **នី ជីង** (Ni Jian) អគ្គលេខាធិការសមាគម នៅស្នាក់ការកណ្តាលគណបក្ស នាវេលាម៉ោង ៩,១៥ នាទី។





កាលថ្ងៃទី ១៥ ខែតុលា ឆ្នាំ ២០១៣ ឯកឧត្តមបណ្ឌិត **ជាម ច័ន្ទសោភ័ណ** ប្រធានក្រុមការងារយុវ-ជនគណបក្សប្រជាជនកម្ពុជាខេត្តបាត់ដំបង ព្រមទាំងសមាជិក សមាជិកា បានចុះសួរសុខទុក្ខ និងបាននាំយកអំណោយមួយចំនួនទៅចែកជូនដល់បងប្អូនប្រជាពលរដ្ឋដែលរងគ្រោះដោយសារទឹកជំនន់ក្នុងឃុំអូរសិរិល ស្រុកសំឡូតចំនួន ៨០ គ្រួសារ សរុប ១៨៥ គ្រួសារ។





យោងមតិណែនាំឯកឧត្តមគណៈប្រចាំការគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល ក្រុមការងារយុវជនគណបក្សថ្នាក់កណ្តាលបានសម្រេចចាត់តាំងតំណាងយុវជនគណបក្ស ០២ រូប គឺឯក-ឧត្តម **ពៅ ប៉ូលីណែល** សមាជិកក្រុមការងារយុវជនគណបក្សថ្នាក់កណ្តាល លោក ទូន យ៉ាត ប្រធានក្រុមសកម្មជនយុវជនគណបក្សស្ថាប័នជុំវិញគណៈកម្មាធិការកណ្តាល បានអញ្ជើញចូលរួមក្នុងកម្មវិធីកិច្ចប្រជុំពិភាក្សាស្តីពី "រដ្ឋធម្មនុញ្ញកម្ពុជា និងការអនុវត្តបន្ត" រៀបចំដោយមូលនិធិខុនរ៉ាដអាដិនណៅអ៊ែរ ពីថ្ងៃទី ១១ ដល់ ១៣ ខែតុលា ឆ្នាំ ២០១៣ នៅខេត្តព្រះសីហនុ។

# លទ្ធផលមួយចំនួននៃវិស័យសេដ្ឋកិច្ច

### ចំណូលពន្ធដារខែកញ្ញា និង ៩ ខែនៃឆ្នាំ ២០១៣ :

អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានបញ្ជាក់ថា នៅក្នុងខែកញ្ញា ឆ្នាំ ២០១៣កន្លងទៅនេះពន្ធដារប្រមូលចំណូលពន្ធបង់ចូលថវិការដ្ឋចំនួន២៨៦,៩ពាន់លានរៀល ឬប្រមាណ ៧១,៨ លានដុល្លារអាមេរិក ។ ចំនួននេះគឺច្រើនជាងចំណូលពន្ធដារដែលប្រមូលបាននាខែសីហាកន្លងទៅប្រមាណ ៩៩២៩ លានរៀល ឬប្រមាណ ២,៤ លានដុល្លារ ។ ចំណូលពន្ធដារក្នុងខែកញ្ញានេះ បើប្រៀបធៀបនឹងចំណូលពន្ធដារខែកញ្ញា ឆ្នាំ ២០១២ មានការកើនឡើងប្រមាណ ២១,២% ។

សរុបរយៈពេល ៩ ខែនៃឆ្នាំ ២០១៣ ពន្ធដារប្រមូលបានចំនួន ២ ៧១២,២៣ លានរៀល ឬប្រមាណ ៦៧៨ លានដុល្លារ ស្មើនឹង ៧៨,៣% នៃគោលដៅកំណត់ក្នុងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០១៣ ។ បើប្រៀបធៀបនឹងរយៈពេល ៩ ខែដូចគ្នានាឆ្នាំ ២០១២ ឃើញថាប្រាក់ចំណូលដែលសម្រេចបាននៅឆ្នាំនេះមានកំណើន ១៦,១% ។ ក្នុងនោះថវិការដ្ឋសម្រេចបាន ៧៥,៩% និងថវិការាជធានី ខេត្តសម្រេចបាន ៩៦,៤% ។

តាមការវិភាគប្រភេទពន្ធឃើញថា ចំណូលពន្ធក្នុងឆ្នាំ ២០១៣ មានការកើនឡើងគ្រប់ប្រភេទពន្ធ ក្នុងនោះ ប្រភេទពន្ធសំខាន់ៗដែលមានការកើនឡើងដូចជា ពន្ធលើប្រាក់បៀវត្សមានការកើនឡើងប្រមាណ ២៤,៤% ពន្ធលើប្រាក់ចំណេញកើនឡើងប្រមាណ ១៩,៥% អាករលើតម្លៃបន្ថែមកើនឡើងប្រមាណ ១៨% និងអាករពិសេស កើនឡើងប្រមាណ ១៦% ។

ការពិនិត្យតាមវិស័យឃើញថា ចំណូលក្នុងឆ្នាំ២០១៣ មានការកើនឡើងស្ទើរគ្រប់សកម្មភាពក្នុងនោះ ផ្នែកផលិតភេសជ្ជៈកើនឡើងប្រមាណ ២១,៩% ផ្នែកសេវាហិរញ្ញវត្ថុកើនឡើងប្រមាណ ២៧,៥% ផ្នែកទូរគមនាគមន៍កើនឡើងប្រមាណ ១៨,៦% ផ្នែកផលិតគ្រឿងប្រើ-ប្រាស់កើនឡើងប្រមាណ ៣៤,៦% ស្ថាបត្យកម្ម និងសំណង់កើនឡើងប្រមាណ ២២,១% ផ្នែកនីហរ័ណអាហរ័ណកើនឡើងប្រមាណ ២៤,២% ផ្នែកផលិតសម្លៀកបំពាក់កើនឡើងប្រមាណ ៤៤,៦% ផ្នែកដឹកជញ្ជូន និងទេសចរណ៍កើនឡីងប្រមាណ ៣៤,៨% អាកាសយានដ្ឋាន និងកំពង់ផែកើនឡើងប្រមាណ ៧៣,៧% សណ្ឋាគារ និងផ្ទះសំណាក់កើនឡើងប្រមាណ ២២,៦% លក់គ្រឿងយន្ត កើនឡើង ២២៤% ផលិតម្ហូបអាហារកើនឡើង ៤៩,២% និងផ្នែកផលិតគ្រឿងអេឡិចទ្រិច និងអេឡិចត្រូនិច កើនឡើង ៤២,៧% ។

### ព្យាករណ៍ពាណិជ្ជកម្មរបស់កម្ពុជាឆ្នាំ២០១៣ :

យោងតាមរបាយការណ៍ធនាគារពិភពលោកចេញផ្សាយកាលពីថ្ងៃទី ៧ ខែតុលា បានធ្វើការព្យាករណ៍ថា ពាណិជ្ជកម្មកម្ពុជានៅឆ្នាំ ២០១៣ នេះនឹងមានតម្លៃរហូតដល់ទៅជិត១៦ ពាន់លានដុល្លាអាមេរិក ។ សម្រាប់តម្លៃនៃការធ្វើពាណិជ្ជកម្មរបស់កម្ពុជាជាមួយនឹងប្រទេសដៃគូ គឺមានតម្លៃប្រមាណ ១៥,៩ ពាន់លានដុល្លារ ។ តម្លៃនៃការនាំចេញរបស់កម្ពុជានៅក្នុងឆ្នាំ ២០១៣ នេះ នឹងមានតម្លៃប្រមាណ ៦,៩ ពាន់លានដុល្លារ រីឯការនាំចូលវិញមានតម្លៃប្រមាណ ៩ ពាន់លានដុល្លារអាមេរិក ។ ឱនភាពពាណិជ្ជកម្មរវាងការនាំចេញ និងនាំចូលមានតម្លៃប្រមាណ២,០៨ពាន់លានដុល្លារ ។ ធនាគារពិភពលោកបានព្យាករណ៍ទៀតថាសម្រាប់ឆ្នាំ ២០១៤ ខាងមុខ ពាណិជ្ជកម្មកម្ពុជានឹងមានតម្លៃប្រមាណ ១៨ ពាន់លានដុល្លារ នៅក្នុងនោះការនាំចេញនឹងមានតម្លៃប្រមាណ ៧,៧ ពាន់លានដុល្លារ រីឯកានាំចូលវិញមានតម្លៃប្រមាណ ១០,៣ ពាន់លានដុល្លារ ។ គួររំឭកដែរថា រយៈពេល ៨ខែនៃឆ្នាំ២០១៣ នេះ ក្រសួងពាណិជ្ជកម្មកម្ពុជាបានអះអាងថា សរុបទំហំពាណិជ្ជកម្មនៅកម្ពុជាមានតម្លៃ ១០,៤៥ ពាន់លានដុល្លារ កើនលើសពីរយៈពេលដដែលកាលពីឆ្នាំទៅ ២០% ក្នុងនោះ ការនាំចេញរបស់កម្ពុជាក្នុងរង្វង់ ៨ ខែនៃឆ្នាំ ២០១៣ មានការកើនឡើង ២៧% នៅក្នុងទឹកប្រាក់នាំចេញសរុបប្រមាណ ៤,៥២ ពាន់លានដុល្លារ ។ ចំណែកការនាំចូលមានទំហំទឹកប្រាក់ ៥,៩៣ពាន់លានដុល្លារ គឺកើន ១៥% ។

### ពាណិជ្ជកម្មកម្ពុជា-ជប៉ុនរយៈពេល ៨ ខែ

អង្គការពាណិជ្ជកម្មក្រៅប្រទេសជប៉ុនបានឱ្យដឹងថា នៅក្នុងរង្វង់ ៨ ខែនៃឆ្នាំ ២០១៣ នេះ ពាណិជ្ជកម្មរវាងប្រទេសកម្ពុជា និងជប៉ុន មានទំហំទឹកប្រាក់ស្មើនឹង ៥០៣ លានដុល្លារអាមេរិក គឺកើន ២៤% បើធៀបនឹងតួលេខរយៈពេលដូចគ្នាកាលពីឆ្នាំ ២០១២ ។

ទំហំទឹកប្រាក់ដែលកម្ពុជានាំចេញទៅជប៉ុនពីខែមករា ដល់ខែសីហា មានចំនួន ៣៥៨ លានដុល្លារ គឺកើនឡើងប្រមាណ ៣៩% ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំ ២០១២ ។ ទំនិញដែលកម្ពុជានាំចេញ រួមមានផលិតផលពីឧស្សាហកម្មកាត់ដេរសម្លៀកបំពាក់ និងស្បែកជើង ។ ក្រៅពីនោះមានដូចជា គ្រឿងសមុទ្រ ម្រេច ។

សម្រាប់ទំហំនៃការនាំចេញរបស់ជប៉ុនមកកាន់ទីផ្សារកម្ពុជាវិញមានតម្លៃ ១៤៥ លាន-ដុល្លារ គឺ កើន ២% ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំ ២០១២ ។ ផលិតផលដែលជប៉ុននាំចូលមកកម្ពុជា រួមមានយានយន្ត ម៉ូតូ ផលិតផលអេឡិត្រូនិក និងគ្រឿងម៉ាស៊ីន ។

គិតមកដល់ពេលនេះ ជប៉ុនគឺជាប្រទេសដែលផ្ដល់ជំនួយឥតសំណងធំជាងគេបំផុតសម្រាប់ការអភិវឌ្ឍនៅក្នុងប្រទេសកម្ពុជា ប៉ុន្តែពាណិជ្ជកម្មគឺនៅមានទំហំតូចនៅឡើយ បើធៀបនឹងប្រទេសផ្សេងៗដូចជា អាមេរិក សហគមន៍អឺរ៉ុប ថៃ និងវៀតណាម ។ កាលពីឆ្នាំ ២០១២ទំហំពាណិជ្ជកម្មរវាងកម្ពុជានិងជប៉ុនគឺមានតម្លៃ ត្រឹមតែ៦៤១លានដុល្លារតែប៉ុណ្ណោះ ខណៈដែលជាមួយនឹងអាមេរិក ២,៩ ពាន់លានដុល្លារ ។

### ការនាំចេញអង្កររយៈពេល ៩ ខែនៃឆ្នាំ ២០១៣ :

សហព័ន្ធអ្នកនាំអង្ករចេញកម្ពុជាបានអះអាងថា តាមតួលេខនៅក្នុងរង្វង់ពីខែមករា ដល់ខែកញ្ញា ឆ្នាំ ២០១៣ នេះ ការនាំចេញអង្កររបស់កម្ពុជាមានបរិមាណ ២៦៦ ១២០ តោន គឺកើនឡើង ១០៦% បើធៀបនឹងរយៈពេលដូចគ្នានាឆ្នាំ ២០១២ ដែលមានបរិមាណត្រឹមតែ ១២៩ ២៣០ តោនប៉ុណ្ណោះ ។

តាមការរំពឹងទុកនៅក្នុងឆ្នាំ ២០១៣ នេះ បរិមាណនៃការនាំចេញអង្ករកម្ពុជាទៅកាន់ទីផ្សារអន្តរជាតិនឹងអាចមានបរិមាណប្រមាណ ៤០០ ០០០ តោន ។

ចំណែកតម្លៃនៃការនាំចេញអង្ករកម្ពុជានាត្រីមាសចុងក្រោយនេះ មានការថយចុះប្រមាណ ៥% ។ កាលពីដើមឆ្នាំអង្ករកម្ពុជាដែលនាំចេញមានតម្លៃប្រមាណ ៩៥០ ដុល្លារនៅក្នុងមួយតោន តែមកដល់ត្រីមាសទីបីនេះមានតម្លៃត្រឹមប្រមាណ ៩០០ ដុល្លារនៅក្នុងមួយតោន ។

គិតមកដល់ពេលនេះកម្ពុជាមានក្រុមហ៊ុនដែលមានលទ្ធភាពនាំអង្ករចេញទៅក្រៅប្រទេសចំនួន ៧២ ក្រុមហ៊ុន ។ ក្រុមហ៊ុនទាំងនេះកំពុងតែនាំអង្ករកម្ពុជាចេញទៅកាន់ប្រទេសប្រមាណ ៥៧ ក្នុងនោះប្រទេសដែលទិញអង្ករកម្ពុជានៅក្នុងឆ្នាំ ២០១៣ ច្រើនជាងគេ គឺ ប៉ូឡូញ បារាំង ម៉ាឡេស៊ី ថៃ ហូឡង់ និងចិន ។

### អាកាសចរណ៍ស៊ីវិល :

រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលបានអះអាងថា ប្រទេសកម្ពុជាបានទទួលអ្នកដំណើរផ្លូវអាកាសចំនួន ៤,៣ លាននាក់ ក្នុងឆ្នាំ ២០១២ គឺកើនឡើង ១៤,៧% បើប្រៀបធៀបទៅនឹងឆ្នាំ ២០១១ មានអ្នកដំណើរផ្លូវអាកាសចំនួន ៣,៦៦លាននាក់ ។ ដោយឡែកអ្នកដំណើរតាមផ្លូវអាកាសពីខែមករា ដល់ខែសីហា ឆ្នាំ ២០១៣ នេះ បានឡើងដល់ ៣,៣២ លាននាក់កើនឡើង១៥,៦% បើប្រៀបធៀបទៅនឹង២,៧លាននាក់សម្រាប់រយៈពេលដូចគ្នាក្នុងឆ្នាំ ២០១២ ។ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលបានបញ្ជាក់ទៀតថា ចំនួន ៥០% នៃភ្ញៀវទេសចរអន្តរជាតិមកកាន់ប្រទេសកម្ពុជាតាមផ្លូវអាកាស ។ ការហោះហើរបានឈានដល់ ៤៨ ៧៨៩ ជើង ក្នុងឆ្នាំ ២០១២ គឺបានកើនឡើង ៨,២% បើប្រៀបធៀបទៅនឹងឆ្នាំ ២០១១ មានជើងហោះហើរចំនួន ៤៤ ៧៨០ ជើង ។

### ទេសចរណ៍ ៨ ខែដើមឆ្នាំ ២០១៣ :

ទេសចរអន្តរជាតិមកទស្សនាកម្ពុជាក្នុងខែសីហា ឆ្នាំ ២០១៣ មានចំនួន ៣៤២ ០៦៤ នាក់ កើនឡើង ១៦,៤% ធៀបនឹងខែកក្កដា ឆ្នាំ ២០១២ ។

ក្នុងរយៈពេល ៨ ខែដើមឆ្នាំ ២០១៣ នេះ មានចំនួន ២ ៧៧៣ ៤២៤ នាក់ កើនឡើង ១៨,៨% ធៀបនឹងរយៈពេលដូចគ្នា ឆ្នាំ ២០១២ ។ ទីផ្សារទេសចរណ៍សំខាន់ៗមកកម្ពុជា ក្នុងអំឡុងពេលនេះមាន វៀតណាម ៥៨៤ ៨៦២ នាក់ ចិន ៣០៥ ៥៤៩ នាក់ កូរ៉េ ២៩៦ ៤៩៧ នាក់ ឡាវ ២៦៣ ២៤៦ នាក់ ថៃ ១៤៧ ៩៥១ នាក់ ជប៉ុន ១៣២ ១២៥ នាក់ អាមេរិក ១២៣ ៤៩៤ នាក់ បារាំង ៨៨ ៨៣៩ នាក់ អង់គ្លេស ៨២ ៧៧៩ នាក់ ម៉ាឡេស៊ី ៨១ ១៨០ នាក់ ។

ដោយឡែកទេសចរកម្ពុជាចេញទៅក្រៅប្រទេស រយៈពេល ៨ ខែដើមឆ្នាំ ២០១៣ មានចំនួន ៥៧៨ ៤៧០ នាក់ កើនឡើង ១១,៣% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ ២០១២ ។/

# ឆ្នាំ ២០១៣ គម្រោងវិនិយោគបានកើនឡើងលើសឆ្នាំមុនជាង ២០០%

ឆ្នាំ២០១៣ នេះជាឆ្នាំមួយដែលគម្រោងវិនិយោគលើវិស័យវាយនភ័ណ្ឌ វិស័យកាត់ដេរ វិស័យឧស្សាហកម្ម សិប្បកម្ម និងជាពិសេសវិស័យសំណង់បានកើនឡើងគួរឱ្យកត់សម្គាល់ បើប្រៀបធៀបរយៈពេលដូចគ្នាកាលពីឆ្នាំ ២០១២។

តាមរបាយការណ៍ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានបង្ហាញថា គម្រោងវិនិយោគដែលបានអនុម័តនៅឆមាសទី ១ ឆ្នាំនេះបានកើនឡើងជាង ២០០% បើប្រៀបធៀបរយៈពេលដូចគ្នាកាលពីឆ្នាំ ២០១២ ក្នុងនោះ ទឹកប្រាក់វិនិយោគបានកើនឡើងពី ៦៩២ លានដុល្លាររហូតដល់ជាង ២,៣១ ពាន់លានដុល្លារ។ ទិន្នន័យបានបង្ហាញថា រាជរដ្ឋាភិបាលបានយល់ព្រមលើគម្រោងវិនិយោគ ៦៨ ក្នុងនោះវិស័យកាត់ដេរ និងវាយនភ័ណ្ឌមាន ៣៦ គម្រោង ដែលមានតម្លៃជាង ២០០ លានដុល្លារ និងវិស័យឧស្សាហកម្មផ្សេងទៀតមាន ៣២ គម្រោង ដែលក្នុងនោះគម្រោងវិនិយោគលើវិស័យសំណង់បានកើនឡើងជិត ២ ពាន់លានដុល្លារ។

អ្នកជំនាញខាងសេដ្ឋកិច្ចនៅកម្ពុជាបានឱ្យដឹងថា ក្នុងអំឡុងពេលនេះដែលមានការកើនឡើងខ្លាំងដូច្នេះ ដោយសារមានការផ្លាស់ប្ដូរនិន្នាការ ពីការវិនិយោគធុនតូច ទៅវិនិយោគធុនធំ និងដោយសារស្ថិរភាពសេដ្ឋកិច្ចនៅអាមេរិក និងសហភាពអឺរ៉ុបដែលជាទីផ្សារសម្រាប់ឧស្សាហកម្មនាំចេញដូចជាវិស័យកាត់ដេរ គឺកំពុងតែមានការទាក់ទាញពីកម្ពុជា។ម្យ៉ាងទៀតកម្ពុជាមានសក្ដានុពលដ៏ល្អក្នុងការទាក់ទាញឧស្សាហកម្មប្រើប្រាស់កម្លាំងពលកម្មច្រើនមិនគ្រាន់តែវិស័យកាត់ដេរ និងស្បែកជើងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផលិតផលគ្រឿងបន្លាស់ផងដែរ។ ការកើនឡើងមនុស្សថ្នាក់កណ្ដាលនៅកម្ពុជាកំពុងទាក់ទាញវិស័យសេវាកម្ម ក្រុមហ៊ុនលក់ទំនិញរាយ និងវិស័យគ្រឿងសម្អាង។ ដោយឡែកចំពោះគម្រោងវិនិយោគលើវិស័យសំណង់ គឺមានការកើនឡើងគួរឱ្យកត់សម្គាល់។ កាលពីខែកញ្ញា ឆ្នាំ២០១៣ កន្លងទៅនេះ ក្រុមហ៊ុន Hong Kong Land បានចាប់ផ្ដើមសាងសង់អគារមានកម្ពស់ ២០ជាន់ មានតម្លៃ ១០០ លានដុល្លារ ហើយក្រុមហ៊ុន Booyoung Group មានមូលដ្ឋាននៅកូរ៉េខាងត្បូងបានចាប់ផ្ដើមសាងសង់ទីក្រុងថ្មីមួយមានតម្លៃជាង ១,១ពាន់លានដុល្លារ នៅតាមមហាវិថីសហព័ន្ធរុស្ស៊ី ខាងលិចស្ពានអាកាស ៧មករា កាលពីខែមេសាកន្លងទៅនេះ។ ចំណែកក្រុមហ៊ុនវិនិយោគអាណិកជនខ្មែរនៅក្រៅប្រទេស OCIC នាពេលនេះ ក៏កំពុងត្រៀមរៀបចំសាងសង់អគារខុនដូដែលមានឈ្មោះ CASA MERIDIAN កម្ពស់ ៣០ជាន់ ចំនួន ២អគារបន្ថែមទៀតនៅលើទីក្រុងកោះពេជ្រនៅចុងឆ្នាំ ២០១៣នេះដែរ។ តាមគម្រោងការសាងសង់អគារខុនដូទាំងពីររបស់ OCIC នឹងត្រូវបញ្ចប់នៅចុងឆ្នាំ២០១៦ ខាងមុខ។ ទន្ទឹមនឹងការអភិវឌ្ឍនេះ ក្រុមហ៊ុន OCIC ក៏នឹងកសាងស្ពានមេអំបៅមួយទៀតដែលចេញពីផ្លូវក្រោយសណ្ឋាគារសូហ្វីតែលមកកាន់កោះពេជ្រផងដែរ។



*វិស័យសំណង់បាននិងកំពុងកើនឡើងគួរឱ្យកត់សម្គាល់*

ឯកឧត្តម **អ៊ឹម ឈុនលឹម** រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់បានមានប្រសាសន៍ថា សំណង់ជាវិស័យសេដ្ឋកិច្ចរួបវន្តមូលដ្ឋានដ៏សំខាន់មួយក្នុងការរួមចំណែកជំរុញកំណើនសេដ្ឋកិច្ចជាតិ។ ជាក់ស្ដែង ក្នុងឆ្នាំ ២០១២កន្លងមកនេះ ការបោះទុនវិនិយោគក្នុងវិស័យសំណង់អគារពីសំណាក់អ្នកវិនិយោគជាតិ និងអន្តរជាតិ មានតម្លៃប៉ាន់ស្មានសរុបជាងពីរពាន់លានដុល្លារអាមេរិក បើប្រៀបធៀបនឹងឆ្នាំ ២០១១ គឺមានការកើនឡើង ប្រមាណ ៧២%។ ដោយឡែកក្នុងឆមាសទី ១ ឆ្នាំ ២០១៣ គម្រោងវិនិយោគលើវិស័យសំណង់នៅតែមានការកើនឡើង គឺកើនឡើងប្រមាណ ១២៣% បើប្រៀបធៀបជាមួយនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១២។

ឯកឧត្តម **អ៊ឹម ឈុនលឹម** បានឱ្យដឹងទៀតថា តម្លៃនៃការវិនិយោគសំណង់បានកើនឡើងខ្លាំងក្នុងរយៈពេលប៉ុន្មានឆ្នាំនេះ គឺអាស្រ័យដោយកម្ពុជាយើងមានបរិយាកាសវិនិយោគល្អ និងសន្តិភាពពេញលេញសម្រាប់វិនិយោគិន។

គួរកត់សម្គាល់ផងដែរថា រហូតមកទល់ពេលនេះ មានក្រុមហ៊ុនធ្វើអាជីវកម្មសំណង់ដែលបានចុះបញ្ជីនៅក្រសួង ដែលមានសុពលភាពចំនួន ៥៧១ ក្រុមហ៊ុន ហើយក្រុមហ៊ុនទាំងនោះបានរួមចំណែកយ៉ាងសកម្មជាមួយអ្នកវិនិយោគឧស្សាហកម្មសំណង់ក្នុង និងក្រៅប្រទេស។

អ្នកជំនាញខាងសេដ្ឋកិច្ចនៅកម្ពុជាបានឱ្យដឹងទៀតថា កម្ពុជានៅតែទទួលបានលំហូរវិនិយោគទាំងក្នុង និងក្រៅប្រទេសយ៉ាងច្រើន ទោះបីឆ្នាំនេះមានការបោះឆ្នោតក៏ដោយ ព្រោះកម្ពុជាមានសក្ដានុពលដ៏ធំក្នុងការទាក់ទាញការវិនិយោគបានច្រើនមុនពេលការបោះឆ្នោត ជាពិសេសលើវិស័យកាត់ដេរ វិស័យសំណង់ និងវិស័យកសិកម្ម។ តាមការព្យាករណ៍របស់រាជរដ្ឋាភិបាលកម្ពុជាបានឱ្យដឹងថា ផលិតផលក្នុងស្រុកសរុបសម្រាប់មនុស្សម្នាក់ៗរបស់កម្ពុជានឹងកើនឡើងដល់ ១០៣៦ ដុល្លារ នៅឆ្នាំ ២០១៣ គឺមានការកើនឡើងពីជិត ១០០០ ដុល្លារ កាលពីឆ្នាំមុន។ ចំណែកវិស័យសេដ្ឋកិច្ចកម្ពុជាត្រូវបានគេរំពឹងថានឹងកើនឡើង ៧,៦% ឬប្រមាណជា ១៥,១៩ ពាន់លាន ដុល្លារ នៅឆ្នាំនេះ។/





*វិស័យកាត់ដេរសម្លៀកបំពាក់ និងកាត់ដេរស្បែកជើង កំពុងមានការទាក់ទាញពីកម្ពុជា*

# ការបង្កបង្កើនផលស្រូវវស្សាឆ្នាំនេះលឿនជាងឆ្នាំមុន តែត្រូវខូចខាតដោយទឹកជំនន់ ៤,៥ ម៉ឺនហិកតា

នារដូវវស្សាឆ្នាំ ២០១៣ នេះ ជាទូទៅភ្លៀងបានចាប់ផ្តើមធ្លាក់តាំងពីដើមរដូវ ដោយមានរបាយស្មើល្អនៅស្ទើរទូទាំងប្រទេស ។ ប្រការនេះបានផ្តល់អំណោយផលល្អដល់ការងារបង្កបង្កើនផលស្រូវ ជាពិសេសស្រូវបង្កើនរដូវ (ស្រូវស្រាលដើមរដូវវស្សា) ។

យោងរបាយការណ៍ដែលផ្តល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គិតត្រឹមសប្តាហ៍ទី ៣ នៃខែតុលា ឆ្នាំ ២០១៣ នេះ ការងារប្រមូលផលស្រូវស្រាលដើមរដូវវស្សាសម្រេចបានលើផ្ទៃដីចំនួន ២៣៨ ៦២៥ ហ.ត ដោយទទួលបានបរិមាណផលសរុប ៨៧៦ ៨១៨ តោន មានទិន្នផលមធ្យមចំនួន ៣,៦៧ តោន ក្នុង ១ ហ.ត ។

ចំពោះការដាំដុះស្រូវរដូវវស្សាក៏មានសន្ទុះលឿនគួរសមដែរ ថ្វីត្បិតតែជួបនឹងគ្រោះរាំងស្ងួត ក្នុងចន្លោះចាប់ពីខែកក្កដារហូតដល់ដើមខែកញ្ញា ដែលបង្កឱ្យប៉ះពាល់ដល់សំណាប សន្ទូង និងស្រូវពង្រោះយ៉ាងច្រើនក៏ដោយ ។ គិតត្រឹមសប្តាហ៍ទី ៣ នៃខែតុលា ឆ្នាំ ២០១៣ នេះ ទូទាំងប្រទេសសម្រេចស្ទូងព្រោះ បានចំនួន ២ ៥៦០ ៧០៣ ហ.ត ស្មើនឹង ១០៦,៧១% នៃផែនការ ២ ៣៩៩ ៦៣៧ ហ.ត ។ បើប្រៀបធៀបរយៈពេលដូចគ្នា ចំនួននេះគឺកើនលើសឆ្នាំមុន ៥៤ ៥៨៩ ហ.ត និងលើសមធ្យមភាគច្រើនឆ្នាំ ១៧០ ៩៤៩ ហ.ត ។

ចំពោះដំណាំរួមផ្សំបានអនុវត្តលើផ្ទៃដីចំនួន ៦៥៣ ០៨៩ ហ.ត ស្មើនឹង ១២១,២៦% នៃផែនការ ៥១៧ ២៦០ ហ.ត លើសឆ្នាំមុន ៣៩ ៣៥១ ហ.ត ដែលរួមមានដំណាំពោត ដំឡូងឈើ ដំឡូងជ្វា សណ្តែកបាយ និងបន្លែគ្រប់មុខ ។ ចំណែកឯដំណាំឧស្សាហកម្មបានអនុវត្តលើផ្ទៃដី ១៤៨ ៣៨២ ហ.ត ស្មើ ៩៦,០៨ នៃផែនការ ១៥៤ ៤២៩ ហ.ត លើសឆ្នាំមុន ២០ ៤៥១ ហ.ត ក្នុង នោះរួមមាន សណ្តែកដី សណ្តែកសៀង ល្ង អំពៅ ក្រចៅ និងថ្នាំជក់ ។

ប៉ុន្តែប្រការដែលគួរឱ្យសោកស្តាយគឺបាតុភូតគ្រោះធម្មជាតិ ជាពិសេសគ្រោះទឹកជំនន់ទឹកភ្លៀង និងជំនន់ទន្លេមេគង្គ បានធ្វើឱ្យផលដំណាំ ពិសេសដំណាំស្រូវនៅបណ្តាខេត្តចំនួន ១៨ ត្រូវរងផលប៉ះពាល់ និងខូតខាត ។ គិតត្រឹមសប្តាហ៍ទី ៣ នៃខែតុលា ឆ្នាំ ២០១៣ នេះ ទឹកជំនន់បានបង្កការប៉ះពាល់លើផ្ទៃដីសន្ទូង និងស្រូវពង្រោះចំនួន ៣០៩ ១៥៨ ហ.ត នៅបណ្តាខេត្ត ទាំង ១៨ ក្នុងនោះមានការខូចខាតចំនួន ៤៥ ២៤២ ហ.ត ។

ដើម្បីស្តារឡើងវិញនូវស្ថានភាពនេះ ធានាឱ្យបាននូវសន្តិសុខស្បៀង និងឈានទៅសម្រេចនូវគោលនយោបាយជំរុញផលិតកម្មស្រូវ និងការនាំចេញអង្កររបស់រាជរដ្ឋាភិបាល សំដៅជំរុញកំណើនសេដ្ឋកិច្ច និងកាត់បន្ថយគ្រោះមហន្តរាយលើអាយុជីវិត សុខភាព និងផលិតកម្មសត្វ ពិសេសកុំឱ្យកើតមានការផ្ទុះជំងឺឆ្លងរាលដាលសត្វនាពេលខាងមុខនេះ ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទបានដាក់ចេញនូវវិធានការចាំបាច់ និងបន្ទាន់មួយចំនួន ណែនាំដល់គ្រប់អង្គភាពបច្ចេកទេសក្រោមឱវាទ មន្ទីរកសិកម្មរាជធានី ខេត្ត ទាំងអស់ ។

វិធានការទាំងនោះមានដូចជា ត្រូវតាមដាននូវស្ថានភាពឧតុនិយម និងចាត់មន្ត្រីចុះចាត់វាយតម្លៃផលប៉ះពាល់ និងការខូចខាតជាបណ្តើរៗ ដើម្បីទទួលបានតួលេខខូចខាតពិតប្រាកដ ដោយក្តាប់ឱ្យបានទីតាំង និងស្ថានភាពភូមិសាស្ត្រដែលមានលទ្ធភាពអាចស្តារនូវការខូចខាតបាន ។ ពិនិត្យឡើងវិញនូវសន្និធិស្រូវពូជដែលមាននៅតាមបណ្តាខេត្តនីមួយៗទាំងបរិមាណ និងគុណភាព ហើយត្រៀមលក្ខណៈជាស្រេចសម្រាប់ការជួយអន្តរាគមន៍ស្តារការខូចខាតឡើងវិញនៅពេលខាងមុខតាមស្ថានភាពភូមិសាស្ត្រជាក់ស្តែង ។ សិក្សារកទីតាំង និងលទ្ធភាពរៀបចំធ្វើជាថ្នាលសំណាបរួម ជាពិសេសថ្នាលដាប៉ុកដើម្បីចែកជូនកសិករធ្វើការដកស្ទូងបានទាន់ពេលវេលានៅពេលទឹកជំនន់ចាប់ផ្តើមស្រក ។ ពិនិត្យលទ្ធភាព និងត្រៀមលក្ខណៈផ្តល់ពូជដំណាំផ្សេងទៀត (ដូចជា ឪឡឹក ពោត សណ្តែក បន្លែ ដំឡូង ជាដើម) ដែលត្រូវការទឹកតិច ។ ត្រូវជំរុញការណែនាំដល់កសិករឱ្យបង្កើនការថែទាំដំណាំស្រូវដែលមិនរងនូវការខូតខាត ។ នៅពេលទឹកចាប់ផ្តើមស្រក ត្រូវចលនាប្រមូលកម្លាំងប្រជាកសិកររួមគ្នាធ្វើការជួសជុល ឬលើកភ្លឺឡើងវិញ ដើម្បីរក្សាទឹកទុក ។ ពិនិត្យលទ្ធភាពជាក់ស្តែងនូវតំបន់ដែលមានប្រភពទឹកសម្រាប់ស្រោចស្រព ដើម្បីកំណត់ឱ្យបានច្បាស់ពីទីតាំង និងផ្ទៃដីដែលអាចធានាការស្រោចស្រព និងស្តារឡើងវិញ ។ ចុះអប់រំបណ្តុះបណ្តាលបច្ចេកទេសដាំដុះដល់ប្រជាកសិករ និងបំផុសជំរុញការអនុវត្តផលិតកម្មផ្សេងៗទៀត តាមស្ថានភាពជាក់ស្តែងក្នុងមូលដ្ឋាននីមួយៗ ដូចជាការចិញ្ចឹមសត្វ ការចិញ្ចឹមត្រី និងមុខរបរបង្កើនប្រាក់ចំណូលដទៃទៀត និងត្រូវបន្តតាមដានសុខភាពសត្វ ដើម្បីមានវិធានការទាន់ពេលវេលាក្នុងករណីដែលត្រូវការការជួយអន្តរាគមន៍ ។



*ដំណាំស្រូវរបស់ប្រជាកសិករកម្ពុជា*

យោងតាមរបាយការណ៍របស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយបានឱ្យដឹងថា គិតត្រឹមថ្ងៃទី ១៨ ខែតុលានេះ ទឹកជំនន់បានធ្វើឱ្យប៉ះពាល់ដល់រាជធានី ខេត្តចំនួន ២០ ប៉ះពាល់ ដល់ប្រជាពលរដ្ឋ ជាពិសេសគឺកសិករប្រមាណ ១,៥ លាននាក់ និងមានបនុស្សស្លាប់ ១៦៨ នាក់ និងបង្កឱ្យមានការខូចខាតនូវហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ផលដំណាំ ទ្រព្យសម្បត្តិរបស់ប្រជាជនយ៉ាងច្រើនក្រៃលែង ។

ស្ថានភាពគ្រោះទឹកជំនន់ឆ្នាំនេះត្រូវបានវាយតម្លៃថា មានស្ថានភាពធ្ងន់ធ្ងរប្រហាក់ប្រហែលនឹងគ្រោះទឹកជំនន់ឆ្នាំ ២០១១ ដែលបានសម្លាប់ជីវិតមនុស្សចំនួន ២៥០ នាក់ និងធ្វើឱ្យខូចខាតសេដ្ឋកិច្ចចំនួនជាង ៥០០ លានដុល្លារអាមេរិក ។/

# ទិន្នន័យប៉ះពាល់ និងខូចខាតដោយទឹកជំនន់ទឹកភ្លៀងលើកទី ២ និងជំនន់ទន្លេមេគង្គ
## (ទិន្នន័យរបស់ គ.ជ.គ.ម ថ្ងៃទី ១៨ ខែតុលា ឆ្នាំ២០១៣)

| ល.រ | រាជធានី-ខេត្ត | ស្រុក | ឃុំ | វិស័យសង្គមកិច្ច | | | | | | | | | វិស័យផលិតកម្ម | | | | | | | ហេដ្ឋារចនាសម្ព័ន្ធ | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ប្រជាជនប៉ះពាល់ (គ្រួសារ) | ប្រជាជនជម្លៀស (គ្រួសារ) | ប៉ះពាល់ផ្ទះ | ខូចខាតផ្ទះ (ខ្នង) | ប្រជាជនរងគ្រោះ | | ប៉ះពាល់ | | | សត្វពាហនៈ | | លិចសន្ទូង (ហត) | | សំណាប (ហត) | ប៉ះពាល់ដំណាំផ្សេងៗ (ហត) | | ផ្លូវជាតិ និងខេត្ត (ម) | | ផ្លូវលំ (ម) | | ស្ពានលិច (កន្លែង) | ប៉ះពាល់ទំនប់ (ខ) | បាក់ច្រាំងទន្លេ (ខ) |
| | | | | | | | | ស្លាប់ | របួស | សាលារៀន | វត្ត | ពេទ្យ | ជម្លៀស | ងាប់ | ប៉ះពាល់ | ខូចខាត | ខូចខាត | ប៉ះពាល់ | ខូចខាត | ប៉ះពាល់ | ខូចខាត | ប៉ះពាល់ | ខូចខាត | | | |
| 1 | ព្រះវិហារ | 8 | 33 | 4609 | 397 | 981 | 3 | 1 | | 9 | | | | | 5410 | 3104 | | 71 | 58 | 8205 | | 43390 | | 3 | | |
| 2 | កំពង់ធំ | 7 | 61 | 17463 | 1114 | 17463 | | 24 | 3 | 121 | 41 | 4 | 5753 | | 22932 | 1725 | | | 30 | 26015 | | 172673 | | | 1ក | |
| 3 | បន្ទាយមានជ័យ | 9 | 59 | 54463 | 8902 | 15027 | 3 | 9 | 1 | 249 | 128 | 21 | | | 52790 | 475 | | 14193 | 1858 | 78130 | | 1135473 | | | 13ក | |
| 4 | សៀមរាប | 10 | 60 | 19022 | 3550 | 3645 | 11 | 15 | 2 | 39 | 8 | 7 | | 17 | 14793 | 1890 | | | 680 | 30941 | | 160688 | | 7 | 4ក | |
| 5 | ឧត្ដរមានជ័យ | 5 | 22 | 13244 | | 3217 | 3 | 4 | | | | | | | 6956 | 784 | | | 2467 | 21900 | | 24340 | | 17 | 19ក | |
| 6 | កំពង់ចាម | 13 | 72 | 51376 | 3546 | 43759 | 36 | 29 | | 268 | 144 | 17 | 2398 | 7 | 10798 | 60 | 28 | 166 | | 11174 | | 338126 | | 4 | 43ក | 1 ក |
| 7 | ក្រចេះ | 5 | 35 | 18552 | 621 | 12447 | 2 | 5 | | 88 | 59 | 1 | 8724 | | 4610 | | 329 | 695 | | 35768 | | 166230 | | | 10ក | 1ក |
| 8 | ស្ទឹងត្រែង | 5 | 29 | 9813 | 1523 | 9385 | 2 | 3 | | 31 | 20 | 3 | | | 8070 | 5490 | | 1419 | 980 | 16500 | | 155179 | | 119 | | |
| 9 | ព្រៃវែង | 13 | 84 | 44764 | 866 | 32193 | 8 | 26 | | 155 | 53 | 8 | 8632 | | 55840 | 13647 | | | | 2748 | | 116900 | | 1 | | |
| 10 | កណ្ដាល | 9 | 65 | 35311 | 235 | 22327 | 31 | 15 | | 126 | 23 | 6 | 2231 | | 4854 | 873 | | 2125 | 2118 | 8892 | | 214803 | | 7 | 15ក | 1ក |
| 11 | កំពង់ឆ្នាំង | 6 | 26 | 6667 | 897 | 3591 | | 9 | | 2 | 38 | | 391 | | 2301 | 1104 | | | | 4110 | | 37000 | | | | |
| 12 | ភ្នំពេញ | 3 | 7 | 3522 | 1622 | | 4 | | | | | | | | | | | | | | | 1900 | | | | |
| 13 | រតនគិរី | 6 | 28 | 6524 | 2289 | | 13 | | | | | 2 | | | 4635 | 1984 | | 1929 | 1343 | 8940 | | 163969 | | 6 | | |
| 14 | បាត់ដំបង | 14 | 102 | 74160 | 4504 | 62451 | 166 | 17 | 4 | 77 | 14 | 9 | | 236 | 128723 | 27565 | | 40003 | 10631 | 152450 | | 819640 | | | | |
| 15 | ប៉ៃលិន | 2 | 8 | 1989 | 239 | 851 | | 3 | 1 | 17 | 2 | | | | 1160 | 753 | | 8536 | 5236 | 2249 | | 8290 | | 4 | 5ក | |
| 16 | ពោធិ៍សាត់ | 6 | 32 | 9271 | 746 | 1004 | 5 | 2 | 18 | 57 | | | 43409 | | 16318 | 3419 | | | | 21800 | | 82407 | | 15 | | |
| 17 | ស្វាយរៀង | 4 | 27 | 3808 | 253 | 347 | | 1 | | | 1 | | 1110 | 4 | 2021 | 5 | | 513 | | 3700 | | 6244 | | | 2ក | |
| 18 | តាកែវ | 5 | 18 | 2796 | 10 | 2796 | | 5 | | 3 | 2 | | | | 1804 | | | | | 6850 | | 46000 | | | 2ក | |
| 19 | មណ្ឌលគិរី | 1 | 1 | | | | | | | | | | | | 269 | | | | | | | | | | | |
| 20 | ព្រះសីហនុ | 1 | 1 | | | | | | | | | | | | | | | | | 200 | | | | | | |
| | សរុប | 132 | 770 | 377,354 | 31,314 | 231,484 | 287 | 168 | 29 | 1,242 | 533 | 78 | 72,648 | 264 | 344,284 | 62,878 | 357 | 69,650 | 25,401 | 440,572 | 0 | 3.693.252 | 0 | 183 | | |

# វិស័យធនាគារមានស្ថេរភាព និងមានកំណើនបន្តទៀត



*ធនាគារជាតិនៃកម្ពុជា*

បច្ចុប្បន្នស្ថានភាពម៉ាក្រូសេដ្ឋកិច្ចរបស់កម្ពុជាមានភាពល្អប្រសើរ ទោះបីជាអត្រាអតិផរណាបានកើនឡើងបន្តិចក្តី ។ប៉ុន្តែជាទូទៅអតិផរណាស្ថិតក្នុងកម្រិតទាបក្រោម ៣% ជាកម្រិតមួយដែលយើងអាចគ្រប់គ្រងបាន ។

រាជរដ្ឋាភិបាលកម្ពុជា ដែលមានសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ជានាយករដ្ឋមន្ត្រី បានអនុវត្តប្រកបដោយប្រសិទ្ធភាពនូវគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈដ៏ត្រឹមត្រូវ ជាមួយនឹងការជំរុញខ្លាំងការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ការលើកកម្ពស់សេវាសាធារណៈ និងការពង្រឹងអភិបាលកិច្ចល្អ ធ្វើឱ្យសេដ្ឋកិច្ច កម្ពុជា នឹងនៅតែបន្តមានកំណើនទៅមុខទៀត ។បើតាមការព្យាករណ៍កំណើននេះនឹងបន្តសម្រេចបានក្នុងរង្វង់ ៧% នៅឆ្នាំ២០១៤ ។

ឯកឧត្តម **ជា ចាន់តូ** ទេសាភិបាលធនាគារជាតិនៃកម្ពុជាបានអះអាងថា វិស័យធនាគារនៅកម្ពុជានឹងបន្តមានស្ថិរភាពជាមួយនឹងកំណើនសេដ្ឋកិច្ចកម្ពុជា ទោះបីជាមានសភាពតានតឹងនយោបាយរវាងគណបក្សប្រជាជនកម្ពុជានិងគណបក្សប្រឆាំងក៏ដោយ ។ឯកឧត្តមបានមានប្រសាសន៍កាលពីពេលថ្មីៗកន្លងទៅនេះ (ថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ ២០១៣) នៅក្នុងពិធីសម្ពោធបើកទីស្នាក់ការការិយាល័យនៃធនាគារ ហុងលីអុង(ដែលជាធនាគារមួយមកពីប្រទេសម៉ាឡេស៊ី) រាជធានីភ្នំពេញថា វិស័យធនាគារនៅកម្ពុជានៅតែបន្តទទួលកំណើនដោយសារតែការគាំទ្រពីអតិថិជន និងអ្នកវិនិយោគទុនបរទេស ។

តាមរបាយការណ៍ពីធនាគារជាតិកម្ពុជាបានប្រកាសឱ្យដឹងថា មកដល់ពេលបច្ចុប្បន្ននេះ កម្ពុជាមានធនាគារពាណិជ្ជចំនួន ៣៤ មានអ្នកខ្ចីលុយចំនួន ១,៦ លាននាក់ និងអ្នកដែលដាក់ប្រាក់បញ្ញើចំនួន ១,៩ លាននាក់ ។ គិតត្រឹមឆមាសទី ១ ដើមឆ្នាំ ២០១៣ នេះ ទំហំទឹកប្រាក់ឥណទានដែលធនាគារឱ្យអតិថិជនខ្ចីគឺមានចំនួន ៦,២ ពាន់លានដុល្លារ ពោលគឺកើនឡើង ៥,៤% បើប្រៀបធៀបនឹងទំហំប្រាក់កម្ចីរយៈពេលដូចគ្នាកាលពីឆ្នាំមុនមានត្រឹមតែ ៥,៨៨ ពាន់លានដុល្លារប៉ុណ្ណោះ ។

ប្រភពដដែលបានឱ្យដឹងទៀតថា សម្រាប់ប្រាក់បញ្ញើវិញក្នុងរយៈពេល ៦ ខែដើមឆ្នាំ ២០១៣ នេះ គឺមានចំនួន ៦,៧៥ ពាន់លានដុល្លារ ពោលគឺមានការកើនឡើងប្រមាណ ៩,៥% បើប្រៀបធៀបរយៈពេលដូចគ្នា កាលពីឆ្នាំ ២០១២ មានត្រឹមតែ ៦,១៦ ពាន់លានដុល្លារ ។

មន្ត្រីធនាគារជាតិកម្ពុជាបានរាយការណ៍ឱ្យដឹងថា ប្រាក់កម្ចីចំនួន ៣០% បានផ្តល់ទៅលើវិស័យពាណិជ្ជកម្មចំនួន ១៨% បានផ្តល់ទៅលើវិស័យកសិកម្មចំនួន ៩% ទៅលើវិស័យផលិតកម្មចំនួន ៧% ទៅលើវិស័យសំណង់ និងចំនួន ៦% ទៀត សម្រាប់បម្រើទៅលើវិស័យសណ្ឋាគារ និងភោជនីយដ្ឋាន ។ល ។

ដោយឡែកទុនបម្រុងអន្តរជាតិរបស់កម្ពុជា នៅក្នុងរយៈពេល ៦



*ទីស្នាក់ការការិយាល័យនៃធនាគារហុងលីអុង*
*ដែលទើបសម្ពោធបើកកាលពីថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ ២០១៣*



*ទីស្នាក់ការកណ្ដាលនៃធនាគារអេស៊ីលីដា ភីអិលស៊ី*

ខែដើម ឆ្នាំ ២០១៣ នេះ មានការកើនឡើងរហូតដល់ ៤ ០៤៦ លានដុល្លារ បើប្រៀបធៀបរយៈពេលដូចគ្នាកាលពីឆ្នាំ ២០១២ ទុនបម្រុងអន្តរជាតិរបស់កម្ពុជា បានកើនឡើងប្រមាណ ១៣,៤% ។ ឯកឧត្តម **ជា ចាន់តូ** ទេសាភិបាលធនាគារជាតិនៃកម្ពុជាបានមានប្រសាសន៍ឱ្យដឹងទៀតថា នៅក្នុងរយៈពេល ៦ ខែដើមឆ្នាំ ២០១៣ នេះ អត្រាប្តូរប្រាក់រៀល បើធៀបនឹងប្រាក់ដុល្លារ បានឡើងថ្លៃប្រមាណជា ០,៧% ហើយអតិផរណាវិញនោះ គឺកើនឡើងដល់ ២,៩% បើប្រៀបធៀបរយៈពេល ៦ ខែដើមឆ្នាំ ២០១២ ដែលមានត្រឹម ០១,៨% ។ ឯកឧត្តម **ជា ចាន់តូ** បានបញ្ជាក់ថា ជាទូទៅអតិផរណាស្ថិតនៅក្នុងកម្រិតទាបក្រោម ៣% គឺជាកម្រិតមួយដែលអាចនឹងគ្រប់គ្រងបាន ។

អ្នកវិភាគសេដ្ឋកិច្ចកម្ពុជាបានឱ្យដឹងថា មូលហេតុដែលជំរុញឱ្យ



*ទីស្នាក់ការកណ្ដាលនៃធនាគារកាណាឌីយ៉ា*



*ទីស្នាក់ការកណ្ដាលនៃធនាគារកម្ពុជាសាធារណៈ*

បណ្ដាធនាគារឯកជនបរទេសមកវិនិយោគនៅកម្ពុជា គឺមកពីកត្តាមួយចំនួនដូចជា ប្រទេសកម្ពុជាកំពុងស្ថិតលើផ្លូវរីកចម្រើនកំណើនសេដ្ឋកិច្ចល្អប្រសើរ កម្ពុជាមានស្ថិរភាពនយោបាយ ប្រទេសទាំងមូលមានសន្តិភាព ជាពិសេសបណ្ដាប្រទេសជាដៃគូអភិវឌ្ឍន៍មួយចំនួន មានការជឿទុកចិត្តលើសមត្ថភាព និងភាពស្មោះត្រង់របស់ភាគីកម្ពុជា ។ អ្នកវិភាគបានឱ្យដឹងទៀតថា ដោយសារការកើនឡើងនូវក្រុមហ៊ុនវិនិយោគបរទេស ដូចជា កូរ៉េខាងត្បូង ចិន វៀតណាម ជប៉ុន មកបណ្ដាក់ទុន ទើបធ្វើឱ្យម្ចាស់ក្រុមហ៊ុនផ្នែកប្រាក់កម្ចី និងផ្ទេរប្រាក់នៃប្រទេសទាំងនោះមួយចំនួនមកបណ្ដាក់ទុនរកស៊ី ដោយពួកគេសង្ឃឹម ថានឹងទទួលបានការចំណេញពីការខ្ចីប្រាក់ ឬផ្ទេរប្រាក់របស់វិនិយោគិនបរទេសទាំងនោះ ។

ជាក់ស្ដែងថ្មីៗនេះ ធនាគារមេបែង (MayBank)ដែលជាធនាគាររបស់ប្រទេសម៉ាឡេស៊ីមួយក្នុងចំណោមធនាគារម៉ាឡេស៊ីចំនួន៥ដែលកំពុងតែប្រតិបត្តិការនៅក្នុងព្រះរាជាណាចក្រកម្ពុជា គ្រោងនឹងបើកការិយាល័យសាខារបស់ខ្លួនចំនួន ៤ កន្លែងបន្ថែមទៀតនៅកម្ពុជានាពេលខាងមុខនេះ ។

ក្រុមអ្នកវិភាគសេដ្ឋកិច្ចបានអះអាងថា មានកត្តាសំខាន់ៗចំនួន ៤ ដែលត្រូវបានមើលឃើញថាជាកត្តាពន្លឿននៃកំណើនវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ទី ១ ដោយសារគោលនយោបាយគាំពារ និងលើកទឹកចិត្តរបស់រាជរដ្ឋាភិបាល ទី ២ ក្របខ័ណ្ឌបទប្បញ្ញត្តិ និងត្រួតពិនិត្យដោយត្រឹមត្រូវប្រុងប្រយ័ត្នរបស់ធនាគារជាតិនៃកម្ពុជា ទី ៣ ភាពរស់រវើក និងការច្នៃប្រឌិតរបស់ប្រតិបត្តិករហិរញ្ញវត្ថុ និងទី ៤ តម្រូវការ និងការគាំពាររបស់អតិថិជន ។/

# សហរដ្ឋអាមេរិកចេញផុតពីការក្ស័យធនឆ្នាំ ២០១៣ តែអាចជួបវិបត្តិនេះម្ដងទៀតនៅដើមឆ្នាំ ២០១៤



*វិមានរដ្ឋសភាអាមេរិកគ្របដណ្ដប់ដោយពពកខ្មៅងងឹត*

កាលពីថ្ងៃទី ១៦ ខែតុលា ភាពទាល់ច្រកនៃវិបត្តិកម្ពស់ពិដានបំណុលដែលនាំដល់ការបិទសេវាសាធារណៈមួយចំនួនរបស់សហរដ្ឋអាមេរិកអាស្រ័យ ដោយគណបក្សសាធារណរដ្ឋជាគណបក្សជំទាស់ និងជាគណបក្សដែលកាន់កាប់អាសនៈប្រធានសភាតំណាងនៃសហរដ្ឋអាមេរិក បានរារាំងមិនឱ្យចេញរួចនោះត្រូវបានដកចេញទៅវិញ គឺប៉ុន្មានម៉ោងប៉ុណ្ណោះ មុនប្រទេសមហាអំណាចសេដ្ឋកិច្ចយោធាមួយនេះត្រូវប្រកាសថាក្ស័យធន។ មូលហេតុនៃការមិនដំណើរការរដ្ឋាភិបាល (ឬបិទសេវាសាធារណៈ Government shut down) គឺដោយសារតែគណបក្សសាធារណរដ្ឋធ្វើការប្រឆាំងទៅនឹងកម្មវិធីសុខភាព អូបាម៉ា ដែលគេគិតថាមានការចំណាយច្រើនលើសលប់ពេក ហើយវាផ្ដល់ផលប្រយោជន៍តែទៅលើគណបក្សប្រជាធិបតេយ្យប៉ុណ្ណោះ។

អ្វីទៅជាការមិនដំណើរការរដ្ឋាភិបាល ? ការមិនដំណើរការរដ្ឋាភិបាលឬហៅថាការបិទដំណើរការរដ្ឋាភិបាលអាមេរិក វាកើតមានពេលណា "សេវា" មិនសំខាន់ទាំងអស់របស់រដ្ឋាភិបាលត្រូវបានផ្អាកដោយសារតែមិនចុះសម្រុងគ្នារវាងព្រឹទ្ធសភា និងសភា ស្ដីពីការចំណាយរបស់រដ្ឋាភិបាល។ នៅសហរដ្ឋអាមេរិកឆ្នាំសារពើពន្ធត្រូវបានគេគិតពីថ្ងៃទី ០១ ខែតុលា នៃឆ្នាំមួយ ទៅដល់ថ្ងៃ ៣០ ខែកញ្ញានៃឆ្នាំបន្ទាប់។ ជារៀងរាល់ឆ្នាំ រដ្ឋាភិបាលសហរដ្ឋអាមេរិកត្រូវតែឆ្លងច្បាប់ស្ដីពីការផ្ដល់ថវិកាឱ្យកម្មវិធីមួយចំនួនដើម្បីឱ្យកម្មវិធីទាំងនោះអាចបន្តសកម្មភាពបាន។ រដ្ឋាភិបាលសហព័ន្ធហើយក៏មានសភានិងព្រឹទ្ធសភាផងដែរ អាចនឹងមានការមិនចុះសម្រុងគ្នាស្ដីពី តើធ្វើយ៉ាងណាដើម្បីផ្ដល់ថវិកាឱ្យកម្មវិធីទាំងនោះនៅដំណាច់នៃឆ្នាំសារពើពន្ធនីមួយៗ។

ប្រការជាឫសគល់សំខាន់មួយនៃមូលហេតុនាំឱ្យមានការបិទសេវាសាធារណៈគឺពួកសាធារណរដ្ឋនិយមតាំងពីឆ្នាំ ២០១០ មកម្ល៉េះ បានប្រឹងប្រែងយកកម្មវិធីសុខភាព ដែលផ្ដើមគំនិត និងតាមគំនិតអូបាម៉ា (Obamacare) ចេញ តែការប្រឹងប្រែងនោះមិនបានជោគជ័យ។សភាសហរដ្ឋអាមេរិក ដែលមានសមាជិកសភាភាគច្រើនជាពួកសាធារណរដ្ឋនិយម បានស្នើឱ្យមាន ការកែប្រែមួយចំនួន សម្រាប់ច្បាប់ចំណាយថវិកាក្នុងឆ្នាំនេះ នាំឱ្យមានថវិកាមិនគ្រប់គ្រាន់ផ្គត់ផ្គង់ដល់ កម្មវិធីសុខភាពខាងលើ។ ព្រឹទ្ធសភាសហរដ្ឋអាមេរិក ដែលមានសមាជិកភាគច្រើនមកពីគណបក្សប្រជាធិបតេយ្យមិនព្រមទទួលយកការកែប្រែទាំងនោះទេ ។ បន្ទាប់ពីមានការជជែកដេញដោលគ្នាជាច្រើនខែ ពេលវេលាក៏ត្រូវវាអស់ ឯភាគីទាំងពីរក៏មិនអាចរកការត្រូវរ៉ូវគ្នាបាន។

អ្វីទៅជាកម្មវិធីសុខភាពអូបាម៉ា? កម្មវិធីនេះជាគំនិតផ្ដើមថ្មីបំផុតសម្រាប់សុខភាព ដែលស្នើឡើងដោយប្រធានាបតី អូបាម៉ា ដែលទាមទារ ឱ្យពលរដ្ឋសហរដ្ឋអាមេរិកទាំងអស់មានការធានារ៉ាប់រងខាងសុខភាព និងអនុញ្ញាតឱ្យក្រុមហ៊ុនធានារ៉ាប់រងបដិសេធមិនផ្ដល់ការថែទាំឱ្យប្រជាពលរដ្ឋទេ។ កម្មវិធីនេះ បើតាមការអះអាងពីឯកសារមួយចំនួន គឺផ្ដល់ជាជំនួយហិរញ្ញវត្ថុដល់អ្នកទាំងឡាយណាដែលមិនអាចរ៉ាប់រងការធានារ៉ាប់រងបាន។ ប្រជាពលរដ្ឋទាំងអស់ត្រូវតម្រូវឱ្យមានការធានារ៉ាប់រងសុខភាព ឬបើមិនដូចនោះទេត្រូវបង់តម្លៃមួយនៅលើពន្ធរបស់ខ្លួន។ តើហេតុអ្វីបានជាសភាចង់គ្រវែងកម្មវិធីសុខភាពអូបាម៉ា ចោល ? សភាសហរដ្ឋអាមេរិក បច្ចុប្បន្នមានសមាជិកភាគច្រើនមកពីគណបក្សសាធារណរដ្ឋ។ពួកគេជឿថាការតម្រូវឱ្យប្រជាពលរដ្ឋទិញការធានារ៉ាប់រង ជាការធ្វើហួសពីដែនកំណត់ ហើយនិងថា ការយកថ្លៃណាមួយបើមិនគោរពតាមកម្មវិធីនេះទេ នោះជាការមិនមានយុត្តិធម៌ទេ។

ការបិទសេវាសាធារណៈឬការមិនដំណើរការរដ្ឋាភិបាល មានឥទ្ធិពលដូចម្ដេចខ្លះចំពោះសហរដ្ឋអាមេរិក ? អ្នកវិភាគសេដ្ឋកិច្ចបានប៉ាន់ស្មានថា ការបិទសេវាសាធារណៈរបស់រដ្ឋពីបី ទៅបួនសប្ដាហ៍នេះ អាចនឹងធ្វើឱ្យមានការបាត់បង់ថវិកាសឹងតែ ៥៥ ពាន់លានដុល្លារ។ និយាយដល់នេះ តាម www.realclearworld.com ដែលស្រង់លទ្ធផលនៃការសាកសួរមតិរបស់មជ្ឈមណ្ឌលស្រាវជ្រាវមួយបង្ហាញថា ៥៤% នៃអ្នកដែលកំណត់ខ្លួនថាជាអ្នកសាធារណរដ្ឋនិយម ជឿថា រដ្ឋាភិបាលសហរដ្ឋអាមេរិក "អាចនឹងទៅហួសពីកាលបរិច្ឆេទ ក្នុងការលើកកម្ពស់កម្រិតពិដានបំណុលដោយមិនមានបញ្ហាសេដ្ឋកិច្ចអ្វីដុំកំភួនទេ" ។

យ៉ាងណាក្ដី មានការវិភាគមិនលម្អៀងទៅតាមតែទស្សនៈរបស់បក្សនយោបាយថា ការគិតបែបនេះនៃមតិភាគច្រើនជាសញ្ញាគួរឱ្យព្រួយបារម្ភថា ភាពពុលនៃប្រព័ន្ធនយោបាយរបស់អាមេរិកកំពុងតែធ្វើឱ្យខូចជំហរសេដ្ឋកិច្ចរបស់ប្រទេស ៥២ រដ្ឋនេះក្នុងពិភពលោកហើយ។

បន្ទាប់ពីការចោទប្រកាន់គ្នាទៅវិញទៅមកអំពីការមិនគិតផលប្រយោជន៍ប្រទេសជាតិ នៅថ្ងៃទី ១៦ ខែតុលា សមាជិកសភាសហរដ្ឋអាមេរិកបានអនុម័តដោយសំឡេង ២៨៥ គាំទ្រ និង ១៤៤ ជំទាស់ចំពោះច្បាប់ថ្មីមួយដែលអនុញ្ញាតឱ្យរដ្ឋាភិបាលខ្ចីប្រាក់បំណុលបន្ថែម។ លោកប្រធានាបតី បារ៉ាក់ អូបាម៉ា ក៏បានចុះហត្ថលេខាលើច្បាប់ថវិកា ដែលនឹងបើកផ្លូវឱ្យរដ្ឋាភិបាលខ្ចីប្រាក់បំណុលបន្ថែម និងផ្គត់ផ្គង់ថវិកាដល់រដ្ឋសហព័ន្ធផង ហើយក៏បើកឡើងវិញនូវប្រាក់ខែ ដែលពួកគេមិនបានទទួលក្នុងពេលត្រូវបញ្ឈប់ពីការងារ ២ សប្ដាហ៍កន្លងទៅ។ទោះយ៉ាងណា ច្បាប់ថ្មីនេះសម្រេចឱ្យប៉ះប៉ូវការផ្គត់ផ្គង់ថវិកាដល់សេវាសាធារណៈត្រឹមថ្ងៃទី១៥ខែមករាតែប៉ុណ្ណោះ ហើយបើកផ្លូវឱ្យរដ្ឋាភិបាលអាចខ្ចីប្រាក់បំណុលបន្ថែមឬរូតពិដានបំណុលត្រឹមថ្ងៃទី ០៧ ខែកុម្ភៈ ឆ្នាំ ២០១៤។ មានការពិចារណាថា ការជាប់គាំងថវិកា និងគ្រោះថ្នាក់ក្ស័យធនកម្រិតជាតិនឹងកើតមានជាថ្មីនៅដើមឆ្នាំក្រោយនេះ បើរដ្ឋាភិបាលអាមេរិកមិនមានលទ្ធភាពនឹងរកប្រាក់ឱ្យបានច្រើនឡើងវិញដើម្បីយកមកដោះស្រាយសភាពការណ៍នេះ ឬក៏បើគណបក្សទាំង ២ រកការយល់គ្នាមិនឃើញតទៅមុខទៀត។/

# ឃុំតាលោ : កាន់តែអភិវឌ្ឍ កាន់តែទទួលបានការគាំទ្រ




លោក យ៉ាំ យ៉េន ជួបពិភាក្សាជាមួយ ប្រជាជនក្នុងមូលដ្ឋាន

*ក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី ៥ នៃរដ្ឋសភាកាលពីថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០១៣ កន្លងទៅ គណបក្សប្រជាជនកម្ពុជាឃុំតាលោទទួលបានសំឡេងគាំទ្រនាំមុខគេក្នុងចំណោម ឃុំទាំង ១០ របស់ស្រុកបាកាន ខេត្តពោធិសាត់ ។តាមរយៈលទ្ធផលនេះបានបង្ហាញច្បាស់នូវជំនឿរបស់ ប្រជាជនជាម្ចាស់ឆ្នោតនៅមូលដ្ឋានចំពោះគណបក្សប្រជាជនកម្ពុជា ។*

## ឃុំតាលោនៅទីណា ?

តាលោ ជាឈ្មោះនៃឃុំមួយរបស់ស្រុកបាកាន ខេត្តពោធិសាត់ និងមានភូមិចំនួន ២០ ។ ឃុំមាន ទីតាំងស្ថិតនៅទិសនិរតីនៃទីរួមខេត្តពោធិសាត់ ប្រមាណ ៤៥ គ.ម និង ២៧ គ.ម ពីទីរួមស្រុកបាកាន។ ដើម្បីទៅដល់ឃុំនេះ គេអាចធ្វើដំណើរតាមផ្លូវចូលចំនួន ៥ ខ្សែខុសៗគ្នា ។ ក្នុងនោះផ្លូវមកពីឃុំដទៃនៃស្រុកបាកានចំនួន ២ ខ្សែ ផ្លូវមកពីក្រុងសំពៅមាស ១ ខ្សែ ផ្លូវមកពីស្រុកភ្នំក្រវាញ ១ ខ្សែ និងពីស្រុករុក្ខគិរី ខេត្តបាត់ដំបង ១ ខ្សែ។

ឃុំតាលោមានព្រំប្រទល់ខាងជើងជាប់នឹងឃុំ



ប្រឡាយទឹកស្រោចស្រពស្រែកសិករឃុំតាលោ

វំលេច ស្រុកបាកាន ខាងកើតជាប់នឹងឃុំខ្នារជើង ស្រុកបាកាន និងឃុំផ្ទះរុង ស្រុកភ្នំក្រវាញ ខាងត្បូងជាប់នឹងឃុំផ្ទះរុងនិងឃុំក្រពើពីរ ស្រុកវាលវែង និងខាងលិចជាប់នឹងឃុំមុខរា ស្រុករុក្ខគិរី ខេត្តបាត់ដំបង ។ ឃុំមានផ្ទៃដីសរុប ៣០ ០០០ ហ.ត។ ក្រៅពីដីលំនៅស្ថាន គឺមានដីស្រែ ១៦ ២១៣,០៧ ហ.ត ដីចម្ការចម្រុះ ១ ៤៤៧,០៩ ហ.ត។ មានពលរដ្ឋ ៤ ៥៣៩ គ្រួសារ ស្មើនឹងចំនួនមនុស្ស ២២ ០៦៣ នាក់ (ស្រី ១១ ៤៤៤នាក់) ។ ប្រជាជននៃឃុំនេះស្ទើរទាំងស្រុងពឹងផ្អែកលើមុខរបរកសិកម្ម។ចំណែកការលក់ដូរមានតិចតួចនៅតាមផ្ទះប៉ុណ្ណោះ។

## លោកមេឃុំតាលោបានរៀបរាប់ពីអ្វីដែលបាន និងកំពុងកើតមាននៅក្នុងឃុំរបស់គាត់

ស្ថិតនៅក្នុងស្នាក់ការឃុំដ៏សមរម្យ និងក្នុងសម្លៀកបំពាក់យ៉ាងសាមញ្ញ លោក យ៉ាំ យ៉េន ប្រធានក្រុមប្រឹក្សាឃុំតាលោ និងជាប្រធានគណបក្សប្រជាជនកម្ពុជាឃុំបានឱ្យដឹងថា តាលោពេលនេះគឺខុសពីពេលម្ភៃឆ្នាំមុននេះ ដែលប្រទេសនៅពុំទាន់មានសន្តិភាពពេលលេញនោះ ទីនេះក៏មិនមានសុវត្ថិភាព និងស្ថិរភាពដែរ ។ តែពេលនេះអ្វីៗបានប្រែប្រួលហើយ។ ភាពព្រួយបារម្ភបានជំនួសវិញដោយសំឡេងសើចក្អាកក្អាយ និងសូរស័ព្ទចម្រៀងនៅក្នុងពិធីបុណ្យ និងពិធីកំសាន្តផ្សេងៗ ។ ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលមានសម្ដេចតេជោជាប្រមុខ ជីវភាពប្រជាជននៅឃុំនេះកាន់តែបានលើកស្ទួយជាលំដាប់។

ចំពោះទីផ្សារកសិផល (ស្រូវ) ដោយមានការជួយសម្របសម្រួលពីមន្ត្រីពាក់ព័ន្ធ និងភាពឧស្សាហ៍ព្យាយាមរបស់កសិករផងនោះ គឺមិនចោទជាបញ្ហាខ្លាំងទេ ។ ម៉្យាងទៀតនៅក្នុងឃុំក៏មានអ្នកទទួលទិញធំៗជាច្រើនផងដែរ។

លោកមេឃុំបន្តថា ដីធ្លីដែលពីមុនធ្លាប់តែសល់ទំនេរមួយចំនួននោះ ឥឡូវធ្វើស្រែ និងចម្ការអស់។ នៅកន្លែងខ្លះប្រជាកសិរបានធ្វើ ស្រែដល់ទៅ ២ ដង ដូចជាតំបន់នៅជាប់នឹងប្រព័ន្ធធារាសាស្ត្រដំណាក់អម្ពិលជាដើម។ ជាភ័ព្វសំណាង ខណៈដែលនៅកន្លែងមួយចំនួននៃខេត្តពោធិសាត់បានរងគ្រោះដោយទឹកជំនន់នោះ នៅឃុំតាលោពុំបានរងគ្រោះទេ គ្រាន់តែមានការប៉ះពាល់បន្តិចបន្តួចលើហេដ្ឋារចនាសម្ព័ន្ធ ផ្លូវ។

គិតត្រឹមថ្ងៃទី ១៦ ខែតុលាឆ្នាំនេះ ប្រជាកសិករបានសម្រេចការបង្កើនផលស្រូវ និងចម្ការ បាន ១០០%នៃផែនការ ក្នុងនោះស្រូវពង្រោះបានចំនួន ៥ ២១០ ហ.ត និងស្រូវសន្ទូង ៣ ១៩៥ ហ.ត ។

លោក យ៉ាំ យ៉េន មានប្រសាសន៍បន្តថា ដីបង្កបង្កើនផល និងលំនៅស្ថានរបស់ប្រជាជនក្នុងឃុំ មានទំហំធំជាងឃុំដទៃទៀតនៅក្នុងស្រុក ។ ក្នុងនោះមានដីមួយចំនួន ដែលមានពាក់ព័ន្ធដីគម្របព្រៃឈើត្រូវបានយុវជនស្ម័គ្រចិត្ត និងក្រុមការងារ បច្ចេកទេសស៊ិរិយោដីវាស់វែង និងផ្ដល់កម្មសិទ្ធិស្របច្បាប់ជូនប្រជាជន តាមរយៈការអនុវត្តបទបញ្ជាលេខ ០១ របស់រាជរដ្ឋាភិបាល។ ប្រការនេះបានផ្ដល់នូវទំនុកចិត្តថែមទៀត ពីប្រជាជនក្នុងការខិតខំបង្កបង្កើនផល។

ទោះបីជាលោកមេឃុំពុំអាចផ្ដល់ជាតួលេខជាក់លាក់ តែលោកអះអាងថា តាមការសង្កេតជាក់ស្ដែង ប្រជាជននៅឃុំរបស់លោកប្រមាណ ៨៥% មានផ្ទះឈើប្រក់សង្កសីប្រក់ក្បឿង និងហ្វីប្រូស៊ីម៉ងត៍។ ជាមួយគ្នានេះ ក៏មានការសាងសង់ជាផ្ទះថ្មបណ្ដើរៗផងដែរ ។ ប្រជាជនភាគច្រើនមានម៉ូតូជិះ និងមានគោយន្តភ្ជួរស្រែ ។ ក្នុងនោះ មួយចំនួនតូចក៏មានម៉ាស៊ីនបោកស្រូវ ម៉ាស៊ីនច្រូតស្រូវផ្សេងទៀត។

លោក យ៉ាំ យ៉េន បន្តថា ការរំដោះជីវភាពប្រជាជនពីភាពក្រីក្រ ត្រូវបានយកចិត្តទុកដាក់ តាមរយៈការបង្កើតមុខរបរ ជំរុញការដាំដុះ ចិញ្ចឹមសត្វ ការសន្សំសំចៃ ការរៀនសូត្រ ការរកទីផ្សារកសិផល ការផ្ដល់ឥណទាន ការលើកកម្ពស់សុខភាព ការអនុវត្តផែនការភូមិ-ឃុំមានសុវត្ថិភាព ។ល។

មន្ត្រីភ្នាក់ងារស្ថាប័នមីក្រូហិរញ្ញវត្ថុនៅឃុំនេះបាននិយាយថា កំណើនបរិមាណប្រាក់កម្ចីនៅឃុំតាលោពុំមែនឆ្លុះបញ្ចាំងថាប្រជាជនកាន់តែក្រីក្រនោះទេ តែបានបង្ហាញថាពួកគេមានការងារធ្វើ មានចំណូល និងខិតខំជាងមុនយ៉ាងខ្លាំងដើម្បីលើកកម្ពស់ជីវភាព។

## ការសាងសង់ និងអភិវឌ្ឍន៍

លោកមេឃុំបានបញ្ជាក់ថា កន្លងមករាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ បានស្ដារ និងអភិវឌ្ឍផ្លូវលំក្រាលក្រួស និងដីចំនួន ៣០ ខ្សែ ប្រវែង ៥៨,០៩ គីឡូម៉ែត្រ និងសាលារៀន មណ្ឌលសុខភាព អណ្ដូងស្រះទឹក ហើយបានធ្វើស្រែបង្ហាញ ការដាំដុះជាគំរូ ផ្ដល់ពូជ ជំនួយបច្ចេកទេសដាំដុះ និងចិញ្ចឹមសត្វ។ ដោយឡែកក្នុងឆ្នាំ ២០១២ -២០១៣ ឃុំទទួលបានអគារសិក្សាថ្មីធ្វើពីបេតុងចំនួន ២ ខ្នង គឺនៅសាលាបឋមសិក្សាបឹងស្ដុក ១ ខ្នង ស្មើនឹង ៦ បន្ទប់ និង

សាលាបឋមសិក្សារហាលទិល ១ ខ្នងស្មើនឹង ៥បន្ទប់ ។ មានមណ្ឌលសុខភាព ថ្មី ១ ទៀត ស្ថិតនៅភូមិរហាលទិល ដែលផ្ដល់តាមរយៈក្រុមការងារគណបក្សប្រជាជនកម្ពុជាចុះជួយឃុំនេះ។ មានសមិទ្ធផលមួយចំនួនទៀត គឺបានមកពីការយកចិត្តទុកដាក់របស់ឯកឧត្តម **ស៊ុយ សែម** ប្រធានក្រុមការងារថ្នាក់កណ្ដាលគណបក្សប្រជាជនកម្ពុជា និងក្រុមការងារចុះជួយខេត្តពោធិសាត់។

សមិទ្ធផលដែលប្រជាជនឃុំតាលោ និងឃុំដទៃទៀតអបអរសាទរ និងអរគុណយ៉ាងជ្រាលជ្រៅចំពោះរាជរដ្ឋាភិបាល និងគណបក្សប្រជាជនកម្ពុជានោះ គឺការស្ថាបនាផ្លូវលំជនបទធ្វើពីកៅស៊ូ ទទឹងពី ៥ ទៅ ៧ ម៉ែត្រ ជំនួសផ្លូវខេត្ត និងផ្លូវលំក្រាលក្រួសក្រហម ក្រោមឥណទានធនាគារអភិវឌ្ឍន៍អាស៊ី (ADB) កម្ចីសម្បទានពីសាធារណរដ្ឋកូរ៉េ និងថវិកាបដិភាគរបស់រាជរដ្ឋាភិបាលដែលសម្ដេចតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី អញ្ជើញបើកការដ្ឋាននៅភូមិព្រៃរោង ឃុំតាលោ កាលពីដើមខែធ្នូ ឆ្នាំ ២០១១។ មកទល់ពេលនេះ បើតាមប្រធានគណបក្សឃុំ និងក្រុមហ៊ុនអនុវត្តគម្រោងបានឱ្យដឹង គឺផ្លូវបានស្ថាបនាគ្រឹះផ្លូវបាន ៨០% ក្រាលកំទេចថ្មបាន ៧៥% និងក្រាលកៅស៊ូ ១ ជាន់បាន ៥៥% ហើយ។ ផ្លូវនេះចេញពីផ្លូវជាតិលេខ ៥ កាត់ឃុំបឹងខ្នារ ឃុំរំលេច ឃុំតាលោ ស្រុកបាកានទៅឃុំសំរោង ស្រុកភ្នំក្រវាញ។

## កាន់តែអភិវឌ្ឍកាន់តែកើនសំឡេងគាំទ្រ

លោក យ៉ាំ យ៉េន បានឱ្យដឹងថា ប្រជាជនភាគច្រើនលើសលប់នៅឃុំតាលោបានមើលឃើញពីភាពជាក់ស្ដែងដែលពួកគេបានទទួល។ ដោយបានយល់ច្បាស់ថា មានតែប្រមុខដឹកនាំគណបក្សប្រជាជនកម្ពុជា គឺសម្ដេចធម្មពោធិសាល **ជា ស៊ីម** សម្ដេចតេជោ **ហ៊ុន សែន** សម្ដេចពញាចក្រី **ហេង សំរិន** និងមន្ត្រីគ្រប់ថ្នាក់ដែលបម្រើការក្នុងរាជរដ្ឋាភិបាល ក្រសួង ស្ថាប័ន អាជ្ញាធរដែនដី និងអង្គភាពជំនាញពាក់ព័ន្ធ ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាលទេ ដែលមានសមត្ថភាព និងលទ្ធភាពជួយដល់ពួកគេបាន ។ ប្រជាជនបានឃើញច្បាស់ថា មានតែមន្ត្រីគណបក្សប្រជាជនកម្ពុជាប៉ុណ្ណោះដែលចុះផ្ទាល់ដល់មូលដ្ឋានយល់ដឹងសុខទុក្ខ និងជួយដោះស្រាយការលំបាកនានារបស់ប្រជាជន។ ឯមន្ត្រី និងថ្នាក់ដឹកនាំគណបក្សផ្សេងទៀតពុំបានធ្វើអ្វីទេ ។

អាស្រ័យហេតុនេះ សំឡេងឆ្នោតគាំទ្រគណបក្សប្រជាជនកម្ពុជាបានកើនឡើងជាលំដាប់ពីការបោះឆ្នោតមួយទៅការបោះឆ្នោតមួយ។ ជាក់ស្ដែងក្នុងការបោះឆ្នោតថ្នាក់ឃុំឆ្នាំ ២០០៧ គណបក្សប្រជាជនកម្ពុជាទទួលបាន ៣ ២២៣ សំឡេង បោះឆ្នោតឃុំឆ្នាំ ២០១២ ទទួលបានសឡេងគាំទ្រ ៥ ៥៥៥ សំឡេង ហើយការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី ៥ កាលពីថ្ងៃទី ២៨ កក្កដា ២០១៣ នេះ គឺមានចំណាត់ថ្នាក់ទី ១ ក្នុងស្រុកបាកាន ដោយមានសំឡេងគាំទ្រចំនួន ៥ ៦០១ សំឡេង ។ ឯគណបក្សសង្គ្រោះជាតិបានត្រឹម ១៩៥៧ សំឡេង និងគណបក្សហ្វ៊ុនស៊ិនប៉ិចបានត្រឹម ១១២ សំឡេង។

## គម្រោងអភិវឌ្ឍន៍បន្ត

លោកមេឃុំបានរំឭកថា ក្នុងអំឡុងពេលចុះឃោសនាបោះឆ្នោតជ្រើសតាំងតំណាង រាស្ត្រកន្លងទៅក្រុមការងារគណបក្សប្រជាជនកម្ពុជា បានបញ្ជាក់ពីការបន្តស្ពានអភិវឌ្ឍន៍គម្រោងថ្មីៗទៀតក្រោយពេលបោះឆ្នោត ដែលរួមមាន" ទី ១ ផ្លូវលំភូមិទួលថ្មី និងភូមិគោករលំពីផ្លូវខេត្តចូលវត្តស្រោងដល់ចំណុចអក្សរតេ និងតទៅដល់ផ្ទះពល រដ្ឋខាងចុងប្រវែង៣ ៦៥០ ម៉ែត្រ។ ទី ២ ផ្លូវលំ ភូមិទួលទទឹងប្រវែង ៣ ០០០ ម៉ែត្រ ។ ទី ៣ ផ្លូវលំ ភូមិបួច្រេសប្រវែង ៣៥០ ម៉ែត្រ។ ទី ៤ ផ្លូវលំភូមិព្រៃវាំងពីខ្លោងទ្វារវត្តដល់ស្ពានប្រវែង ៤ ៦០០ ម៉ែត្រ និងផ្លូវលំតទៅភូមិទួលតាលោប្រវែង ២ ០០០ ម៉ែត្រ ។ ទី ៥ ផ្លូវលំភូមិព្រៃតោ ១ ៥០០ ម៉ែត្រ។ ទី ៦ ផ្លូវលំភូមិតាលោ ១ ៥០០ ម៉ែត្រ ។

ចំណែកប្រព័ន្ធធារាសាស្ត្រវិញ គឺទី ១ ប្រឡាយនាំទឹកត្រពាំង ស្ដើងទុង ទន្លេ-ចង្អុក-ចារ៉ល់-ព្រៃវាំង-ទួលតាលោ និងទួលទទឹង ។ ទី ២ ប្រឡាយរងតាមថ្នល់កៅស៊ូពីប្រព័ន្ធប្រឡាយមេដំណាក់អំពិលពីចំណុចភូមិគោករលំដល់មុខស្នាក់ការបក្សឃុំ។ ទី ៣ ប្រឡាយនាំទឹកភូមិបួច្រេស-ទួលថ្ម។ បន្ថែមលើនោះ នៅគ្រប់ភូមិនៃឃុំនេះបាន និងកំពុងត្រៀមទទួលការផ្គត់ផ្គង់បណ្ដាញអគ្គិសនីពីអាជ្ញាធរអគ្គិសនីកម្ពុជា។

លោក ឃន ឃៀង មេភូមិទួលជ្រាវបាននិយាយថា បើបានប្រឡាយរង និងប្រឡាយនាំទឹកសម្រាប់យកទឹកធ្វើស្រែវស្សា និងដល់ស្រែប្រាំង ទៀតដែលគ្រោងស្ថាបនាដោយគណបក្សប្រជាជនកម្ពុជានោះ កសិករដែលរំពឹងតែទឹកភ្លៀងមួយមុខនាពេលកន្លងមកនឹងមានជីវភាពធូរធាថែមទៀត ពីព្រោះអាចមានលទ្ធភាពបង្កបង្កើនផលដាំ បន្លែ ចិញ្ចឹមសត្វ និងប្រកបរបរផ្សេងៗ។

អ៊ំស្រី ខាត់ រាំ អាយុ ៥៩ ឆ្នាំ រស់នៅភូមិទួលជ្រាវនិយាយថា សេចក្ដីត្រូវការរបស់ប្រជាជនបន្ថែមលើសុខសន្តិភាព ស្ថិរភាពនោះ គឺជីវភាពធូរធារ មានសុខភាពល្អ មានផ្លូវ សាលារៀន ប្រព័ន្ធប្រឡាយ ពូជដំណាំ ព្រមទាំងបច្ចេកទេសផលិត រហូតដល់តម្លៃកសិផល និងទីផ្សារ។ អ៊ំស្រីក៏ដូចកសិករទូទៅក្នុងភូមិ



*ផ្លូវឆ្លងកាត់ឃុំតាលោ*

ចង់ឱ្យគណបក្សប្រជាជន និងអាជ្ញាធរស្ថាបនាឡើងវិញភ្លឺភ្លោះ(ប្រឡាយនាំទឹក)ដែលស្ថាបនាពីសម័យកម្ពុជាប្រជាធិបតេយ្យ ដើម្បីនាំទឹកមកធ្វើស្រែឱ្យបានពីរដងក្នុងមួយឆ្នាំ។

ឯកសិករឈ្មោះ ញូន សុភា នៅភូមិបួច្រេសនិយាយថា អ្វីៗបានពេញចិត្តប្រជាជនហើយ តែតទៅមុខ ប្រជាជនសុំកសាងប្រឡាយនាំទឹកដែលនឹងអាចឱ្យធ្វើស្រែបាន ២ ដងក្នុងមួយឆ្នាំ។ បើជួយពូជបច្ចេកទេស ជី និងទីផ្សារលក់ទៀត កាន់តែល្អ។

អ៊ំប្រុស ផ្លែក មឿន អាយុ ៧៥ ឆ្នាំ រស់នៅភូមិតាលោនិយាយថា ចំណូលក្នុងគ្រួសាររបស់គាត់គឺធ្វើតែស្រែមួយមុខ តែគាត់អាចចិញ្ចឹមកូន ៥ នាក់ ដែលកំពុងតែរៀនទាំងអស់។ ពីមុនស្រូវត្រូវដឹកទៅលក់ដល់ផ្លូវជាតិលេខ ៥ ហើយផ្លូវក៏លំបាក។ ឥឡូវបានផ្លូវល្អ ងាយស្រួល និងមានច្រើន។ រថយន្តធំៗរបស់ឈ្មួញបានចូលមកទិញស្ទើរដល់ស្រែនាំទៅលក់នៅប្រទេសវៀតណាម និងថៃ។

អ៊ំប្រុសនិយាយបន្តថា "ប្រជាជនមានបំណងសុំឱ្យរដ្ឋជួយជាប្រឡាយទឹក បច្ចេកទេសដាំដុះ ពូជ និងកន្លែងលក់កសិផល។ បើសម្រេចបានដូចនេះ ប្រជាជននឹងមានជីវភាពធូរធារឡើងទៀត"។ អ៊ំសង្ឃឹមថា សមិទ្ធផលផ្លូវកៅស៊ូថ្មីជាចំណងដៃរបស់រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ផ្លូវលំ ប្រឡាយទឹក សាលារៀន មណ្ឌលសុខភាព សេវានានា បណ្ដាញភ្លើង នឹងញ៉ាំងឱ្យប្រជាជនរីករាយសប្បូរសប្បាយ និងរឹងរឹតតែជឿជាក់គាំទ្រគណបក្សប្រជាជនកម្ពុជាក្នុងការបោះឆ្នោតក្រោយៗ។

លោកមេឃុំបានបញ្ជាក់ថា អ្វីៗដែលជាសំណូមពររបស់ប្រជាជននៅឃុំតាលោ គឺសុទ្ធតែស្ថិតនៅក្នុងកម្មវិធីអភិឌ្ឍន៍របស់ឃុំ និងការគិតគូររបស់ ស្រុក ខេត្ត និងរាជរដ្ឋាភិបាលអស់ហើយ ពេលនេះកំពុងត្រូវបានអនុវត្តជាបន្តបន្ទាប់។/

# វស្សាភ្លៀងធំ

(បទកាកគតិ)

ស្រណោះវាលស្រែ វស្សាដើមខែ សន្ទុងលាស់ខ្ចី
បៃតងស្រងាត់ ដូចផាត់ពណ៌ថ្មី ក្រាលគ្របសព្វដី
ផ្ទៃស្រែចម្ការ ។

បិណ្ឌភ្ជុំមកដល់ ទន្លេព្រៀបកល ជោរជន់ជលសារ
ភ្លៀងធំសន្ធាប់ ស្រោចស្រពខ្លាំងក្លា នាំគ្រោះអន្តការ
លិចលង់ដំណាំ ។

ស្តាយអើយសែនស្តាយ មិនគួរអន្តរាយ ផលកសិកម្ម
កំពុងលូតលាស់ រីកស្រស់ស្រងាំ ត្រូវទឹកជនត្រាំ
ស្អាំលិចរលួយ ។

អាសូរប្រជា ជួបគ្រោះពាធា ដល់នូវទុក្ខព្រួយ
បាត់ស្នាមញញឹម សង្ឃឹមជំនួយ ស្រោចស្រង់លើកស្ទួយ
ឆ្លងគ្រោះមួយគ្រា ។

នេះបន្ទុកធ្ងន់ បក្សប្រជាជន រួមនឹងរដ្ឋា (ភិបាល)
ព្រមទាំងកាកបាទ ក្រហមកម្ពុជា ចុះជួយម្ចីម្នា
រំដោះគ្រោះភ័យ ។

ខែភទ្របទ រនោចឆ្លងផុត ដល់អស្សុជថ្មី
ទឹកស្រកលាស្រែ ពុកម៉ែផុតភ័យ ផ្តើមសាបព្រោះថ្មី
ដាំដុះបន្ត ។

ដោយៈ សុខ សុធន




## ម៉េចខាយម្លេះ !

ពេលសាកសួរចម្លើយ លោកចៅក្រម និយាយជាមួយនាយ គ្រុឌ ដែលជាពិរុទ្ធជន :

- ទោសរបស់អ្នកឯង ត្រូវជាប់គុក ៤ឆ្នាំ ប៉ុន្តែបើអ្នកឯងព្រមប្រាប់ត្រង់ថា លុយដែល លួចបាននោះយកទៅលាក់ទុកនៅកន្លែងណា នឹងទទួលបានការសម្រាលទោស នៅត្រឹមជាប់គុកតែបួនខែប៉ុណ្ណោះ ។

នាយ គ្រុឌ សើចរួចឆ្លើយ :

-ម៉េចក៏ងាយម្លេះ? លោកចៅក្រមស្មានថា បើមិនជាប់គុក ៤ឆ្នាំ ខ្ញុំអាចរកលុយបានច្រើនដល់ម្លឹងឬ? ។

## ទៅផឹកស្រា

ព្រឹកមួយលោកអនុសេនីយទោមេបញ្ជាការ បានប្រជុំជួរពលទាហានថ្មីទាំងអស់ ហើយសួរ :

- ទាំងអស់គ្នា មុនពេលមកធ្វើទាហាន មានអ្នកណាធ្លាប់ផឹកស្រាទេ?

ទាំងអស់គ្នាស្ងាត់មាត់ច្រៀប អត់ហ៊ានឆ្លើយ ។ ពេលវេលាកន្លងទៅមួយសន្ទុះ ទើបនាយ ជុន ដើរចេញពីជួរដើម្បីឆ្លើយតបទៅលោកមេបញ្ជាការ ប៉ុន្តែនាយ ជុន មិនទាន់បាននិយាយផង លោកមេបញ្ជាការនិយាយមុន :

- ល្អណាស់ ! បើអ៊ីចឹងឯងទៅផឹកស្រាជាមួយខ្ញុំចុះ ចំណែកអ្នកឯទៀតដែលមិនធ្លាប់ផឹកស្រា ត្រូវទៅបោចស្មៅទាំងអស់គ្នា ។

## ព្រោះតែកណ្តាស់

នាយ ទក និង នាយ ទិន ជាប់ទោសនៅក្នុងបន្ទប់ឃុំឃាំងតែមួយ សំណេះ សំណាលគ្នា :

ទក - តើឯងមានទោសស្អី ?

ទិន - កណ្តាស់ !

ទក - អ្ហែស ! ខ្ញុំសួរថា ឯងជាប់គុក ព្រោះអ្វីមិនសួរពីជំងឺទេ ។

ទិន - អើ គឺវាអ៊ីចេះ ! យប់មួយមេឃងងឹត ហើយត្រជាក់ ខ្ញុំលបចូលផ្ទះអ្នកមេម៉ាយស្តុកម្នាក់ ។ ចូលដល់ក្នុង អ្នកផ្ទះកំពុងលង់លក់ស្រមុកខុរៗ ខ្ញុំនឹក ត្រេកអរថា នឹងអាចយកបានមាសប្រាក់ ឬរបស់មានតម្លៃផ្សេងៗ លក់បានលុយ ច្រើនមិនខាន ។ ដឹងអីមិនទាន់បានបញ្ចេញស្នាដៃផង ខ្ញុំក៏កណ្តាស់ឆែតៗជួនគ្នា ផ្អើលអ្នកមេម៉ាយ និងកូនចៅ ហៅប៉ូលីសព័ទ្ធចាប់ខ្ញុំបានទាំងយប់ ។ អ៊ីចឹងបើមិនជាប់ទោសព្រោះកណ្តាស់ តើស្អីទៅវិញ? ។

## លោកជាអ្នកណា ?

រាត្រីមួយ លោកមេធាវីម្នាក់ បើករថយន្តចេញពីកន្លែងជប់លៀងឡើងផ្ទះថ្មីរបស់មិត្តភក្តិ ។ ដោយផឹកស្រាស្រវឹងធ្លាក់ភ្នែក ក៏បានបើករថយន្តបុកគូទរថយន្តមួយគ្រឿងទៀតដែលបើកបរពីខាងមុខស្របទិសគ្នា ។ ពេលរថយន្តខាងមុខបញ្ឈប់លោកមេធាវីចុះដើរសំដៅរថយន្តនោះរួចនិយាយក្តែងៗគំរាមម្ចាស់រថយន្ត :

- ម្តងនេះ លោកឯងស៊យធំហើយ ដឹងថាខ្ញុំជាអ្នកណាទេ?

ម្ចាស់រថយន្តរងគ្រោះ ធ្វើភ្នែកឡឹងឡង់សួរវិញ :

- ចុះលោកជាអ្នកណា ?

- ខ្ញុំនេះជាមេធាវី !

- បើអ៊ីចឹង អ្នកដែលត្រូវស៊យនោះ គឺលោកទៅវិញទេ ពីព្រោះខ្ញុំជាចៅក្រមតុលាការ ។/

## សេចក្តីកែតម្រូវ

ទស្សនាវដ្តីប្រជាជនសូមធ្វើការកែតម្រូវខ្លឹមសារចំណងជើងរូបថតក្នុងអត្ថបទចេញផ្សាយក្នុងលេខ ១៤៨ ខែកញ្ញា ឆ្នាំ ២០១៣ ទំព័រទី ១៨ ដែលដាក់ថា *: ឯកឧត្តម* ***ខៀវ តាន់យ៉ុង*** *ទទួលស្វាគមន៍សម្តេចតេជោ* ***ហ៊ុន សែន*** សូមដាក់ថា *: ឯកឧត្តម* ***លី ខីឈាង*** *ទទួលស្វាគមន៍សម្តេចតេជោ* ***ហ៊ុន សែន*** ។

ចំណងជើងរូបថតនៅទំព័រទី ១៩ ដែលដាក់ថា *: សម្តេចអគ្គមហាសេនាបតីតេជោ* ***ហ៊ុន សែន*** *ក្នុងឱកាសជួបសវនាការជាមួយឯកឧត្តម* ***ឈិន វុ*** និងឯកឧត្តម ***លី ខីឈាង*** សូមដាក់ថា *: សម្តេចអគ្គមហាសេនាបតីតេជោ* ***ហ៊ុន សែន*** *ក្នុងឱកាសជួបសវនាការជាមួយឯកឧត្តម* ***ឈិន វុ*** និងឯកឧត្តម ***លី ជីហោង*** ។

**សូមអរគុណ**

បោះពុម្ពដោយរោងពុម្ព **អរិយធម៌** ផ្ទះលេខ ៩២, ផ្លូវលេខ ៥៩៤, សង្កាត់បឹងកក់ II ខណ្ឌទួលគោក-ភ្នំពេញ
H/P : 012 935 822 / Tel : 023 885 188 / Fax : 023 885 189 E-mail : ariyathoar@yahoo.com / ariyathoar@online.com.kh

# អ្នកឧបត្ថម្ភ ទស្សនាវដ្ដី ប្រជាជន លេខ ១៤៩

| | | | | | |
|---|---|---|---|---|---|
| ១- | ឯ.ឧ | កែ | គឹមយ៉ាន | សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្ដាល ប្រធានក្រុមការងារចុះខេត្តបន្ទាយមានជ័យ | ១០០ ដុល្លារ |
| ២- | ឯ.ឧ | ចម | ប្រសិទ្ធ | ប្រធានគណៈកម្មាធិការគណបក្សក្រសួងពាណិជ្ជកម្ម និងលោកជំទាវ | ២០០ ដុល្លារ |
| ៣- | ឯ.ឧ | មិន | ឃិន | ប្រធានគណៈកម្មាធិការគណបក្សក្រសួងធម្មការ និងសាសនា និងលោកជំទាវ **ខួន ផួន** | ១០០ ដុល្លារ |
| ៤- | ឯ.ឧ | អ៊ុក | រ៉ាប៊ុន | អនុប្រធានគណៈកម្មាធិការគណបក្សក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ១០០ ដុល្លារ |
| ៥- | ឯ.ឧ | ចន្ទ | សារុន | ទេសរដ្ឋមន្ត្រី | ៤០០.០០០៛ |
| ៦- | ឯ.ឧ | ត្រាំ | អ៊ីវតឹក | ប្រធានគណៈកម្មាធិការគណបក្សក្រសួងសាធារណការ និងដឹកជញ្ជូន | ១០០ ដុល្លារ |
| ៧- | ឯ.ឧ | ថោង | ខុន | ប្រធានគណៈកម្មាធិការគណបក្សក្រសួងទេសចរណ៍ | ១០០ ដុល្លារ |
| ៨- | ឯ.ឧ | ឯិន | ឃុន | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកប្រធានរតនាគារជាតិ | ១០០ ដុល្លារ |
| ៩- | ឯ.ឧ | ហ៊ុន | ណេង | ប្រធានគណៈកម្មាធិការគណបក្សខេត្តកំពង់ចាម | ១០០ ដុល្លារ |
| ១០- | ឯ.ឧ | ជៀង | អំ | ប្រធានគណៈកម្មាធិការគណបក្សខេត្តស្វាយរៀង | ១០០ ដុល្លារ |
| ១១- | ឯ.ឧ | ស្បោង | សារ៉ាត | ប្រធានគណៈកម្មាធិការគណបក្សខេត្តព្រះសីហនុ | ១០០ ដុល្លារ |
| ១២- | ឯ.ឧ | ខូយ | សុខា | អនុប្រធានគណៈកម្មាធិការគណបក្សខេត្តពោធិសាត់ | ១០០ ដុល្លារ |
| ១៣- | ឯ.ឧ | អ៊ូស្ថាន | ហាស្សាន់ | ប្រធានគណៈចលនាសាសនិកឥស្លាមនៃគណបក្សប្រជាជនកម្ពុជា | ១០០ ដុល្លារ |
| ១៤- | ឯ.ឧ | សរ | ចំរ៉ុង | ប្រធានគណៈកម្មាធិការគណបក្សខេត្តក្រចេះ | ១០០ ដុល្លារ |
| ១៥- | ឯ.ឧ | ផា | សុជាតិវង្ស | អនុប្រធានគណៈកម្មាធិការគណបក្សរាជធានីភ្នំពេញ | ១០០ ដុល្លារ |
| ១៦- | ឯ.ឧ | ម៉ម | ប៊ុននាង | សមាជិកព្រឹទ្ធសភា | ១០០ ដុល្លារ |
| ១៧- | ឯ.ឧ | ប្រាក់ | ចំរើន | សមាជិកព្រឹទ្ធសភា | ១០០ ដុល្លារ |
| ១៨- | ឯ.ឧ | គង់ | វិបុល | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអគ្គនាយកដ្ឋាន នៃអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ១០០ ដុល្លារ |
| ១៩- | ឯ.ឧ | យូ | តិរម្យ | សមាជិកក្រុមការងារចុះខេត្តកំពង់ស្ពឺ ប្រធានក្រុមការងារចុះស្រុកឧិរ៉ាល់ | ១០០ ដុល្លារ |
| ២០- | គណៈកម្មាធិការគណបក្សខេត្តបាត់ដំបង | | | | ១០០ ដុល្លារ |
| ២១- | គណៈកម្មាធិការគណបក្សខេត្តសៀមរាប | | | | ១០០ ដុល្លារ |
| ២២- | គណៈកម្មាធិការគណបក្សខេត្តបន្ទាយមានជ័យ | | | | ៥០ ដុល្លារ |
| ២៣- | គណៈកម្មាធិការគណបក្សក្រសួងកិច្ចការនារី | | | | ៥០ ដុល្លារ |
| ២៤- | ឯ.ឧ | លឹម | គានហោ | ប្រធានគណៈកម្មាធិការគណបក្សក្រសួងធនធានទឹក | ២០០.០០០ ៛ |
| ២៥- | ឯ.ឧ | ឃឹម | សារិទ្ធ | ប្រធានគណៈកម្មាធិការគណបក្សក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | ៥០ដុល្លារ |
| ២៦- | ឯ.ឧ | ម៉ម | ប៊ុនហេង | ប្រធានគណៈកម្មាធិការគណបក្សក្រសួងសុខាភិបាល | ៥០ ដុល្លារ |
| ២៧- | ឯ.ឧ | ជា | យ៉ាវ | អនុប្រធានគណៈកម្មាធិការគណបក្សធនាគារជាតិនៃកម្ពុជា | ២១៣.៤៧០៛ |
| ២៨- | ឯ.ឧ | យូ | ស៊ុនឡុង | ទីប្រឹក្សាផ្ទាល់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** | ៥០ ដុល្លារ |
| ២៩- | ឯ.ឧ | ជូ | យ៉ិនស៊ុំម | រដ្ឋលេខាធិការក្រសួងសុខាភិបាល | ៥០ ដុល្លារ |
| ៣០- | ឯ.ឧ | អ៊ុក | ប្រាថ្នា | រដ្ឋលេខាធិការក្រសួងព័ត៌មាន | ២០០.០០០ ៛ |
| ៣១- | ឯ.ឧ | ប៉ាវ | ហាមផាន | អនុប្រធានគណៈកម្មាធិការគណបក្សខេត្តរតនគិរី | ៥០ ដុល្លារ |
| ៣២- | ឯ.ឧ | សូ | ដុងហួរ | ប្រធានក្រុមប្រឹក្សាខេត្តព្រះសីហនុ | ៥០ ដុល្លារ |
| ៣៣- | ឯ.ឧ | ចាយ | បូរិន្ទ | អ្នកតំណាងរាស្ត្រមណ្ឌលកំពង់ចាម | ៥០ ដុល្លារ |
| ៣៤- | ឯ.ឧ | នរៈ | រតនៈវឌ្ឍនោ | រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា | ២០០.០០០ ៛ |
| ៣៥- | ឯ.ឧ | ប៊ុន | លឹមហេង | អនុរដ្ឋលេខាធិការទីស្ដីការគណៈរដ្ឋមន្ត្រី | ២០០.០០០៛ |
| ៣៦- | ឯ.ឧ | សេង | នៀង | ជំនួយការផ្ទាល់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** | ២០០.០០០៛ |
| ៣៧- | ឧកញ៉ា | ម៉ក់ | គឹមហុង | ប្រធានអគ្គនាយកចំការកៅស៊ូជប់ | ២០០.០០០៛ |
| ៣៨- | ឯ.ឧ | គឹម | ណាំង | សមាជិកព្រឹទ្ធសភា | ១០០.០០០៛ |
| ៣៩- | ឯ.ឧ | ម៉ៅ | ប៊ុនណារិន | សមាជិកគណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា | ១០០.០០០៛ |
| ៤០- | ឯ.ឧ | ម៉ែន | ស៊ុំផាន់ | សមាជិកព្រឹទ្ធសភា | ១០០.០០០៛ |
| ៤១- | ឯ.ឧ | សុន | គន្ធរ | រដ្ឋមន្ត្រីប្រតិភូអមសម្ដេចនាយករដ្ឋមន្ត្រី | ១០០.០០០៛ |
| ៤២- | លោកជំទាវ **ស៊ឹង** | | **ស៊ុយុត** | | ១០០.០០០៛ |
| ៤៣- | ឯ.ឧ | គឹម | ផា | ប្រធានក្រុមប្រឹក្សាខេត្តស្វាយរៀង | ១០០.០០០៛ |
| ៤៤- | ឯ.ឧ | គាំម | កុសល | ទីប្រឹក្សាសម្ដេចអគ្គមហាពញាចក្រី **ហេង សំរិន** | ១០០.០០០៛ |
| ៤៥- | ឯ.ឧ | ប៊ិច | សុវណ្ណ | | ១០០.០០០៛ |
| ៤៦- | ឯ.ឧបណ្ឌិត **មាស** | | **ប៉ូ** | អនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | ១០០.០០០៛ |
| ៤៧- | លោកជំទាវ **ឆិត្យ** | | **ច័ន្ទតារីន** | អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ១០០.០០០៛ |
| ៤៨- | ឯ.ឧ | ប៊ុន | ថារឫទ្ធិ | ទីប្រឹក្សាសម្ដេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** អភិបាលរងខេត្តសៀមរាប | ១០០.០០០៛ |
| ៤៩- | ឯ.ឧ | អ៊ុំ | វណ្ណា | | ១០០.០០០៛ |
| ៥០- | ឯ.ឧ | ឆា | ច័ន្ទលីដា | ទីប្រឹក្សាសម្ដេចអគ្គមហាពញាចក្រី **ហេង សំរិន** | ១០០.០០០៛ |
| ៥១- | ឯ.ឧ | យិន | សុង | ទីប្រឹក្សាឯកឧត្ដម **ខួន សុឌារី** អនុប្រធានទី ១ រដ្ឋសភា | ១០០.០០០៛ |
| ៥២- | ឯ.ឧ | ម៉ែន | វិបុល | ប្រធានគណៈហិរញ្ញវត្ថុនៃគណៈកម្មាធិការគណបក្សខេត្តស្វាយរៀង | ១០០.០០០៛ |
| ៥៣- | ឯ.ឧ | អោម | ចន | ទីប្រឹក្សាសម្ដេចអគ្គមហាពញាចក្រី **ហេង សំរិន** | ១០០.០០០៛ |
| ៥៤- | ឯ.ឧ | ជួន | ថេរ៉ាវ៉ាត | ទីប្រឹក្សាសម្ដេចអគ្គមហាពញាចក្រី ហេង សំរិន | ១០០.០០០៛ |
| ៥៥- | ឯ.ឧ | ម៉ៅ | ឡាំង | ទីប្រឹក្សាឯកឧត្ដម **ខួន សុឌារី** អនុប្រធានទី ១ រដ្ឋសភា | ១០០.០០០៛ |
| ៥៦- | ឯ.ឧ | ទន់ | ចន | ទីប្រឹក្សាឯ.ឧរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន | ១០០.០០០៛ |
| ៥៧- | លោក | ឆាយ | ឫទ្ធិសែន | ប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្ម និងសំណង់ និងសុរិយោដីរាជធានីភ្នំពេញ | ១០០.០០០៛ |
| ៥៨- | លោក | សាំ | ពិសិដ្ឋ | ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូន រាជធានីភ្នំពេញ | ១០០.០០០៛ |
| ៥៩- | ឯ.ឧ | អ៊ុន | ឆាលី | អភិបាលរងនៃគណៈអភិបាលខេត្តកោះកុង | ១០០.០០០៛ |
| ៦០- | លោក | សុខ | វិសាលសម្បត្តិ | អនុប្រធានក្រុមការងារចុះជួយឃុំព្រៃដើមថ្នឹង និងឃុំត្នោត១ ស្រុកស៊ិធរកណ្ដាល ប្រធានក្រុមហ៊ុនសម្បត្តិមហាសាល | ១០០.០០០៛ |
| ៦១- | លោកជំទាវ **ស៊ុន** | | **សារឿន** | តំណាងរាស្ត្រមណ្ឌលក្រចេះ | ៥០.០០០៛ |
| ៦២- | ឯ.ឧ | សៀង | សុខឃុនឌី | ទីប្រឹក្សាក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ៥០.០០០៛ |
| ៦៣- | ឯ.ឧ | សាយ | បូរិន | ទីប្រឹក្សាសម្ដេចអគ្គមហាពញាចក្រី **ហេង សំរិន** | ៥០.០០០៛ |

# អ្នកឧបត្ថម្ភ ទស្សនាវដ្តី ប្រជាជន លេខ ១៤៩

| | | | | | |
|---|---|---|---|---|---|
| ៦៤- | ឯ.ឧ | លី | អ៊ីមឡាក់ | ទីប្រឹក្សាក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ៥០.០០០៛ |
| ៦៥- | ឯ.ឧ | សេង | គឹមសាន | ជំនួយការសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** | ៥០.០០០៛ |
| ៦៦- | ឯ.ឧ | ពត | ចាន់នី | សមាជិកក្រុមការងារចុះជួយខេត្តកំពង់ចាម | ៥០.០០០៛ |
| ៦៧- | ឯ.ឧ | សុខ | ឌី | | ៥០.០០០៛ |
| ៦៨- | ឯ.ឧ | ហេង | វណ្ណា | សមាជិកក្រុមការងារគណបក្សចុះជួយខេត្តព្រះសីហនុ | ៥០.០០០៛ |
| ៦៩- | លោកជំទាវ | សៀ | ច័ន្ទថា | | ៥០.០០០៛ |
| ៧០- | លោក | ហួត | ពៅ | ប្រធាននាយកដ្ឋាននីតិវិធីនៃអគ្គលេខាធិការដ្ឋានរដ្ឋសភា | ៥០.០០០៛ |
| ៧១- | កញ្ញា | ផាង | និតហ្វើរី | មន្ត្រីក្រសួងទេសចរណ៍ | ៥០.០០០៛ |
| ៧២- | លោក | ង៉ោ | ម៉េងជួន | អភិបាលក្រុងប៉ោយប៉ែត | ៥០.០០០៛ |
| ៧៣- | លោក | អ៊ុំ | រាត្រី | ប្រធានគណ:កម្មាធិការគណបក្សក្រុងសេរីសោភ័ណ្ឌ ខេត្តបន្ទាយមានជ័យ | ៥០.០០០៛ |
| ៧៤- | លោក | កែវ | សែន | ប្រធានគណ:កម្មាធិការគណបក្សស្រុកអូរជ្រៅ | ៥០.០០០៛ |
| ៧៥- | លោក | ស្ទួន | សុធី | ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្តបន្ទាយមានជ័យ | ៥០.០០០៛ |
| ៧៦- | លោក | គឹម | ប៊ុណ្ណា | ប្រធានសាខាបក្សមន្ទីរសាធារណ:ការ និងដឹកជញ្ជូន ខេត្តសៀមរាប | ៥០.០០០៛ |
| ៧៧- | លោក | គាត | ហ៊ីល | ប្រធានគណ:កម្មាធិការគណបក្សសង្កាត់ផ្សារកណ្តាល ខេត្តបន្ទាយមានជ័យ | ៥០.០០០៛ |
| ៧៨- | ឯ.ឧ | អ៊ឹង | វិបុល | អង្គភាព (Q101) | ៥០.០០០៛ |
| ៧៩- | ឯ.ឧ | វេង | សាខុន | រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម | ៤០.០០០៛ |
| ៨០- | លោក | លី | សារី | សមាជិកគណ:អចិន្ត្រៃយ៍គណ:កម្មាធិការគណបក្ស ប្រធានមន្ទីររៀបចំដែនដី ខេត្តបន្ទាយមានជ័យ | ៤០.០០០៛ |
| ៨១- | លោក | គឹម | សុវណ្ណ | ប្រធានមន្ទីរសាធារណការ ខេត្តបន្ទាយមានជ័យ | ៤០.០០០៛ |
| ៨២- | គណ:កម្មាធិការគណបក្សប្រជាជនកម្ពុជា ប្រចាំគណ:កម្មាធិការសម្របសម្រួលខ្មែរកម្ពុជាក្រោម | | | | ៤០.០០០៛ |
| ៨៣- | ឯ.ឧ | ស៊ិន | វុទ្ធី | សមាជិកអចិន្ត្រៃយ៍គណ:កម្មាធិការគណបក្សក្រសួងធនធានទឹក | ៣០.០០០៛ |
| ៨៤- | ឯ.ឧ | ឈុំ | វណ្ណារិទ្ធ | អភិបាលរងខេត្តបន្ទាយមានជ័យ | ៣០.០០០៛ |
| ៨៥- | លោក | ម៉ៅ | ស្ទុខលីម | អនុប្រធានមជ្ឈមណ្ឌលជាតិវេជ្ជសាស្ត្របូរាណក្រសួងសុខាភិបាល សមាជិកក្រុមការងារចុះខេត្តតាកែវ | ៣០.០០០៛ |
| ៨៦- | លោក | ចាន់ | ស៊ុំណាត | សមាជិកគណ:កម្មាធិការគណបក្សក្រសួងធនធានទឹក | ៣០.០០០៛ |
| ៨៧- | ឯ.ឧ | ឯម | ប៊ុនធឿន | សមាជិកគណ:កម្មាធិការគណបក្ស ក្រសួងធនធានទឹក និងឧតុនិយម | ៣០.០០០៛ |
| ៨៨- | លោក | ឃុ | ពៅ | អភិបាលស្រុកស្វាយចេក | ៣០.០០០៛ |
| ៨៩- | លោក | នេព | វិសិដ្ឋ | អនុប្រធានសាខាពន្ធដារ ខេត្តព្រះសីហនុ | ២៥.០០០៛ |
| ៩០- | លោក | ឈា | ប៊ុនរិទ្ធ | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ២០.០០០៛ |
| ៩១- | លោក | ម៉ៅ | ហាក់ | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ២០.០០០៛ |
| ៩២- | លោក | លឹម | វីរក្ស | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ២០.០០០៛ |
| ៩៣- | លោក | លឹម | ថេង | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ២០.០០០៛ |
| ៩៤- | លោក | ឃ្លោក | សំអាង | សមាជិកក្រុមការងារចុះខេត្តកំពង់ចាម | ២០.០០០៛ |
| ៩៥- | ឯ.ឧ | ចួង | ផែត | អភិបាលរងខេត្តបន្ទាយមានជ័យ | ២០.០០០៛ |
| ៩៦- | កញ្ញា | កែវ | ស្ទុជាតា | មន្ត្រីជំនួយការគណ:កម្មាធិការទី ៤ នៃព្រឹទ្ធសភា | ២០.០០០៛ |
| ៩៧- | ឯ.ឧ | នេស | ច័ន្ទគីរី | សមាជិកក្រុមប្រឹក្សាខេត្តសៀមរាប | ២០.០០០៛ |
| ៩៨- | លោក | នូច | សារ៉េត | ប្រធានការិយាល័យគណនេយ្យកសិកម្ម ខេត្តបន្ទាយមានជ័យ | ២០.០០០៛ |
| ៩៩- | លោក | ហ៊ួង | ជ្រិន | ប្រធានគណ:ហិរញ្ញវត្ថុនៃគណ:កម្មាធិការគណបក្សខេត្តបាត់ដំបង | ២០.០០០៛ |
| ១០០- | ឯ.ឧ | វើក | សានត្ន | ទីប្រឹក្សាសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** | ២០.០០០៛ |
| ១០១- | លោក | គួច | ចាន់ធីត្យ | អាជីវករ ខេត្តបន្ទាយមានជ័យ | ២០.០០០៛ |
| ១០២- | លោក | លី | សារុន | មន្ត្រីក្រសួងហិរញ្ញវត្ថុ | ១៥.០០០៛ |
| ១០៣- | លោក | អ៊ុច | សាវ៉ន | អនុប្រធានមន្ទីរកសិកម្ម ខេត្តបន្ទាយមានជ័យ | ១៥.០០០៛ |
| ១០៤- | ឯ.ឧ | សេង | ស្ទុមុនី | សមាជិកគណ:អចិន្ត្រៃយ៍គណ:កម្មាធិការគណបក្សក្រសួងធម្មការ និងសាសនា | ១០.០០០៛ |
| ១០៥- | លោក | ម៉ី | លីហួត | សមាជិកក្រុមការងារចុះខេត្តកំពង់ចាម | ១០.០០០៛ |
| ១០៦- | លោក | ជួន | វណ្ណារិទ្ធ | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១០៧- | លោក | មឹម | ឬទ្ធស | អនុប្រធាននាយកដ្ឋានរដ្ឋបាល និងធនធានមនុស្សនៃក្រសួងធានធានទឹក និងឧតុនិយម | ១០.០០០៛ |
| ១០៨- | លោក | សៅ | សម្ផស្ស | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១០៩- | លោក | ឈុន | ប៊ុនឈឿន | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១១០- | លោក | ថេង | ប៊ុនតេង | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១១១- | លោក | ស្វាយ | ស្ទុគន្ធី | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១១២- | លោក | សុខ | ចំណាន | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១១៣- | លោក | សុខ | តារា | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១១៤- | លោក | សូ | ផល្លី | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១១៥- | លោក | ហួត | ធាន | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១១៦- | លោក | ទឹម | វុដ្ឋារី | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១១៧- | លោក | ណុប | វៀមណី | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១១៨- | លោក | សារុន | សម្បត្តិ | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១១៩- | លោក | សរ | វិចិត្រ | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១២០- | លោក | នូច | សុផល្លា | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១២១- | លោក | ជុំ | ឧត្តរ៉ា | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១២២- | លោក | ឈ្លាង | ប៊ុយ | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១២៣- | លោក | យស់ | ធុល | សមាជិកក្រុមការងារចុះស្រុកកំពង់លាវ ខេត្តព្រៃវែង | ១០.០០០៛ |
| ១២៤- | លោក | ឡុង | ចន្ធា | សមាជិកក្រុមការងារចុះស្រុកកំពង់លាវ ខេត្តព្រៃវែង | ១០.០០០៛ |
| ១២៥- | លោក | ម៉ុ | វុទ្ធា | មន្ត្រីមន្ទីរគណបក្ស ខេត្តព្រៃវែង | ១០.០០០៛ |
| ១២៦- | លោក | ឡាច | តារ៉ាត់ | សមាជិកក្រុមការងារចុះស្រុកបាភ្នំ ខេត្តព្រៃវែង | ១០.០០០៛ |
| ១២៧ - | លោក | ឈាង | សុវណ្ណារ៉ា | មន្ត្រីមន្ទីរគណបក្ស ខេត្តព្រៃវែង | ១០.០០០៛ |




**និពន្ធនាយក :**

**លោក តាក ស៊ុនអ៊ី**

**គណៈកម្មការនិពន្ធ**

១. លោក ខៀវ ណារី

២. លោក អ៊ុម សុន្ទរៈ

៣. លោក វង្ស សារុធ

៤. លោក ទាវ សារៈមុនី

៥. លោក សុខ សុធន

**លេខានិពន្ធ**

១. លោក ជុំ សម្បត្តិ

២. លោក ម៉ក់ ឈិន

**អ្នកបកប្រែភាសា**

១. លោកស្រី ម៉ែន នារីសោភ័គ

**អ្នកថតរូប**

១. លោក សុផាត វីរៈមុនី

**វិចិត្រករ**

១. លោក ធា សារុធ

អាស័យដ្ឋាន :

លេខ ២០៣

មហាវិថី ព្រះនរោត្តម

ភ្នំពេញ-កម្ពុជា

ទូរស័ព្ទលេខ :

០២៣ ២១៩ ០៦៥

**Address :**

**No 203 Preah**

**Norodom Bld.**

**Phnom Penh Cambodia**

**Tel : 023 219 065**





ព្រះរាជពិធីគោរពព្រះវិញ្ញាណក្ខន្ធព្រះករុណា
ព្រះបរមរតនកោដ្ឋ គម្រប់ខួប ១ ឆ្នាំ
បានប្រព្រឹត្តទៅនៅទូទាំងប្រទេស

៩





រដ្ឋសភានីតិកាលទី ៥
បន្តបើកសម័យប្រជុំលើកទី ១

១២







កិច្ចប្រជុំកំពូលអាស៊ានលើកទី ២៣
និងកិច្ចប្រជុំកំពូលពាក់ព័ន្ធនានា
នៅប្រទេសប្រ៊ុយណេ

១៣





ឯកឧត្តម **ឆេង ខន** ចុះសួរសុខទុក្ខ
និងផ្តល់អំណោយជូនប្រជាពលរដ្ឋរងគ្រោះ
ដោយទឹកជំនន់ នៅខេត្តកណ្តាល ព្រៃវែង
និងខេត្តបាត់ដំបង

១៧


## ក្របមុខ

**ព្រះករុណា ព្រះមហាវីរក្សត្រ**

**ព្រះបរមរតនកោដ្ឋ**

*ស្ថិតស្ថេរជានិរន្តរ៍*

*ក្នុងដួងចិត្តរបស់ប្រជារាស្ត្រខ្មែរ*

# មាតិកា

# Contents


*វិចារណកថា :* រូបរួមកម្លាំងជាតិ ជម្នះផលវិបាកនៃគ្រោះទឹកជំនន់ដ៏ធ្ងន់ធ្ងរ.............................. ៣

➩ សេចក្តីថ្លែងការណ៍របស់គណបក្សប្រជាជនកម្ពុជា អំពីកំណែទម្រង់ការបោះឆ្នោត......... ៤

➩ បញ្ជីរាយនាមសមាសភាពរាជរដ្ឋាភិបាលសម្រាប់នីតិកាលទី ៥ នៃរដ្ឋសភា.................. ៥

➩ សកម្មភាពសមាជិកព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស ................................ ១៨

➩ សកម្មភាពរបស់ក្រុមការងារយុវជនគណបក្ស ..........................................................២១

➩ លទ្ធផលមួយចំនួននៃវិស័យសេដ្ឋកិច្ច.....................................................................២២

➩ ឆ្នាំ ២០១៣ គម្រោងវិនិយោគបានកើនឡើងលើសឆ្នាំមុនជាង ២០០%.................................២៣

➩ ការបង្កបង្កើនផលស្រូវវស្សាឆ្នាំនេះលឿនជាងឆ្នាំមុន តែត្រូវខូចខាត
ដោយទឹកជំនន់ ៤,៥ ម៉ឺនហិកតា.............................................................................. ២៤

➩ ទិន្នន័យប៉ះពាល់ និងខូចខាតដោយទឹកជំនន់ទឹកភ្លៀងលើកទី ២ និងជំនន់ទន្លេមេគង្គ.................. ២៥

➩ វិស័យធនាគារមានស្ថេរភាព និងមានកំណើនបន្តទៀត.................................................... ២៦

➩ *ចំណេះដឹងទូទៅ :* សហរដ្ឋអាមេរិកចេញផុតពីការក្ស័យធនឆ្នាំ ២០១៣
តែអាចជួបវិបត្តិនេះម្តងទៀតនៅដើមឆ្នាំ ២០១៤............................................................ ២៨

➩ *ទឹកដីមាតុភូមិ :* ឃុំតាលោ : កាន់តែអភិវឌ្ឍ កាន់តែទទួលបានការគាំទ្រ .............................. ២៩

➩ *កំណាព្យ :* វស្សាភ្លៀងធំ......................................... *សំណើច* .................................. ៣១

ទស្សនាវដ្តី

# ប្រជាជន

THE PRACHEACHUN MAGAZINE



ឆ្នាំទី១៣ លេខ ១៤៩ ខែតុលា ឆ្នាំ ២០១៣



ការដ្ឋានស្ថាបនាសួនច្បារ
ផ្លូវ និងច្រាំងទន្លេចតុមុខ
ត្រើយខាងកើតចាប់ពី
គល់ស្ពានជ្រោយចង្វារហូត
ដល់មុខព្រះបរមរាជវាំង
រាជធានីភ្នំពេញ





ចែកជូនដោយឥតគិតថ្លៃ